ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ជីវនារីខ្មែរ
- ការឆ្លុះបញ្ចាំងអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងរបបក្រោយៗមកទៀត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ១០០ ខែមេសា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០០ ខែមេសា ឆ្នាំ២០០៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រៈ វីរនារីខ្មែរ ....................................................................១

**ផ្នែកឯកសារ**

◆ អ្នកស្រុកថ្មពួក ចូលរួមដាក់ពាក្យបណ្តឹងដើម្បីយុត្តិធម៌ ...........................២

◆ ការពាំនាំប្រវត្តិសាស្ត្រខ្មែរក្រហមទៅឲ្យក្មេងជំនាន់ក្រោយ .....................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កម្មវិធីសម្រាប់ការអប់រំនិស្សិត ................................................១៣

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម.................................១៤

◆ ស្រី ពោះ អតីតកម្មាភិបាលខ្មែរក្រហមភ្នំវល្លិ៍..................................១៩

◆ ការឆ្លុះបញ្ចាំងអំពីរបបកម្ពុជាប្រជាធិបតេយ្យ .................................២១

◆ ឌិត ប្រន ៖ ជនរងគ្រោះនៃរបបវាលពិឃាត ..................................២៤

**ផ្នែកច្បាប់**

◆ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹង .......................២៥

◆ ការប្តឹងជំទាស់ទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា ...............៣១

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ................៤១

◆ ប្រវត្តិនិងតម្លៃញ្ញត្តិរណសិរ្សចំពោះដំណើរការអង្គជំនុំជម្រះ ............៤៧

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ....................................៥១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការទន្ទឹងរង់ចាំរបស់គ្រួសារខ្ញុំ ................................................៥៥

◆ ខ្ញុំរង់ចាំមើលលទ្ធផលនៃការកាត់ទោសមេខ្មែរក្រហម....................៥៨

◆ សេចក្តីអំពាវនាវពីជនរងគ្រោះក្នុងរបបខ្មែរក្រហម......................៦០




ការណែនាំអំពីការបំពេញពាក្យបណ្តឹង



សកម្មបំពេញពាក្យបណ្តឹងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នាដៃលេខនេះ ៖** លី សុខឃាង, សើ សាយ្យាណា, គង់ សុកគឿន, សារ៉ា ចន ឌីគីន, អ៊ែន ហាញឌល, ឌី ខាំបូលី, វីលៀម ដេ ស្គលថ៍, អេតែល ហ៊ីហ្គនេត, ប្រាក់ កែវតារា, ហាវ សោភា, សេង គន្ធី, ភី វ៉ាន់ដែន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** លី សុផល **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# វីរនារីខ្មែរ

*ស្ត្រីទាំងអស់ដែលជាជនរងគ្រោះ ហើយដែលរស់រានមានជីវិតក្រោយរបបកម្ពុជាប្រជាធិបតេយ្យគឺជាវីរនារីខ្មែរ ។ នៅក្រោយដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំទៅក្នុងឆ្នាំ ១៩៧៩ ស្ត្រីគឺជាចំនួនភាគច្រើននៃប្រជាជនកម្ពុជា ដែលមានដល់ទៅប្រមាណ៧០ភាគរយ ដែលភាគច្រើនគឺជាស្ត្រីមេម៉ាយ ។ ស្ត្រីទាំងអស់នេះហើយគឺជាកម្លាំងស្នូលក្នុងការកសាងមាតុភូមិកម្ពុជាពីបាតដៃទទេ និងជាអ្នកស្តារសេដ្ឋកិច្ចជាតិឡើងវិញនៅក្នុងពេលដែលមាតុភូមិកម្ពុជាកំពុងប្រឈមមុខនឹងសង្គ្រាមរ៉ាំរ៉ៃជាមួយនឹងក្រុមខ្មាំងខ្មែរក្រហមនៅតាមព្រំដែនថៃនៅឡើយ ។ ស្ត្រីទាំងនេះគឺជាអ្នកធ្វើឲ្យរស់ឡើងវិញនូវវប្បធម៌ ការអប់រំ ទំនៀមទម្លាប់ និងប្រពៃណីដែលស្ទើររលាយសាបសូន្យដោយស្នាដៃខ្មែរក្រហម ។ ស្ត្រីទាំងអស់នេះហើយ គឺជាដួងព្រលឹងរបស់ជាតិ ។*

*ដើម្បីជាសក្ខីភាពឆ្លុះបញ្ចាំងឲ្យឃើញពីវីរភាពរបស់ស្ត្រីខ្មែរទាំងអស់ ខ្ញុំយល់ឃើញថារូបសំណាកជាតិមួយគួរតែត្រូវបានស្ថាបនាឡើងដើម្បីជាការចងចាំនូវប្រវត្តិសាស្ត្រដ៏ជូរចត់មួយទុកជាមេរៀនសម្រាប់កូនខ្មែរនិងសាកលលោក ហើយក៏ជាការចងចាំនូវវីរភាពរបស់ស្ត្រីខ្មែរច្រើនជំនាន់ដែលកសាងជាតិសម្រាប់កូនចៅបច្ចុប្បន្ននិងតទៅថ្ងៃអនាគត ហើយក៏ដើម្បីទុកជាការរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែរ ។*

*រូបសំណាកនោះគឺអាចជារូបស្ត្រីម្នាក់ ឬស្ត្រីបីកូនឈរពេញមួយជំហរដ៏ធំសម្បើមដែលអាចមានកម្ពស់ដល់ទៅ២០ម៉ែត្រ តំណាងឲ្យសតវត្សរ៍ទី២០ ។ រូបសំណាកទាំងមូលត្រូវបានបែងចែកជា៧ផ្នែកដែលបង្ហាញនូវអត្ថន័យដាច់ដោយឡែកពីគ្នា ក្នុងនោះបីផ្នែកខាងក្រោមនៃរូបសំណាកត្រូវបានកប់ទៅក្នុងដីតំណាងឲ្យប្រជាជនខ្មែរជាច្រើនលាននាក់ដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយបួនផ្នែកដែលស្ថិតនៅលើដីតំណាងឲ្យប្រជាជនដែលបានរួចផុតជីវិតពីការសម្លាប់ដែលភាគច្រើនអ្នកដែលនៅរស់រានមានជីវិតគឺស្ត្រី ។*

*រូបសំណាកនេះគួរតែកសាងដាក់បែរមុខទៅទិសខាងលិច ដែលជាទិសនៃសេចក្តីស្លាប់ ប៉ុន្តែនៅពេលល្ងាចវេលាព្រះអាទិត្យរៀបលិចយើងអាចឃើញមុខរូបសំណាកជានិមិត្តរូបនៃការចងចាំមិនភ្លេច ។ នៅពេលដែលព្រះអាទិត្យរះពីទិសខាងកើតវានឹងមានពន្លឺចាំងស្រមោលមកលើរូបសំណាកដែលជានិមិត្តរូបនៃវិញ្ញាណអ្នកដែលបានស្លាប់ទៅរាប់លាននាក់ដែលនៅជាមួយយើងជារៀងរហូត ។ មនុស្សមិនអាចរស់នៅដោយគ្មានការចងចាំបានទេ ។ ស្រមោលធម្មជាតិនៃរូបសំណាកគឺជានិមិត្តរូបនៃការចងចាំ ។ រូបសំណាកនេះមានលក្ខណៈជាសិល្បៈនិងមនុស្សធម៌ជាជាងការសងសឹកនិងគុំកួន ហើយក៏ជាតំណាងឲ្យសន្តិភាពនិងការអភិវឌ្ឍគ្រប់ទិវានារី៨មីនាដែរ ។*

*ទីតាំងនៃការសាងសង់សំណង់នោះ គួរតែមានទីតាំងនៅសួនច្បារសម្តេច ហ៊ុន សែន ក្បែរមាត់ទន្លេឬសួនច្បារខាងលិចវត្តភ្នំ ព្រោះជាទីសាធារណៈសម្រាប់មនុស្សទូទៅស្វែងយល់ពីរបបប្រល័យពូជសាសន៍នេះទុកជាមេរៀនដើម្បីជាការទប់ស្កាត់អំពើនេះមិនឲ្យកើតមានជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជាក៏ដូចជានៅទូទាំងសាកលលោកទាំងមូល ។ ពេលវេលានៃការសាងសង់សំណង់រូបសំណាកប្រវត្តិសាស្ត្រនោះគួរតែត្រូវបានរៀបចំធ្វើឡើងទន្ទឹមនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ ។* **ឆាំង យុ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

*មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។*

*យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។* **ស៊ិន សុធីតា**

# អ្នកស្រុកថ្មពួក ចូលរួមដាក់ពាក្យបណ្តឹងដើម្បីយុត្តិធម៌និងសំណងសមូហភាព

ស្រុកថ្មពួកជាស្រុកមួយដាច់ស្រយាលដែលមានចម្ងាយប្រហែលជា៤០គីឡូម៉ែត្រពីរួមខេត្តបន្ទាយមានជ័យនិងជាប់ព្រំដែននៃប្រទេសថៃ ។ ទោះបីជារបបខ្មែរក្រហមត្រូវបានផ្តួលរំលំនៅឆ្នាំ១៩៧៩ក៏ដោយ ក៏ស្រុកនេះនៅតែប្រឈមមុននឹងបញ្ហាអសន្តិសុខពេញអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងជាងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ។ ប្រជាជនបានទទួលរងនូវការវាយឆ្មក់និងឆក់ប្លន់ពីកងទ័ពព្រៃខ្មែរក្រហមជាញឹកញាប់ ។

ទើបតែនៅឆ្នាំ១៩៩៧ ក្រោយពេលដែលរាជរដ្ឋាភិបាលកម្ពុជាធ្វើសមាហរណកម្មរវាងមេដឹកនាំកងទ័ពព្រៃខ្មែរក្រហម ស្ថានភាពនៅតំបន់នោះមានស្ថិរភាពឡើងវិញ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ប្រជាជនមួយចំនួនធំនៅទីនោះនិងតំបន់ដាច់ស្រយាលផ្សេងទៀតមានលទ្ធភាពទទួលបានព័ត៌មានតិចតួចបំផុតដោយសារប្រព័ន្ធផ្សព្វផ្សាយមិនទាន់មានលក្ខណៈទូលំទូលាយ ពិសេសព័ត៌មានស្តីអំពីដំណើរការរបស់តុលាការចម្រុះដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីនាំយកអតីតមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតរបស់របបខ្មែរក្រហមមកកាត់ទោស ។

ដើម្បីឲ្យព័ត៌មានទាំងអស់នេះបានផ្សព្វផ្សាយទៅដល់ប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាលអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានកំពុងធ្វើការយ៉ាងសស្រាក់សស្រាំដោយបង្កើតនូវគម្រោងផ្សេងៗដើម្បីធ្វើយ៉ាងណាឲ្យប្រជាជនទទួលបានព័ត៌មានទាំងអស់នេះ ។ មជ្ឈមណ្ឌលឯកសារបានបង្កើតគម្រោងមួយដែលមានឈ្មោះថា«ដំណើរទស្សនកិច្ចមកកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» តាំងពីឆ្នាំ២០០៦ដើម្បីចូលរួមទស្សនានិងស្តាប់គ្រប់សវនាការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ រហូតដល់ដល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញតំណាងប្រជាជនមកពីគ្រប់ខេត្តក្រុងចំនួន៧០៤០នាក់ ។ អ្នកចូលរួមទាំងអស់នេះបានចែករំលែកការយល់ដឹងទៅដល់សហគមន៍របស់ខ្លួននៅពេលត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ។

នៅពីថ្ងៃទី៤ខែកុម្ភៈមានតំណាងប្រជាជនស្រុកថ្មពួកចំនួន



សកម្មភាពបំពេញពាក្យបណ្តឹងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

១៨រូបត្រូវបានអញ្ជើញឲ្យមកចូលរួមស្តាប់សវនាការលើបណ្តឹងឧទ្ធរណ៍ស៊ុំនៅក្រៅឃុំរបស់ នួន ជា ។ នៅពេលជាមួយគ្នានោះ អ្នកទាំងអស់ក៏បានចូលរួមបំពេញទម្រង់បែបបទជនរងគ្រោះ ។ នៅក្នុងការបំពេញពាក្យបណ្តឹងមានសរសេររៀបរាប់អំពីការឈឺចាប់និងការបាត់បង់សាច់ញាតិនៅក្នុងរបបកម្ពុជាធិបតេយ្យ ព្រមទាំងបញ្ជាក់អំពីការរំពឹងទុកនិងការទាមទារសំណងខ្វះៗ សម្រាប់ជាប្រយោជន៍ក្នុងសហគមន៍របស់ខ្លួន ។ អ្នកទាំងអស់រំពឹងថា ពាក្យបណ្តឹងរបស់គាត់នឹងក្លាយជាឯកសារដ៏សំខាន់សម្រាប់តុលាការប្រើប្រាស់ ។ ខាងក្រោមនេះជាការបរិយាយរឿងរបស់អ្នកដាក់ពាក្យបណ្តឹង ។

យន់ យឹន អាយុ៤៧ឆ្នាំ ជាក្រុមប្រឹក្សាឃុំគោករមៀត ស្រុកថ្មពួក បានសម្តែងពីអារម្មណ៍រីករាយចំពោះការអញ្ជើញនេះ ព្រោះថាជាឱកាសមួយដើម្បីគាត់បានបំពេញទម្រង់ពាក្យបណ្តឹងដ៏មានសារប្រយោជន៍ជូនតុលាការ ។ យឹន បានប្រាប់ឲ្យដឹងអំពីមូលហេតុដែលគាត់បានដាក់ពាក្យប្តឹងនេះថា គាត់មានការឈឺចាប់ចំពោះទង្វើដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់ និងសាច់ញាតិរបស់គាត់ ជាពិសេសការឈឺចាប់របស់ខ្លួនគាត់ផ្ទាល់តែម្តង ។

យឹន បានបាត់បង់បងប្រុសម្នាក់និងឪពុកមាពីរនាក់នៅក្នុងឆ្នាំ១៩៧៨ ។ អ្នកទាំងបីត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធនឹងរដ្ឋការនៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ ហេតុការណ៍នេះកើតឡើងមុនមួយថ្ងៃ គឺនៅល្ងាចថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៨ ប្រធានសហករណ៍បានកោះហៅប្រជាជនទូទាំងសហករណ៍គោករមៀតប្រហែលជាងបីរយនាក់ឲ្យទៅប្រជុំដើម្បីត្រៀមខ្លួនចេញដំណើរទៅរៀនសូត្រនៅថ្ងៃស្អែក ។ បងប្រុសនិងឪពុកមាពីរនាក់របស់ យឹន ស្ថិតនៅក្នុងចំណោមអ្នកភូមិ៣៧នាក់ដែលបានចុះឈ្មោះទៅប្រជុំដែរ ។ ប្រធានសហករណ៍បានចែកខ្មៅដៃនិងសៀវភៅម្នាក់មួយក្បាលសម្រាប់កត់ត្រារៀនសូត្រ ។ ព្រឹកឡើងអ្នកដែលមានឈ្មោះទាំងប៉ុន្មានបានចាកចេញពីភូមិដោយគ្មាននរណាម្នាក់ដឹងថាទៅរៀនសូត្រនៅកន្លែងណាទេ ។ ចាប់តាំងពីពេលនោះមក យឹន មិនដែលបានឃើញអ្នកទាំងបីវិលត្រឡប់មកភូមិវិញឡើយ ។ ក្រោយឆ្នាំ១៩៧៩ សាកសពទាំង៣៧នេះត្រូវប្រជាជនរកឃើញនៅក្នុងរណ្តៅចំនួនបីនៅក្នុងព្រៃមួយដែលមានចម្ងាយប្រហែល៥០០ម៉ែត្រពីភូមិប៉ុណ្ណោះ ។ យឹន អះអាងបញ្ជាក់ថា *«សាកសពរកឃើញនៅឆ្នាំ១៩៧៩ចំនួនបីរណ្តៅសម្រាប់តែភូមិខ្ញុំទេ...ពេលរាប់សពទៅឃើញចំនួន៣៧មែន»* ។ បច្ចុប្បន្នរណ្តៅនេះត្រូវប្រជាជនភ្ជួរធ្វើស្រែពីលើអស់ទៅហើយ ។

នេះជាលើកទី១ហើយដែល យឹន បានមកចូលរួមក្នុងកម្មវិធីបែបនេះ ដែលធ្វើឲ្យគាត់មានឱកាសសរសេររៀបរាប់អំពីព្រឹត្តិការណ៍ជាក់ស្តែងដែលគាត់ជួបប្រទះនិងឃើញនៅក្នុងរបបនោះ ដើម្បីជាតឹកតាងមួយដល់តុលាការ ។ យឹន បានជួបប្រទះនូវព្រឹត្តិការណ៍ពីរដែលគួរឲ្យរន្ធត់នៅក្នុងជីវិតរបស់គាត់ ។ នៅក្នុងឆ្នាំ១៩៧៧ យឹន បានឃើញការសម្លាប់នៅចំពោះមុខគាត់ ដោយឈ្លបខ្មែរក្រហមវាយសម្លាប់បុរសម្នាក់ ឈ្មោះតាឈឹមជាអ្នកភូមិកណ្តាល ឃុំគោករមៀត ស្រុកថ្មពួក ។ តាឈឹម ត្រូវបានបញ្ជូនទៅនៅសហករណ៍មួយដែលជាកន្លែងអត្តខាត់បំផុត ។ នៅពេលដែលគាត់វិលត្រឡប់មកភូមិវិញ គាត់គាស់បានដំឡូងមួយមើមតូចហូប ពេលនោះខ្មែរក្រហមមកទាន់ ក៏វាយគាត់រហូតដល់ស្លាប់តែម្តង ។ ហេតុការណ៍រន្ធត់នេះបានធ្វើឲ្យ យឹន ចងចាំមិនភ្លេចនិងមិនអាចអត់ឱនទោសឲ្យបាន ពីព្រោះថា ប្រសិនបើគិតទៅតាមច្បាប់វិញ ទោសកំហុសរបស់ តាឈឹម មិនអាចដល់ស្លាប់នោះទេ ។ យឹន និយាយថា *«កំហុសតិចតួចណាស់ ព្រោះបើមើលទៅដំឡូងធំជាងមេដើងបន្តិចប៉ុណ្ណោះ វាមិនគប្បីវាយឲ្យគាត់ស្លាប់នោះទេ»* ។ លើកទី២ យឹន បានឃើញខ្មែរក្រហមបណ្តើរមនុស្សចំនួន៤០នាក់ចេញពីភូមិរោគខាងកើតភ្នំស្រុកយកទៅសម្លាប់ចោលនៅភូមិគោករមៀត ឃុំគោករមៀត ។ យឹន មិនបានឃើញសកម្មភាពសម្លាប់របស់ខ្មែរក្រហមភ្លាមទេ ប៉ុន្តែប្រហែលជាប្រាំពីរថ្ងៃក្រោយ គាត់បានឃើញសាកសពទាំងនោះដោយចៃដន្យនៅទីវាលចម្ការមួយឈ្មោះថា «ព្រៃគោកទ្រង់មាន់» ។ សាកសពនោះ មិនបានកប់ត្រឹមត្រូវឡើយ ។ យឹន អះអាងថា *«ដំបូងខ្ញុំឃើញគេបណ្តើរប្រជាជនប្រហែលមួយសប្តាហ៍មុន ។ ពេលខ្ញុំច្រូតស្រូវហើយ ខ្ញុំរែកទៅបត់ជើងនៅកន្លែងមួយចម្ងាយប្រហែលមួយរយម៉ែត្រខ្ញុំបានឃើញសាកសពនៅលើគោកហើយខ្ញុំក៏បានរាប់សាកសពទាំងអស់គឺឃើញចំនួន៤០នាក់ដូចពេលខ្ញុំឃើញបណ្តើរមកមែន»* ។ យឹន បន្តថា សន លេន

ជាប្រធានសហករណ៍ដែលបញ្ជូនពីភូមិភាគនិរតី មកកាន់សហករណ៍ភូមិភាគពាយ័ព្យ ជាអ្នកដឹកនាំការសម្លាប់នេះ ។ ការសម្លាប់នេះកើតឡើងប្រហែលក្នុងខែមិថុនា ឆ្នាំ១៩៧៨ រយៈពេលពីរខែមុនពេលយកបងប្រុសនិងឪពុកមារបស់គាត់ទៅរៀនសូត្រ ។ យឺន ដឹងថានៅតំបន់ផ្សេងៗ មានការសម្លាប់ភាពសាហាវដាងសហករណ៍ភូមិឃុំគាត់ទៅទៀត មិនត្រឹមតែសម្លាប់ប្រជាជនទេថែមទាំងសម្លាប់មេដឹកនាំធំៗរបស់ខ្លួនទៀត ។ តាមការប៉ាន់ស្មានរបស់ យឺន បានឲ្យដឹងថា នៅទូទាំងឃុំរបស់គាត់មានប្រជាជនស្លាប់ប្រហែល ៦០០នាក់ ហើយមានគ្រួសារមួយចំនួនបានស្លាប់ផុតពូជ ។

យឺន ជាយុវជនកងចល័តស្រុកព្រះនេត្រព្រះ ហើយត្រូវបញ្ជូនឲ្យទៅលើទំនប់នៅអាងត្រពាំងថ្ម ដោយត្រូវបង្ខំឲ្យធ្វើការធ្ងន់ៗនិងទទួលរបបអាហារមិនគ្រប់គ្រាន់បណ្តាលឲ្យកើតជំងឺហើម ។ ដោយការអត់ឃ្លាន យឺន ដើររកបេះស្លឹកឈើណាដែលអាចហូបបានដើម្បីជំនួសរបបរបស់គាត់ ។ «ខ្ញុំស៊ីតាំងពីស្លឹកខ្ទឹប ស៊ីស្លឹកឈើណាដែលខ្ញុំអាចហូបបាន» ។ យឺន មិនដែលមានឱកាសជួបឪពុកម្តាយបងប្អូនឡើយរហូតដល់ឆ្នាំ១៩៧៨ ។ នៅក្នុងឆ្នាំនោះមានការចោទប្រកាន់ពីភូមិភាគនិរតីថា អ្នកភូមិភាគពាយ័ព្យក្បត់អង្គការ ហើយមានការចាប់ចងមេដឹកនាំធំៗនៅភូមិភាគពាយ័ព្យ ។ នៅពេលនោះកងចល័តរបស់គាត់ត្រូវបានរំសាយ ហើយគាត់ក៏វិលត្រឡប់មកសហករណ៍វិញ ។

នៅខែតុលា ឆ្នាំ១៩៧៨ យឺន បានរៀបការប្រពន្ធដើម្បីគេចពីការកែនទៅធ្វើកងទ័ពឡើងសមរភូមិប្រយុទ្ធជាមួយវៀតណាម ។ ប៉ុន្តែក្រោយពេលរៀបការ យឺន ត្រូវទទួលការចោទប្រកាន់ថា គាត់មានប្រវត្តិរូបមិនល្អ មានបងប្រុសម្នាក់រត់គេចទៅប្រទេសថៃ(សព្វថ្ងៃរស់នៅប្រទេសបារាំង) ។ យឺន បានចាកចោលប្រពន្ធទៅលាក់ខ្លួននៅក្នុងព្រៃរហូតដល់ថ្ងៃជ័យជម្នះឆ្នាំ១៩៧៩ ទើបវិលត្រឡប់មករួមរស់ជាមួយប្រពន្ធវិញ ។

ក្រោយពីរបបនេះដួលរលំ យឺន បានចូលរួមដាក់ពាក្យប្តឹងម្តងដែរ ប៉ុន្តែការដាក់ពាក្យប្តឹងនៅពេលនោះ គឺគ្រាន់តែជាការធ្វើញត្តិរួមមួយដែលមានតំណាងម្នាក់នៅក្នុងភូមិឃុំដើរចុះស្រង់ស្ថិតិសាច់ញាតិដែលស្លាប់នៅក្នុងរបបនោះ ។ យឺន ក៏មិនបានគិតថាការបំពេញពាក្យបណ្តឹងឬញត្តិគាំទ្រនោះមានប្រយោជន៍ប៉ុនណានោះទេ ហើយគាត់ក៏មិនសង្ឃឹមថាមានតុលាការការកាត់ទោសមេខ្មែរក្រហមពិតប្រាកដដូចពេលនេះដែរ ។ អ្វីដែលគាត់គិតឃើញនៅពេលនោះគឺការរស់រានមានជីវិតពីរបបនេះ ។ យឺន បានលើកឡើងថា «មិនសូវជាដឹងប៉ុន្មានទេគេឲ្យបំពេញចេះតែបំពេញតាមគេទៅ ហើយមិនបានគិតថាយុត្តិធម៌មានន័យយ៉ាងម៉េចផងទេ... ពេលងើបពីស្លាប់នេះមិនបានគិតដល់សេចក្តីស្លាប់ពេលមុននោះទេ» ។ យឺន បានបង្ហាញពីអារម្មណ៍រីករាយថា ពាក្យបណ្តឹងគាត់សរសេរនោះមិនដូចការដាក់ពាក្យប្តឹងកាលពី៣០ឆ្នាំមុនទេ ពីព្រោះថាគាត់មានគោលបំណងច្បាស់លាស់ដោយសារគាត់បានស្វែងយល់ពីព្រឹត្តិការណ៍ផ្សេងៗនិងដំណើរការខ្មែរក្រហមច្រើន ។ លើសពីនេះទៅទៀត គាត់បានបំពេញតួនាទីប្រជាពលរដ្ឋម្នាក់និងជាតំណាងឲ្យសាច់ញាតិជនរងគ្រោះដែលបានស្លាប់ក្នុងរបបនេះបានចូលរួមស្វែងរកយុត្តិធម៌ក្នុងដំណើរកាត់ទោសនេះ ។ «យើងបានសរសេរពីសកម្មភាពរបស់ខ្លួនយើងនិងសាច់ញាតិរបស់យើងផ្ទាល់ខុសពីពេលមុនដែលយើងគ្រាន់តែបង្ហាញឈ្មោះថាសមាជិកគ្រួសារបានរងគ្រោះប៉ុណ្ណោះ ។ ឈ្មោះនេះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។ ក្នុងនាមខ្ញុំជាជនរងគ្រោះម្នាក់ដែរ ហើយនៅរស់រានមានជីវិតខ្ញុំត្រូវធ្វើអ្វីៗជូនអ្នករងគ្រោះដើម្បីឲ្យវិញ្ញាណក្ខន្ធរបស់អ្នកទាំងអស់


អ្នកភូមិកំពុងបំពេញពាក្យបណ្តឹងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

បានដឹងថាខ្ញុំជាសាច់ញាតិបានបំពេញកិច្ចការជូនគាត់ជូនអ្នករងគ្រោះនិងខ្លួនឯង» ។ យឹន បន្ថែមថា «អស់ចិត្តត្រង់ថា ខ្ញុំបានបំពេញពាក្យបណ្តឹងដើម្បីបញ្ជូនដល់តុលាការ ហើយម្យ៉ាងទៀតខ្ញុំបានចូលរួមសវនាការជាក់ស្តែងតែម្តង» ។

ចំណែក រឿង រ៉េន អាយុ៥៧ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំ បច្ចុប្បន្នរស់នៅភូមិទ្រាស ឃុំគោកកថិន បានមានប្រសាសន៍ថា គាត់សប្បាយចិត្តដែលបានចូលរួមនៅក្នុងការកាត់ក្តីនេះ ព្រោះថាជាលើកទី១សម្រាប់ជីវិតរបស់គាត់ចាប់តាំងពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ។

ថ្វីដ្បិតតែថា ក្រុមគ្រួសាររបស់ រ៉េន មិនត្រូវបានជម្លៀសចេញពីភូមិនិងមិនមានបាត់បង់សាច់ញាតិណាម្នាក់នៅក្នុងគ្រួសារក៏ដោយក៏ រ៉េន មកចូលរួមបំពេញពាក្យបណ្តឹងនេះក្នុងគោលបំណងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ដែលបានស្លាប់និងសម្លាប់នៅក្នុងរបបខ្មែរក្រហម ។ ម្យ៉ាងទៀត រ៉េន ក៏ជាជនរងគ្រោះម្នាក់ដែលទទួលទារុណកម្មផ្នែករាងកាយនិងបាត់បង់ទ្រព្យសម្បត្តិអស់ជាច្រើនដែរ ។ រ៉េន បានរៀបរាប់ពីហេតុការណ៍មួយចំនួនដែលគាត់បានជួបប្រទះក្នុងឆ្នាំ១៩៧៧ដើម្បីភ្ជាប់ជាមួយពាក្យបណ្តឹងរបស់គាត់ ។ រ៉េន បាននិយាយរំឭកឡើងវិញថា ថ្ងៃមួយពេលគាត់កំពុងដេរខោអាវរហែកៗនៅសហករណ៍ ពេលនោះយោធាខ្មែរក្រហមបានចុះមកហ៊ុមព័ទ្ធភូមិរបស់គាត់ ហើយបញ្ជាឲ្យប្រធានសហករណ៍ដើរស្រង់ស្ថិតិយកឈ្មោះអ្នកដែលធ្លាប់ធ្វើទាហាននិងមានប្រវត្តិរូបជាប់ខ្សែស្រឡាយវៀតណាម ។ ប្រធានសហករណ៍ភូមិទ្រាសប្រមូលឈ្មោះប្រជាជនបានចំនួន២០គ្រួសារដែលអ្នកទាំងនោះជាអ្នកមូលដ្ឋាននិងប្រជាជន១៧មេសា ដោយកុហកថា បញ្ជូនទៅធ្វើការនៅស្រុកស្វាយចេក ។ អ្នកទាំងនេះត្រូវបានដឹកចេញពីភូមិនៅពេលព្រលប់ លុះព្រឹកឡើងទើបដឹងថាអ្នកទាំងអស់ត្រូវបានសម្លាប់ ។ «យប់បន្តិចទើបដឹកចេញពីភូមិ ។ ចេញមកមិនដឹងយកទៅសម្លាប់ទេ ព្រឹកឡើងទើបដឹង ។ ឃើញរណ្តៅលុបថ្មីឈាមនៅល្ហាចល្ហឹម ហើយខោអាវព្រឹកឡើងទៅសហករណ៍វិញ ។ ចែកឲ្យអ្នកដែលនៅរស់» ។ ក្រោយពីសម្លាប់រួច យោធាទាំងនោះបានមកហ៊ុមព័ទ្ធភូមិរបស់គាត់ម្តងទៀត ហើយធ្វើការឆែកឆេរក្រែងមាននៅសេសសល់ទៀត ។

ពាក ធឿយ អាយុ៥៨ ឆ្នាំប្រកបមុខរបរធ្វើស្រែ រស់នៅភូមិបន្ទាយឆ្មារខាងជើង ឃុំបន្ទាយឆ្មារ ។ ធឿយ ធ្លាប់បានដឹងព័ត៌មានអំពីតុលាការនេះខ្លះដែរ ហើយគាត់ចង់ដាក់ពាក្យប្តឹងនេះយូរហើយ តែមិនដឹងថាតើត្រូវដាក់ពាក្យនៅកន្លែងណា ។ ឱកាសល្អដែលគាត់មកចូលរួមពេលនេះ ធឿយ សម្រេចចិត្តបំពេញពាក្យបណ្តឹងដោយភ្ជាប់មកជាមួយនូវព័ត៌មានបន្ថែមទាក់ទងនឹងឧក្រិដ្ឋ-កម្មរបស់ខ្មែរក្រហម ។ ធឿយ ចង់ធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ធឿយ បានឲ្យដឹងថា គាត់ចង់ឲ្យតុលាការកាត់ទោសមេខ្មែរក្រហមមិនមែនដើម្បីសម្រាប់ឪពុករបស់គាត់ម្នាក់នោះទេ គឺសម្រាប់ជនរួមជាតិទាំងមូលបានធូរស្រាលនិងបំបាត់កង្វល់ដែលដក់ជាប់នៅក្នុងចិត្តដែលពីមុនមកមិនទាន់មាននរណាដោះស្រាយ ។



អ្នកភូមិកំពុងស្តាប់ការពន្យល់ពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបំពេញពាក្យបណ្តឹង

នៅសម័យនោះ ឪពុករបស់ ធឿយ ត្រូវកម្មាភិបាលយោធាចាប់យកទៅសម្លាប់ចោលដោយសារគាត់ជាជំទប់ទីមួយ និងជាមេទាហានស្ម័យគ្រាណក្នុងរបបលន់នល់ ។ ចំណែក ធឿយ ត្រូវបញ្ជូនទៅកងចល័តស្រុកនិងចាត់តាំងឲ្យទៅលើកទំនប់ទឹកពីរកន្លែងគឺនៅអាងជើងគ្រះនិងអាងត្រពាំងថ្ម។ នៅទីនោះ ធឿយ បានទទួលការលត់ដំទាំងផ្នែករាងកាយនិងស្មារតី ។

អាងជើងគ្រះមានប្រវែង៣៣០០ម ស្ថិតនៅភូមិបន្ទាយឆ្មារខាងជើង ឃុំបន្ទាយឆ្មារ ស្រុក

ថ្មពួក ខេត្តបន្ទាយមានជ័យ ។ អាងជើងគ្រុះចាប់ផ្តើមកសាងនៅឆ្នាំ១៩៧៧ ដោយអង្គការបានកែនកម្លាំងប្រជាជនប្រមាណជា ៥ពាន់នាក់ដើម្បីកសាងអាងទឹកនេះ ។

កម្លាំងទាំងអស់ត្រូវបានបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃជាមួយនឹងបបររាវៗ ។ ពេលល្ងាចក្រោយពីហូបបបររួច កម្លាំងធ្វើការទាំងអស់ត្រូវបើកប្រជុំរៀបចំជាពួក និងក្រុមដើម្បីដាក់ផែនការធ្វើយ៉ាងណាកុំឲ្យរាំងស្ទះដល់ការងារ ។ ក្នុងពេលគាត់កំពុងធ្វើការឈ្លបខ្មែរក្រហមដើរត្រួតពិនិត្យមើលទៅមកៗ ប្រសិនបើឃើញនរណាម្នាក់អង្គុយ ទោះជាឈឺក៏ដោយ ឈ្លបនោះនឹងធាក់មួយជើងឬពីរជើងជាការព្រមាន ។ បើអ្នកនោះនៅតែរឹងរូសទៀតប្រាកដជាត្រូវយកទៅសម្លាប់ចោលភ្លាម ។ ធឿយ ធ្វើការនៅទីនោះរយៈពេលជិតមួយឆ្នាំ ហើយធ្លាប់ទទួលរងការដាក់ទណ្ឌកម្មម្តងពីបទលួចដំឡូង គាត់ត្រូវកងឈ្លបវាយធ្វើបាបនិងកាត់បន្ថយរបបអាហារឲ្យនៅតែមួយពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ព្រមទាំងត្រូវដាក់ពិន័យឲ្យគាស់គល់ឈើឲ្យបានមួយរ៉ែ(៤០ម៉ែត្រការ៉េ)ក្នុងមួយថ្ងៃថែមទៀត ។ ធឿយ ត្រូវឈ្លបដោះលែងគាត់មកវិញដោយសារគាត់សម្រេចបានតាមផែនការ ។

អាងត្រពាំងថ្មមានទីតាំងនៅភូមិត្រពាំងថ្មកណ្តាល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ យុវជននិងយុវនារីនិងប្រជាជនដែលរស់នៅតំបន់៥ ត្រូវបានបញ្ជូនមកជីកអាងទឹកនេះ ។ អាងនេះចាប់ផ្តើមជីកនៅឆ្នាំ១៩៧៥ដល់ចុងឆ្នាំ១៩៧៦ដែលមានបណ្តោយ១០គីឡូម៉ែត្រនិងទទឹង៧គីឡូម៉ែត្រអាចស្តុកទឹកបាន៧លានម៉ែត្រគូបសម្រាប់ធ្វើស្រែប្រាំងនៅក្នុងស្រុកចំនួនពីរគឺស្រុកព្រះនេត្រព្រះនិងស្រុកភ្នំស្រុក ។ ធឿយ បានទៅធ្វើការនៅអាងត្រពាំងថ្មនេះនៅក្នុងដំណាក់ទី២ដែលអង្គការប្រមូលកម្លាំងទៅបំពេញដើម្បីឲ្យការសាងសង់នេះសម្រេចតាមផែនការ ។ ធឿយ ជួបប្រទះការលំបាកច្រើននៅអាងត្រពាំងថ្ម ។ អារម្មណ៍របស់គាត់មិននឹងនរទេដោយសារនៅពេលយប់មានការចាប់មនុស្សធ្វើទារុណកម្មនិងសម្លាប់ចោល ។ ធឿយ កើតជំងឺហើមដៃជើង ប៉ុន្តែគាត់ស៊ូទ្រាំធ្វើការទាំងលំបាកព្រោះ ខ្លាចឈ្លបយកទៅសម្លាប់ ។ ធឿយ ធ្លាប់បានឃើញការធ្វើទារុណកម្មនិងការសម្លាប់ដាក់ស្តែង «វាចងដៃមនុស្សដូចចងសេកដើរបណ្តើរចាក់បណ្តើរ...វាចាក់មួយការបិតឲ្យបងប្អូនអ្នកវែកដីឃើញកុំឲ្យយកគំរូតាម» ។ ចុងឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតីបានស្រាវជ្រាវគ្រួសារដែលមានប្រវត្តិ-ទាក់ទងទាហានលន់នល់ ហើយចាប់យកទៅទាំងគ្រួសារនៅក្នុងចំណោមនោះមានមួយគ្រួសារជាម្តាយមីងរបស់ ធឿយ ដែលប្តីរបស់គាត់ធ្លាប់ធ្វើជាទាហាន ។ ធឿយ បញ្ជាក់ថា «*នៅភូមិមានចាប់សម្លាប់ជាគ្រួសារ វាយកទៅម្តង១០ឬ២០គ្រួសារ*» ។ រណ្តៅខ្លះមានយ៉ាងតិចពី៥០-៦០នាក់ សព្វថ្ងៃទីតាំងទាំងនោះត្រូវប្រជាជនរានដីធ្វើស្រែចម្ការអស់ហើយ ។ នៅភូមិបន្ទាយឆ្មារប្រជាជនប្រមាណជា១៥គ្រួសារត្រូវបានសម្លាប់ ហើយក្នុងនោះមានមិត្តភក្តិគាត់ម្នាក់ដែលបានរត់រួចពីការសម្លាប់នេះ សព្វថ្ងៃរស់នៅប្រទេសកាណាដា ។ ក្រោយឆ្នាំ១៩៧៩ ធឿយ បានចូលរួមគាស់សាកសពជាមួយអ្នកភូមិដើម្បីយកអដ្ឋិធាតុមកធ្វើបុណ្យនិងតម្កល់ទុកនៅក្នុងស្តូប ។ ប៉ុន្តែអដ្ឋិធាតុទាំងនោះត្រូវកងទ័ពព្រៃខ្មែរក្រហមដុតបំផ្លាញអស់នៅពេលវាយឆ្មក់ចូលភូមិម្តងៗ ។

វាំង ឌី មានយោបល់មិនខុសពីអ្នកទាំងបីឡើយ គោលបំណងរបស់គាត់គឺចង់ទាមទារយុត្តិធម៌ឲ្យបងប្រុសពីរនាក់ដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមនិងជនរួមជាតិទាំងមូល ។ បងប្រុសទាំងពីររបស់ ឌី បានបាត់ខ្លួននៅពេលចូលធ្វើការក្នុងកងចល័ត ។ កាលណោះ ឌី ធ្វើជាប្រធានយុវជននៅមូលដ្ឋាន ។ ឌី ធ្លាប់បានឃើញនិងដឹងឮថាមានការសម្លាប់មនុស្សដែលមានប្រវត្តិជាទាហានដែរ «*គេចាប់ទាំងរទេះទាំងអស់១២គ្រួសារយកទៅវាយនៅខាងត្បូង ភូមិខ្ញុំចម្ងាយប្រហែលជាបីគីឡូម៉ែត្រ... អ្នកទាំងនោះត្រូវគេ[ខ្មែរក្រហម]ស្រាវជ្រាវដឹងប្រវត្តិថាជាទាហានវៀតណាម គេប្រមូលមកចុងក្រោយសម្លាប់អស់មួយសាទៅ*» ។ ជនរងគ្រោះត្រូវបានដឹកចេញពីភូមិចំនួន៥ ដែលនោះក្នុងមានបីគ្រួសារជាអ្នកភូមិរបស់ ឌី ផង ។ ឌី អះអាងថា នៅថ្ងៃនោះមានការប្រមូលប្រជាជនពីភូមិផ្សេងៗមកជួបជុំគ្នានៅភូមិរបស់គាត់ ហើយអ្នកនៅក្នុងភូមិមិនអនុញ្ញាតឲ្យដើរចេញពីភូមិឡើយ ។ ព្រឹកឡើងអ្នកទាំងនោះត្រូវបានកុហកថា ទៅដាំពោតនៅភូមិនេះភូមិនោះ ។ នៅថ្ងៃបន្ទាប់ឪពុករបស់គាត់បានទៅលើកទ្រូនៅឯស្រែចម្ងាយប្រហែលមួយគីឡូម៉ែត្រពីភូមិ ហើយក៏ប្រទះឃើញស្នាមឈាមនៅលើដីនិងស្នាមអូសសាកសពយកទៅកប់ ហើយសាកសពខ្លះកប់មិនទាន់

ជិត ។ ការសម្លាប់នោះកើតឡើងប្រហែលនៅចុងឆ្នាំ១៩៧៧ ។

## ទាមទារសំណងសម្រាប់សហគមន៍

តុលាការនេះបង្កើតឡើងក្នុងគោលបំណងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជាដែលបានរងគ្រោះក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ហើយជនរងគ្រោះអាចទាមទារសំណងដែលអាចបម្រើឲ្យផលប្រយោជន៍សមូហភាពប៉ុណ្ណោះ ។ តំណាងប្រជាជននៅស្រុកថ្មពួក យឺន សំណូមពរឲ្យមានការកសាងស្រះទឹករួមមួយសម្រាប់ប្រើប្រាស់នៅក្នុងភូមិរបស់គាត់ «ខ្ញុំសុំឲ្យជួយកសាងនូវស្រះទឹកមួយដែលជា «ស្រះទឹកសហគមន៍» កើតចេញពីសំណងសម្រាប់ជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបនោះ» ។ ចំណែក ធឿយ ក៏ចង់បានជាសំណងមួយសម្រាប់ផលប្រយោជន៍ឲ្យភូមិឃុំ ឬសហគមន៍របស់គាត់ដែរ ។ គាត់សុំឲ្យជួយជីកស្រះមួយសម្រាប់ប្រើប្រាស់នៅក្នុងភូមិ ។ ក្រៅពីនោះ ធឿយ សំណូមពរបន្ថែមសុំឯកសារ កាសែត ទស្សនាវដ្តី និងពង្រីកប្រព័ន្ធផ្សព្វផ្សាយឲ្យបានទូលំទូលាយ ពីព្រោះសព្វថ្ងៃគាត់អាចមើលទូរទស្សន៍តែពីរប៉ុស្តិ៍ប៉ុណ្ណោះ គឺប៉ុស្តិ៍លេខ៥និងប៉ុស្តិ៍បាយ័ន ។ វ៉ាំង ឌី សុំឲ្យមានការសង់ជាសាលារៀនសម្រាប់សម្រួលដល់ការធ្វើដំណើររបស់កូនចៅគាត់ និងកសាងផ្លូវថ្នល់សម្រាប់សម្រួលឲ្យប្រជាជនស្រុកថ្មពួកបានធ្វើដំណើរទៅណាមកណាដោយងាយស្រួល ។

## សំណូមពរ

ជាមួយគ្នានេះ យឺន បានសំណូមពរបន្ថែមសុំឲ្យអង្គការជាតិនិងអន្តរជាតិជួយជំរុញតុលាការឲ្យកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ៗចាប់ពីឆ្នាំ២០០៨នេះតទៅ ។ ក្រៅពីនេះ យឺន សំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយប្រជាជនដែលរងគ្រោះនៅក្នុងរបបនោះ ហើយដែលរស់នៅតាមតំបន់ដាច់ស្រយាលចូលរួមសវនាការក្រោយទៀតផង ។ ធ្វើបែបនេះជនរងគ្រោះនឹងអស់ចិត្តព្រោះដឹងថា រឿងនេះកំពុងតែកើតមានប្រាកដមែន ។

ចំណែក វ៉ែន បានសម្តែងពីអារម្មណ៍ខ្វល់ខ្វាយរបស់គាត់ថា តើមេដឹកនាំខ្មែរក្រហមនឹងត្រូវកាត់ទោសពិតប្រាកដឬយ៉ាងណា បើពេលនេះតុលាការចេះតែពន្យារពេលករណីនីមួយៗឲ្យយឺតយូរ នោះជាពិសេសការសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា ។ «ឃើញតែមិនទាន់អស់ចិត្តមិនទាន់ដឹងតើតុលាការនឹងសម្រេចយ៉ាងណានោះទេ ។ ខ្ញុំដូចពិបាកយល់ការពន្យារពេលនេះណាស់» ។ វ៉ែន មានសំណូមពរតែមួយគត់គឺធ្វើ យ៉ាងណារកយុត្តិធម៌ឲ្យបានត្រឹមត្រូវនិងឲ្យមានស្ថិរភាពទៅមុខទៀត ។

**លី សុផល**



អ្នកភូមិកំពុងបំពេញពាក្យបណ្តឹងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

# ការពាំនាំប្រវត្តិសាស្ត្រខ្មែរក្រហមទៅឱ្យក្មេងជំនាន់ក្រោយ

*កំពុងអង្គុយម្នាក់ឯងយ៉ាងស្ងៀមស្ងាត់នៅក្នុងខ្ទមរហែកក្បែរត្រពាំងរំចង់នៅខាងមុខផ្ទះ តូច ឡូន ដែលមានវ័យ៦៧ឆ្នាំ មានរាងកាយស្គមស្គាំងស្បែកជ្រីវជ្រួញ កំពុងសម្លឹងមើលក្រុមបញ្ចាំងខ្សែភាពយន្តដែលទៅពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខណៈពេលយើងកំពុងដើរសំដៅទៅរកគាត់ ។ ឡូន ទទួលស្វាគមន៍យើងយ៉ាងរាក់ទាក់ឲ្យអង្គុយនៅលើគ្រែរនាបឫស្សី ។ បន្ទាប់មកគាត់ ចាប់ផ្តើមសួរយើងថាមកពីខាងណា? ជាការឆ្លើយតបវិញ ក្រុមបញ្ចាំងកុនបានណែនាំសមាជិកកុនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងសកម្មភាពរបស់ក្រុមកុននៅក្នុងឃុំចំនួនពីររបស់ខេត្តស្វាយរៀង រួមទាំងឃុំដែល ឡូន កំពុងរស់នៅផង ។ សកម្មភាពទាំងអស់នេះរួមមានការបញ្ចាំងខ្សែភាពយន្តឯកសារការពិភាក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាមួយអ្នកភូមិនិងការចែករំលែកព័ត៌មានថ្មីស្តីអំពីដំណើរវិវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែល ឡូន និងមនុស្សភាគច្រើនស្គាល់ជាទូទៅថា ជាសាលាក្តីខ្មែរក្រហម ។*

*ការពន្យល់របស់យើង បានធ្វើឲ្យ ឡូន នឹកឃើញឡើងវិញអំពីអតីតកាលប្រកបដោយសោកនាដកម្មនៅក្នុងប្រទេសកម្ពុជា ។ ក្នុងអំឡុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រជាជន កម្ពុជាជិតពីរលាននាក់បានស្លាប់បាត់បង់ជីវិត ។ ឡូន រៀបរាប់យ៉ាងពិស្តារអំពីការឈឺចាប់របស់ប្រជាជនភូមិភាគបូព៌ាមុនឆ្នាំ១៩៧៥ រហូតដល់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ឡូន ដែលរស់នៅក្នុងឃុំកំពង់អម្ពិល ខេត្តស្វាយរៀង បានរៀបរាប់ប្រាប់យើងអំពីប្រវត្តិសាស្ត្រនានាទាក់ទងនឹងហេតុការណ៍ជ្រួលច្របល់ផ្នែកសង្គមនយោបាយ ដោយរាប់ពាក់ព័ន្ធទាំងការទម្លាក់គ្រាប់បែកជាប្រចាំ ការរីកដុះដាលយ៉ាងខ្លាំងនូវចលនាខ្មែរក្រហមនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ការសម្រិតសម្រាំងនិងការសម្លាប់ជាលក្ខណៈប្រព័ន្ធទៅលើប្រជាជននៅខាងបូព៌ា និងការខិតខំប្រឹងប្រែងរបស់ប្រជាជនក្នុងការកសាងជីវិតថ្មីនៅក្នុងឃុំកំពង់អម្ពិលដែលគ្របដណ្តប់ទៅដោយគ្រាប់មីនយ៉ាងច្រើនបន្ទាប់ពីការដួលរលំនៃរបបនេះ ។*

## ***ភាពវិបល្លាសមុនឆ្នាំ១៩៧៥***

*បន្ទាប់ពីទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់លើគ្រប់វិស័យនៅក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ។ ប៉ុន្តែនៅឆ្នាំ១៩៧០ លេចចេញឲ្យឃើញរបត់នយោបាយដ៏គួរឲ្យសោកសង្រេងដែលបាននាំប្រទេសដ៏តូចនេះទៅដល់ចំណុចមួយស្ទើរតែស្តារវិញមិនបានអស់ជាច្រើនសតវត្សរ៍ចាប់ពីពេលនោះមក ។ នៅក្នុងឆ្នាំ១៩៧០ សម្តេចដែលទទួលការគោរពយ៉ាងខ្លាំងពីប្រជាជន ត្រូវបានបណ្តេញចេញពីអំណាចដោយសេនាប្រមុខ លន់ នល់ ដែលបានគ្រប់គ្រងប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៧៥ ។ បន្ទាប់មក ប្រជាជនកម្ពុជាបានចាប់ផ្តើមចាត់ទុករដ្ឋប្រហារលន់ នល់ ថាជាបណ្តាសាមួយដែលត្រូវទទួលខុសត្រូវចំពោះជីវិតរស់នៅពោរពេញទៅដោយភាពត្រដាបត្រដួសក្រោយៗមកទៀត ។ ភាពលំបាកលំបិនរបស់ប្រជាជនកម្ពុជាបណ្តាលមកពីសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃរវាងរបបលន់នល់និងចលនាខ្មែរក្រហម ព្រមទាំងការទម្លាក់គ្រាប់បែកពីលើអាកាសបានបំផ្លិចបំផ្លាញជីវភាពរស់នៅរបស់ប្រជាជនចាប់ពីពេលនោះមក ។ របបលន់នល់មិនអាចជួយប្រជាជនឲ្យរស់នៅប្រកបដោយស្ថិរភាពបានទេ ហេតុដូច្នេះប្រជាជនបានសម្តែងនូវការមិនសប្បាយចិត្តចំពោះភាពគ្មានអំណាចរបស់របបនេះ ។*

*អ៊ុង ចំរើន ដែលមានវ័យ៦៣ឆ្នាំរស់នៅឃុំពងទឹក បានបញ្ជាក់ថា «...ប្រជាជនបន្តគោរពប្រណិប័តន៍សម្តេច សីហនុ និងឆ្លើយតបតាមការអំពាវនាវរបស់ព្រះអង្គថា សូមកូនចៅ (ប្រជាជនកម្ពុជា) ចូលព្រៃម៉ាគីដើម្បីតស៊ូប្រយុទ្ធប្រឆាំងខ្លាំងសត្រូវ...» ។ ស្រដៀងគ្នានេះដែរ សូ សាន ដែលមានវ័យ៦៣ឆ្នាំរស់នៅក្នុងឃុំពងទឹក បានប្រាប់យើងថា រដ្ឋប្រហារប្រឆាំងនឹងសម្តេច សីហនុ បានធ្វើឲ្យប្រជាជនមិនសប្បាយចិត្ត ។ សាន បាននិយាយបន្តថា ការយាងសម្តេចមកកាន់អំណាចវិញជាវិធានការតែមួយគត់ដែលអាចកែប្រែប្រទេសកម្ពុជាឲ្យក្លាយទៅជាសង្គមរីកលូតលាស់បាន*

។ ក្នុងចំណោមប្រជាជននៅខេត្តស្វាយរៀង ឡូន បានឲ្យ ដឹងថា ការទម្លាក់គ្រាប់បែកជាប្រចាំនោះគឺជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលញុំាងឲ្យប្រជាជននៅក្នុងខេត្តរបស់គាត់ចូលរួមជាមួយចលនាខ្មែរក្រហម ។ ការទម្លាក់គ្រាប់បែកបានបង្កឲ្យស្លាប់ជីវិតជនស៊ីវិលច្រើនសន្ធឹកសន្ធាប់ បើទោះជាការទម្លាក់គ្រាប់បែកនោះសំដៅទៅលើមូលដ្ឋានយោធាក៏ដោយ ។ ឡុង ពៅ ដែលមានវ័យ៦១ឆ្នាំរស់នៅក្នុងឃុំកំពង់អម្ពិលដែរ បាននិយាយរំឭកឡើងវិញថា គ្រាប់បែកមួយគ្រាប់បានធ្លាក់ចំវត្តមួយកន្លែងបណ្តាលឲ្យអ្នកភូមិនិងព្រះសង្ឃស្លាប់និងសុគតយ៉ាងច្រើន ។

ក្រៅពីកំហឹងរបស់ប្រជាជនចំពោះការទម្លាក់គ្រាប់បែក ឡូន បានអះអាងថា ខ្មែរក្រហមបានរើសទ័ពដោយបង្ខំនៅក្នុងខេត្តស្វាយរៀង ។ ជាការឆ្លើយតបទៅនឹងការចចេសរឹងរូសរបស់យុវជនចំពោះការកែនទ័ព ខ្មែរក្រហមបានឃោសនាថា «គ្មាននរណាម្នាក់អាចរារាំងកង់ប្រវត្តិសាស្ត្របានទេ» ។ ដោយលើកយកឧទាហរណ៍អំពីការរើសទ័ពដោយបង្ខំ ចំរើន បាននិយាយអំពីរបៀបដែលខ្មែរក្រហមផ្សឹកព្រះសង្ឃប្រមាណជាហុកសិបអង្គនៅក្នុងភូមិកំណើតរបស់គាត់ ។ ខ្មែរក្រហមបានណែនាំព្រះសង្ឃឲ្យលាចាកសិក្ខាបទ ដោយនិយាយកែច្នៃសកម្មភាពរបស់ខ្លួនតាមរយៈការគូសបញ្ជាក់អំពីសារសំខាន់ក្នុងការរួមកម្លាំងគ្នាប្រយុទ្ធប្រឆាំងនឹងរបបលន់នល់ ។ ខ្មែរក្រហមបានចាត់វិធានការដ៏តឹងរ៉ឹងប្រឆាំងនឹងអ្នកទាំងឡាយណាដែលមិនគោរពការណែនាំ ។ អ៊ិន សារី ដែលមានវ័យ៥៦ឆ្នាំ រស់នៅក្នុងឃុំកំពង់អម្ពិលក៏បានរំឭកឡើងវិញថា «...នៅក្នុងឆ្នាំ១៩៧២ ខ្ញុំជាសង្ឃមួយអង្គនៅវត្តអង្គក្រូច ។ នៅពេលខ្មែរក្រហមអនុវត្តការកែនទ័ពដោយបង្ខំនោះ ខ្ញុំក៏ត្រូវបានបង្ខំឲ្យចាកចេញពីអារាមដែរ ហើយឲ្យទៅចូលរួមធ្វើការងារយោធាដែរ រួមមានការសែងអ្នករបួសពីសមរភូមិនិងសែងគ្រាប់... នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំស្ថិតក្នុងចំណោមទាហានក្មេងៗមានវ័យ១៥ឆ្នាំ ដែលត្រូវបានបញ្ជូនឲ្យទៅប្រយុទ្ធនៅសមរភូមិស្វាយចេក» ។

ខ្មែរក្រហមបានកេណ្ឌមនុស្សជាច្រើនឲ្យចូលបម្រើកងទ័ព ។ សាន បានមើលឃើញនៅចុងឆ្នាំ១៩៧៥ ថាមានការកើនឡើងខ្លាំងនូវចំនួនកងទ័ពខ្មែរក្រហម ។ មនុស្សជាច្រើនបានព្យាករណ៍ទុកអំពីជោគជ័យរបស់ខ្មែរក្រហមទៅលើទាហានលន់នល់ ដែលមូលដ្ឋានរបស់លន់នល់ស្ថិតតែនៅក្នុងទីរួមខេត្តស្វាយរៀងដ៏តូចមួយប៉ុណ្ណោះ ។

## ពីអ្នកចម្បាំងទៅជាជនក្បត់ជាតិ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រាំឆ្នាំនៃសង្រ្គាម


ការបំពេញពាក្យបណ្តឹងនៅខេត្តស្វាយរៀង

ស៊ីវិលនិងការទម្លាក់គ្រាប់បែកដ៏រាំរ៉ៃបានបញ្ចប់ទៅដោយជ័យជម្នះដ៏ខ្ទរខ្ទាររបស់ចលនាខ្មែរក្រហមទៅលើរដ្ឋាភិបាលលន់នល់ដែលស្គាល់ថា ជារបបសាធារណរដ្ឋខ្មែរ ។ នៅក្នុងទីក្រុងភ្នំពេញ អ្នកទីក្រុងខ្លះបានឈរអមតាមផ្លូវដើម្បីអបអរសាទរការមកដល់របស់ក្រុមទាហានឯកសណ្ឋានពណ៌ខ្មៅ ។ ម្យ៉ាងទៀត អ្នកផ្សេងៗទៀតចាប់ផ្តើមភ័យខ្លាចថា ការចាប់ខ្លួនឬការសម្លាប់នឹងកើតមាននាពេលដ៏ខ្លីខាងមុខ ។ ក្នុងរយៈពេលតែមួយសប្តាហ៍ប៉ុណ្ណោះ ខ្មែរក្រហមបានធ្វើឲ្យទីក្រុងនិងទីប្រជុំជននានានៅក្នុងប្រទេសកម្ពុជាគ្មានមនុស្សនៅ ដោយរាប់បញ្ចូលទាំងទីក្រុងភ្នំពេញផង ។ ការជម្លៀសដោយបង្ខំនេះបានបង្កឲ្យមនុស្សជាច្រើនស្លាប់តាមផ្លូវ ។

ខណៈពេលដែលការជម្លៀសត្រូវបានអនុវត្តទូទាំងប្រទេសកម្ពុជា ចំរើន បាននិយាយអំពីសភាពការណ៍កាន់តែដុនដាបទៅៗនៅក្នុងខេត្តស្វាយរៀង ។ ចំរើន បាននិយាយថា ស្ថានភាពធ្វើការងារជាទម្លាប់មុនឆ្នាំ១៩៧៥ បានផ្លាស់ប្តូរឲ្យទៅជាការងារសហករណ៍ជាមួយនឹងការហូបរួមគ្នា ។ អ្នកធ្វើការងារត្រូវជីកប្រឡាយ លើកដីនិងលើកទំនប់ ។ ចំណែក សារី វិញ ត្រូវបានដំឡើងឋានៈជាឈ្លបឃុំ ។ ការទទួលខុសត្រូវរបស់គាត់រួមមានការកត់ត្រានិងរាយការណ៍រាល់បញ្ហានានាទៅឲ្យប្រធានឃុំ ។ សារី បានបន្តថា «ខ្ញុំដើរត្រួតពិនិត្យមើលតាមសហករណ៍នីមួយៗ ។ នៅពេលប្រជាជនមិនគោរពតាមអង្គការវិន័យ មិនមកធ្វើការងារ ឬធ្វើពុតជាឈឺ ខ្ញុំនាំអ្នកទាំងនោះទៅអប់រំកសាង» ។

ខ្មែរក្រហមចាត់ទុកបញ្ហាខុសសីលធម៌ស្ថិតក្នុងលំដាប់ខក្រិដ្ឋធ្ងន់ធ្ងរបំផុត ដែលនឹងនាំឲ្យមានការដាក់ទោសប្រហារជីវិតចំពោះអ្នកដែលត្រូវបានរកឃើញ ។ សារី បញ្ជាក់ថា ក្រមសីលធម៌ទី៦បានចែងថា ទំនាក់ទំនងផ្លូវភេទរវាងបុរសនិងស្ត្រីត្រូវដាក់ទោសរហូតដល់ស្លាប់ ។ ស្រដៀងគ្នានេះដែរ សុខ ផន ដែលមានវ័យ៥៩ឆ្នាំ រស់នៅក្នុងឃុំកំពង់អម្ពិល បានប្រាប់យើងថា នៅក្នុងសហករណ៍របស់គាត់ បុរសនិងនារីត្រូវបានដាក់នៅដាច់ដោយឡែកពីគ្នា ។ មានការហាមប្រាមយ៉ាងដាច់ខាត ចំពោះការស្រឡាញ់គ្នា ។ ផន បានឃើញផ្ទាល់ភ្នែកនូវការកាប់សម្លាប់មនុស្សពីរនាក់ដែលត្រូវចោទប្រកាន់ពីបទប្រព្រឹត្តខុសសីលធម៌ ។ អ្នកទាំងពីរត្រូវបង្ខំឲ្យបិទជិតនិងសម្លាប់ចោល ។ មានតែវិធីមួយគត់ដែលអាចធានាដល់ការរៀបអាពាហ៍ពិពាហ៍គឺប្រជាជនអាចរៀបការបានដោយសុវត្ថិភាពដោយមានការយល់ព្រមពីអង្គការ ។ តែទោះជាយ៉ាងណាក៏ដោយ សារី បានប្រាប់យើងពីឧទាហរណ៍នៃការរៀបការដោយមានការព្រមព្រៀងរវាង សាវ៉ន ប្រធានកងនារី «គ» និង អ៊ំ ប្រធានកងបុរស «គ» ។

ទោះបីដឹងថា អង្គការនឹងដាក់ទោសយ៉ាងធ្ងន់ធ្ងរដល់អ្នកទាំងឡាយណាដែលរកឃើញថាបានរំលោភលើបទបញ្ជា សារី បានប្រថុយជីវិតរបស់ខ្លួនដោះលែងមនុស្សយ៉ាងហោចណាស់ក៏ដប់នាក់ដែរ ដែលជាប់ចោទពីបទលួចផលដំណាំខាងមុខផ្ទះដើម្បីហូប ។ ប្រធានឃុំបានបន្ទោសគាត់ពីបទមិននាំយក «ចោរ» ទាំងអស់នោះទៅអប់រំកសាង ។ ប្រធានឃុំបានព្រមាន សារី ថា កុំឲ្យរឿងបែបនេះកើតឡើងម្តងទៀត ។

ទោះជាយ៉ាងណាក៏ដោយ នៅចុងឆ្នាំ១៩៧៧ សភាពការណ៍នៅខាងភូមិភាគបូព៌ាកាន់តែអាក្រក់ឡើង ខណៈពេលដែលការប៉ះទង្គិចប្រដាប់អាវុធរវាងខ្មែរក្រហមនិងកងទ័ពវៀតណាមកាន់តែខ្លាំងក្លាឡើង ។ ឡុន បានរំឭកឡើងវិញថា ទាហានខ្មែរក្រហម


បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងណែនាំក្នុងការបំពេញពាក្យបណ្តឹង ខេត្តស្វាយរៀង

ដកថយក្រោយ កងទ័ពវៀតណាម បានចូលបោះជំរំនៅក្នុងឃុំរបស់គាត់ ។ បន្ថែមពីនេះទៀត ដោយមានការចាប់ខ្លួនជនក្បត់ជាតិតាមការចោទប្រកាន់ ឈ្មោះ សោភឹម ប្រធានភូមិភាគបូព៌ា ប្រជាជនជាច្រើនបានភៀសខ្លួនទៅជ្រកកោននៅប្រទេសវៀតណាម ។ ហេតុផលទាំងនេះហើយ ទើបប្រជាជននៅខាងភូមិភាគបូព៌ាត្រូវបានហៅថា «ក្បាលយួនខ្លួនខ្មែរ» ។ ចាប់ពីពេលនោះមក អង្គការលែងទុកចិត្តកម្មាភិបាលទាំងអស់នៅខាងភូមិភាគបូព៌ា ។ ទាំង ចំរើន និង ឡូន បានអះអាងថាខ្មែរក្រហមបានចាប់ខ្លួនកម្មាភិបាលទាំងអស់ដែលបម្រើការជាប្រធានភូមិ ឃុំ ស្រុក ខេត្ត និងជំនួសវិញដោយកម្មាភិបាលមកពីភូមិភាគនិរតី ។

ទោះជាការចម្រាញ់ដំបូងសំដៅតែទៅលើកម្មាភិបាលនៅខាងភូមិភាគបូព៌ា ក៏ប្រជាជននៅទីនោះមិនអាចរួចផុតពីការធ្វើទុកបុកម្នេញដែរ ។ អ្នកផ្តល់សម្ភាសន៍ភាគច្រើនបានប្រាប់ថាប្រជាជននៅខាងភូមិបូព៌ា (ខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តកំពង់ចាមមួយចំណែក) ជារៀយៗត្រូវបានបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់និងបាត់ដំបង ដើម្បីជាការរារាំងអ្នកទាំងនោះមិនឲ្យរត់




ទៅប្រទេសវៀតណាម ។ នៅពេលទៅដល់ទីនោះ ខ្មែរក្រហមបានដាក់លក្ខខណ្ឌការងារធ្ងន់ៗ ដោយសារអ្នកទាំងនោះត្រូវបានចាត់ទុកថាជាមនុស្ស «ក្បាលយួនខ្លួនខ្មែរ» ។ ឡូន រាយការណ៍ថា ឪពុករបស់គាត់ត្រូវបានសម្លាប់ជាមួយនឹងប្រាំគ្រួសារផ្សេងៗទៀតនៅពោធិ៍សាត់ ។ នៅពេលសួរថាតើគាត់អាចគេចរួចពីការសម្លាប់ដោយរបៀបណា? ឡូន បានឆ្លើយតបថា «ខ្ញុំក៏ស្ថិតនៅក្នុងបញ្ជីរង់ចាំតែការយកទៅសម្លាប់ប៉ុណ្ណោះ» ។

បើទោះជា ប៉ែន គុណ អាយុ៦៧ឆ្នាំ បានផ្លាស់ចេញពីខេត្តស្វាយរៀង ទៅកាន់ខេត្តបាត់ដំបងតាំងពីនៅតូចក៏ដោយ ក៏គាត់ប្រឈមមុខនឹងការធ្វើបាបស្រដៀងគ្នានេះដែរនៅក្នុងរបបនោះ ។ ដោយសារតែគាត់មានប្រវត្តិរូបនៅស្វាយរៀង ខ្មែរក្រហមបានសម្លាប់ប្តីគាត់ភ្លាមៗ ហើយ គុណ ត្រូវបានបញ្ជូនទៅកាន់ស្រុកមង្គលបូរី ។ ស្រដៀងគ្នានេះដែរ មាស យា ដែលមានវ័យ៧១ឆ្នាំរស់នៅក្នុងឃុំពងទឹក ក្រៀមក្រំចិត្តយ៉ាងខ្លាំងនៅពេលគាត់និយាយអំពីការស្លាប់របស់ឪពុកម្តាយនិងបងប្អូនបង្កើតប្រាំបួននាក់ផ្សេងៗទៀតនៅខាងភូមិភាគបូព៌ា ។ នៅពេលរបបនេះត្រូវបានបណ្តេញចេញពីអំណាចនៅក្នុងឆ្នាំ១៩៧៩ មាស គឺជាអ្នកនៅរស់រានជីវិតតែម្នាក់គត់នៅក្នុងគ្រួសាររបស់គាត់ ។

## ការវិលត្រឡប់មកស្រុកកំណើត

ក្រោយពីរបបវាលពិឃាតនេះដួលរលំទៅ ការចាប់ផ្តើមជីវិតថ្មី ផលវិបាកជាច្រើនបានបន្សល់ទុកឲ្យប្រជាជននិងរដ្ឋាភិបាលដោះស្រាយ ។ ការលំបាកទាំងនេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ បើពិនិត្យមើលមូលដ្ឋានសង្គម នយោបាយ សេដ្ឋកិច្ច សាសនា និងវប្បធម៌របស់ប្រទេសត្រូវបានបំផ្លាញ ហើយថាអ្នកចេះដឹងស្ទើរតែទាំងអស់បានក្លាយទៅជាមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញ និងសម្លាប់ ។ អ្នករស់រានមានជីវិតយល់ឃើញថា ខ្លួនស្ថិតនៅក្នុងបរិយាកាសមួយដែលមិនច្បាស់លាស់ ច្របូកច្របល់ អសុវត្ថិភាព និងមានការប៉ះពាល់ខាងផ្លូវចិត្ត ។ ប្រជាជនបានវិលត្រឡប់ទៅកាន់ភូមិកំណើតវិញ ហាក់ដូចជាវិលទៅភាពជាជនរងគ្រោះនៃគ្រាប់មីនម្តងទៀតអីចឹង ។ យោងទៅតាមសម្តី ឡូន ភាពអត់ឃ្លានបានបង្ខំឲ្យប្រជាជន ប្រថុយជីវិតដើរកាត់តំបន់មានមីនដើម្បីស្វែងរកអាហារ ។ ឡូន បញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៩ ប្រជាជនប្រហែល

ជា៥០នាក់ នៅក្នុងឃុំកំពង់អម្ពិល បានដើរជាន់មីន ហើយដេកដួលហូរឈាមរហូតដល់ស្លាប់ដោយសារតែកង្វះខាតប្រព័ន្ធសុខាភិបាលត្រឹមត្រូវ ។

## សារសំខាន់ក្នុងការរៀនអំពីអតីតកាល

បន្ទាប់ពីបានទទួលរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរអស់រយៈពេលជិតបួនឆ្នាំនៅក្រោមរបបខ្មែរក្រហម ជនរងគ្រោះជាច្រើនមិនអាចបំភ្លេចរយៈកាលនេះបានទេ ។ ជារឿយៗ ជនរងគ្រោះតែងតែពាំនាំរឿងរ៉ាវរបស់ខ្លួនទៅប្រាប់កូនៗ តាមរយៈការពិភាក្សាអំពីសម័យកាលនោះ ។ ដំណើរការនៃការនិយាយរឿងរ៉ាវនេះបង្ហាញឲ្យឃើញអំពីមធ្យោបាយដ៏ល្អមួយដែលអ្នករស់រានមានជីវិតអាចព្យាបាលរបួសពីអតីតកាល ។ ទោះជាយ៉ាងណាក៏ដោយ អ្នករស់រានមានជីវិតភាគច្រើនបំផុតបានរអ៊ូថា ក្មេងៗជំនាន់ក្រោយបានបង្ខំចិត្តជឿរឿងរ៉ាវអំពីរបបខ្មែរក្រហម ។ យុវជនខ្លះវិញបែរជាសើចពេលឮរឿងទាំងនោះដោយឆ្លើយតបថា រឿងទាំងនោះជារឿងប្រឌិត ។

តាមទស្សនៈរបស់ ជន វិញ វាជាការសំខាន់ខ្លាំងណាស់ដែលក្មេងជំនាន់ក្រោយបានឮរឿងរ៉ាវទាំងនេះ ពីមនុស្សចាស់ដោយសាររឿងទាំងនេះបានប្រាប់ក្មេងៗពីអំពើឃោរឃៅដែលពួកខ្មែរក្រហមបានប្រព្រឹត្ត ។ ប្រសិនបើអ្នករស់រានមានជីវិតទាំងអស់ប្រាប់រឿងរ៉ាវរបស់ខ្លួនទៅកាន់ក្មេងជំនាន់ក្រោយ អ្នកទាំងនោះនឹងចាប់ផ្ដើមជឿរឿងទាំងអស់នោះជាក់ជាពុំខាន ។ ជាមួយនឹងស្នាមញញឹម ឡុន បាន ប្រាប់ក្រុមបញ្ចាំងកុនរបស់យើងថា «ខ្ញុំចង់ឮចម្លើយមកពីជនជាប់ចោទទាំងប្រាំនាក់ ។ តើអ្នកទាំងនេះនិយាយថា អត់ដឹងពីការសម្លាប់ក្នុងជំនាន់របបកម្ពុជាប្រជាធិប-តេយ្យយ៉ាងម៉េចកើត? ខ្ញុំមិនជឿការបដិសេធរបស់អ្នកទាំងនោះទេ ។ ក្នុងសម័យនោះ ខ្ញុំបាត់សាច់ញាតិប្រហែលមួយរយនាក់ដោយរាប់ទាំងឪពុកម្ដាយខ្ញុំដែរ» ។

ខណៈពេលដែល កាត់ យ៉ា ដែលមានវ័យ៦៦ឆ្នាំរស់នៅឃុំអណ្ដូងក្រសាំង មិនបានឮអំពីការកាត់ទោសនាពេលខាងមុខ ឡុន បានប្រាប់យើងទៀតថា គាត់បានតាមដានការផ្សព្វផ្សាយព័ត៌មានស្ដីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ និយាយអំពីការកាត់ទោសនេះ សាន បានសម្ដែងពីឆន្ទៈក្នុងការរង់ចាំយុត្តិធម៌ ។ ដោយមានភាពរីករាយស្រដៀងគ្នានេះដែរ កសិករម្នាក់អាយុ៦១ឆ្នាំនៅក្នុងខេត្តស្វាយរៀងបានសម្ដែងការសប្បាយចិត្តនៅពេលស្ដាប់ឮអំពីដំណើរការវិវត្តន៍ថ្មីៗនៅឯអង្គជំនុំជម្រះ ។ ដោយសារតែបាត់បងប្អូនបង្កើត៦នាក់នៅក្នុងរបបនោះ កសិកររូបនេះ បានស្នើសុំឲ្យក្រុមបញ្ចាំងកុនជួយបំពេញនិងបញ្ជូនទម្រង់ព័ត៌មានជនរងគ្រោះឲ្យទៅអង្គភាពជនរងគ្រោះរបស់អង្គជំនុំជម្រះ ដើម្បីជូនដំណឹងដល់សហព្រះរាជអាជ្ញាអំពីបទឧក្រិដ្ឋដែលគាត់បានឃើញផ្ទាល់ភ្នែកនិងការឈឺចាប់របស់គាត់ ។ កសិកររូបនេះជាអ្នកដែលស្ថិតនៅក្នុងចំណោមអ្នកដាក់ពាក្យបណ្ដឹងចំនួន១៦នាក់នៅក្នុងខេត្តស្វាយរៀង ។ នេះបញ្ជាក់ច្បាស់ថា កសិកររូបនេះនិងអ្នកផ្សេងៗទៀតចង់ចូលរួមនៅក្នុងដំណើរការសាលាក្ដី ។ ដោយរំពឹកឲ្យយើងនឹកឃើញថា «យុត្តិធម៌ដែលពន្យារពេលមានន័យស្មើនឹងយុត្តិធម៌ដែលត្រូវបានបដិសេធ» កសិកររូបនេះបានអំពាវនាវឲ្យតុលាការឆាប់រកយុត្តិធម៌ជាបន្ទាន់ ។

## សេចក្ដីសន្និដ្ឋាន

ប្រជាជនជាច្រើននៅក្នុងឃុំទាំងពីរដែលក្រុមបញ្ចាំងភាពយន្តរបស់យើងបានទៅដល់ បានសម្ដែងអំណរគុណចំពោះការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ ។ ក្រៅពីការនិយាយរឿងប្រាប់មិនផ្លូវការរបស់អ្នករស់រានមានជីវិត ការបញ្ចាំងខ្សែភាពយន្តឯកសារជាមធ្យោបាយដ៏មានសារសំខាន់ដែលអាចអប់រំប្រជាជន ដោយរាប់បញ្ចូលទាំងអ្នកដែលកើតក្រោយឆ្នាំ១៩៧៩ ឲ្យដឹងពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមពីនេះទៀត ក្រុមបញ្ចាំងខ្សែភាពយន្តបានជួយអ្នករស់រានមានជីវិតចំនួន១៦នាក់ឲ្យបំពេញនិងដាក់ពាក្យបណ្ដឹងទៅកាន់អង្គភាពជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ អ្នករស់រានមានជីវិតទាំងនេះបានសម្ដែងនូវការសប្បាយរីករាយដែលអាចមានលទ្ធភាពចូលរួមនៅក្នុងដំណើរការតុលាការ ។ ខណៈដែលការចូលរួមនៅក្នុងដំណើរការតុលាការមានសារសំខាន់នៃការនិយាយរឿងរ៉ាវមិនផ្លូវការប្រាប់ទៅដល់ក្មេងៗជំនាន់ក្រោយស្ដែងឲ្យឃើញថាជាវិធីមួយដ៏មានសារសំខាន់បំផុតដែលអ្នករស់រានមានជីវិតអាចបង្កើនការយល់ដឹងខាងផ្នែកប្រវត្តិសាស្ត្រនិងទទួលបាននូវការសះស្បើយ ។

**លី សុខឃាង**

# កម្មវិធីសម្រាប់ការអប់រំនិស្សិត

នៅថ្ងៃទី១៧មេសា មជ្ឈមណ្ឌលឯកសារកម្ពុជាអញ្ជើញយុវជន-យុវនារីចាមមូស្លីមចំនួន៥០០នាក់ ចូលរួមទស្សនកិច្ចសិក្សា «គម្រោងផ្សព្វផ្សាយអប់រំសិស្សនិស្សិត» ដែលជាផ្នែកមួយនៃសកម្មភាពផ្សព្វផ្សាយរបស់គម្រោងនេះ ។ នៅក្នុងដំណើរទស្សនកិច្ចនេះ បុគ្គលិករបស់មជ្ឈមណ្ឌលនឹងនាំនិស្សិតទៅកាន់វិទ្យាស្ថានអប់រំជាតិ ទស្សនាមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក មជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ដំណើរទស្សនកិច្ចនេះគឺជាផ្នែកមួយនៃគម្រោងផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីអប់រំជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្មេងជំនាន់ក្រោយ និស្សិតនិងសមាជិកក្រុមសាសនានិងប្រជាពលរដ្ឋកម្ពុជា ។ ទស្សកិច្ចនេះមានគោលបំណងផ្ដល់នូវព័ត៌មានដល់សិស្សនិស្សិតស្ដីអំពីអង្គជំនុំជម្រះវិសាមញ្ញនិងការវិវត្តរបស់តុលាការនិងផ្ដល់ឱកាសជាឲ្យយុវជនជំនាន់ក្រោយចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។

ដំណើរទស្សនកិច្ចនឹងចាប់ផ្ដើមឡើងនៅ(វិទ្យាស្ថានអប់រំជាតិវិទ្យាស្ថានគរុកោសល្យ) ដែលនៅទីនោះ និស្សិតនឹងបានស្ដាប់នូវសេចក្ដីណែនាំដោយសង្ខេបអំពីតុលាការដោយនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់សេចក្ដីណែនាំនេះនឹងមានការពិភាក្សាមួយដែលដឹកនាំដោយសាស្ត្រាចារ្យប្រវត្តិសាស្ត្រ សំបូ ម៉ាណ្ណារ៉ា ស្ដីអំពីការយល់ឃើញខុសៗគ្នាជុំវិញថ្ងៃ១៧មេសា ទំនាក់ទំនងទៅនឹងព្រឹត្តិការណ៍ទំនាស់ជុំវិញថ្ងៃទី១៧មេសា ដែលជាថ្ងៃប្រវត្តិសាស្ត្រ ។ បន្ទាប់មកទៀតនិស្សិតនឹងធ្វើដំណើរទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ។ នៅទីនោះ លោក រាជ សម្បត្តិ មន្ត្រីអ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមពានិងនិស្សិតដែលមកកម្មសិក្សានៅតុលាការនឹងទទួលស្វាគមន៍និស្សិតទាំងអស់ជាមួយនឹងការណែនាំឲ្យដើរទស្សនាទៅកាន់អគារតុលាការ ។

ជំហានបន្ទាប់និស្សិតនឹងធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលប្រល័យពូជសាសន៍វាលពិឃាតជើងឯក ជាកន្លែងដែលនឹងមានការប្រារព្ធពិធីបង្សុកូលមួយឧទ្ទិសដល់អ្នកស្លាប់ និងបន្ទាប់មកធ្វើដំណើរទៅកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដើម្បីចូលរួមបើកការតាំងពិព័រណ៍ថ្មីរបស់មជ្ឈមណ្ឌលកម្ពុជាដែលមានឈ្មោះថា «ការឆ្លុះបញ្ចាំងពីរបបកម្ពុជាប្រជាធិបតេយ្យនិងក្រោយមកទៀត» ។ ពិព័រណ៍ថ្មីដែលមានរៀបចំនៅក្នុងអគារចំនួនបីរបស់សារមន្ទីរទួលស្លែង មានគោលបំណងនាំភ្ញៀវទេសចរណ៍ទស្សនាសារមន្ទីរទៅមើលទិដ្ឋភាពប្រវត្តិសាស្ត្រពិតមួយ ដោយដំណើរចាប់ផ្ដើមនៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ និងបញ្ចប់ជាមួយនឹងដំណើរការនៃតុលាការដែលកំពុងកើតមានសព្វថ្ងៃនេះ ។ ពិព័រណ៍នេះមានដាក់តាំងរូបថតជាច្រើនដែលជាសមិទ្ធផលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពិព័រណ៍នេះរៀបចំឡើងក្នុងគោលបំណងឆ្លុះបញ្ចាំងពីចម្ងល់ផ្សេងៗនិងផ្ដល់ព័ត៌មានពិស្ដារស្ដីអំពីរបបកម្ពុជាប្រជាធិបតេយ្យ រឿងរ៉ាវរបស់បុគ្គលម្នាក់ៗនិងជុំវិញបញ្ហាយុត្តិធម៌និងការផ្សះផ្សា ។ បុគ្គលិកពីរនាក់របស់សារមន្ទីរទួលស្លែងនឹងត្រូវចាត់តាំងឲ្យនៅតាមអគារនីមួយៗដើម្បីធ្វើការណែនាំនិស្សិតទាំងអស់អំពីគុកទួលស្លែង ។

គោលបំណងរបស់ដំណើរទស្សនកិច្ចគឺដើម្បីពង្រីកការយល់ដឹងនិងទស្សនវិស័យអំពីសារសំខាន់ជាប្រវត្តិសាស្ត្រនិងសង្គមសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងផលប៉ះពាល់របស់ព្រឹត្តិការណ៍នោះ ។ គោលបំណងនៃព្រឹត្តិការណ៍និងទីតាំងជាក់លាក់ទាំងនេះគឺដើម្បីអប់រំនិងផ្ដល់នូវការយល់ឃើញខុសៗគ្នាទៅលើរឿងរ៉ាវនិងបញ្ហាផ្សេងៗអំពីការប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ។ និស្សិតទាំងអស់នឹងត្រូវបានណែនាំនិងផ្ដល់នូវឱកាសដើម្បីចូលរួមការពិភាក្សាស៊ីជម្រៅអំពីប្រវត្តិសាស្ត្រកម្ពុជា ។ តាមរយៈការជួបសំណេះសំណាលជាមួយអ្នកបម្រើការនៅតុលាការដែលមានអាយុស្របាលគ្នា និស្សិតនឹងអាចយល់ដឹងអំពីតុលាការតាមទស្សនវិស័យមួយ និស្សិតទាំងអស់យល់ថាមានសារសំខាន់និងមានទំនាក់ទំនងចំពោះខ្លួន ។ មជ្ឈមណ្ឌលសង្ឃឹមថានៅថ្ងៃទី១៧ មេសា គឺជាការឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅមួយនិងបទពិសោធន៍នៃការអប់រំសម្រាប់និស្សិតទាំងអស់ ។ **សើ សាយ្យាណា**



# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

***(តពីលេខមុន)***

*នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ប្រជាជនកម្ពុជាចំនួន២៣ គ្រួសារបានបំពេញពាក្យបណ្តឹងនៅក្នុងតុលាការ ប៉ែលហ្ស៊ិកប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម នួន ជា, ខៀវ សំផន និងអៀង សារី ដោយចោទប្រកាន់ពីបទប្រព្រឹត្តខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ដើមបណ្តឹងត្រូវបានលើកទឹកចិត្តឲ្យធ្វើការចោទប្រកាន់ បន្ទាប់ពីជនរងគ្រោះនៅក្រោមអំណាចផ្តាច់ការរបស់ ពីណូដេ បានទទួលជោគជ័យក្នុងការចេញដីកាចាប់ខ្លួនជាអន្តរជាតិចំពោះអតីតអ្នកកាន់លទ្ធិផ្តាច់ការរូបនេះ ។*

*នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចិនបានសម្តែងការប្រឆាំងនឹងការបង្កើតតុលាការអន្តរជាតិមួយសម្រាប់អតីតមេដឹកនាំខ្មែរក្រហម ដោយនិយាយថា វាគឺជាកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ។ ថាង ជាស៊ាន់ (Tang Jia Xuan)មន្ត្រីក្រសួងការបរទេសនៃប្រទេសចិនបានថ្លែងថា ការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការអន្តរជាតិដែលជាការរៀបចំដោយអង្គការសហប្រជាជាតិគឺជាគំនិតរបស់ប្រទេសលោកខាងលិច ជាពិសេសប្រទេសអាមេរិក ។*

*នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ អៀង ធីរិទ្ធ ដែលជាប្រពន្ធរបស់អៀង សារី និងជារដ្ឋមន្ត្រីនៃក្រសួងអប់រំនិងសង្គមកិច្ចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យបានសរសេរលិខិតមួយឆ្លើយតបនឹងអត្ថបទនៅក្នុងខេមបូឌាដេលី កាលពីថ្ងៃទី៥ ខែកុម្ភៈ ដែលមានចំណងជើងថា «អៀង សារី ព្រមានមិនឲ្យមានការរំដើបរំជួលពាក់ព័ន្ធនឹងអង្គជំនុំជម្រះ» ។ អត្ថបទនេះសរសេរថា អៀង ធីរិទ្ធ គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិក៤នាក់នៃគណៈកម្មាធិការមជ្ឈិមខ្មែរក្រហមដែលរស់នៅតំបន់ប៉ៃលិន ។*

*នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានបញ្ចូលអ្នកដែលនៅសល់ពីរបបខ្មែរក្រហមទៅជាកងយោធពលខេមរភូមិន្ទ ។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ របាយការណ៍របស់ក្រុមអ្នកជំនាញការកម្ពុជាអនុលោមទៅតាមការសម្រេចរបស់មហាសន្និបាតលេខ៥២/១៣៥ត្រូវបានចេញផ្សាយ ។ របាយការណ៍នេះបានស្នើសុំឲ្យមានការបង្កើតតុលាការអន្តរជាតិនិងគណៈកម្មការស្វែងរកការពិតដើម្បីដោះស្រាយឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ឈិត ជឿន ដែលហៅថា ម៉ុក ឬតាម៉ុក ត្រូវបានចាប់ខ្លួនដោយកងកម្លាំងកម្ពុជាក្រោមច្បាប់កម្ពុជាឆ្នាំ១៩៩៤ប្រឆាំងនឹងខ្មែរក្រហម ។*

*នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ របាយការណ៍របស់ក្រុមអ្នកជំនាញកម្ពុជាអនុលោមទៅតាមការសម្រេចរបស់មហាសន្និបាតលេខ៥២/១៣៥ ត្រូវបានបញ្ជូនទៅកាន់ក្រុមប្រឹក្សាសន្តិសុខនិងអង្គមហាសន្និបាត ។ នៅក្នុងរបាយការណ៍នោះ ក្រុមអ្នកជំនាញបានស្នើសុំឲ្យមានការបង្កើតតុលាការអន្តរជាតិដើម្បីកាត់ទោសខ្មែរក្រហមជាផ្លូវការចំពោះឧក្រិដ្ឋប្រឆាំងមនុស្សជាតិនិងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ពីថ្ងៃ១៧មេសា១៩៧៥ដល់ថ្ងៃ៧មករា ១៩៧៩ ។*

*នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៩ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានគុកទួលស្លែងខ្មែរក្រហម ។ ឌុច និយាយថា នួន ជា បានបញ្ជាឲ្យគាត់សម្លាប់ជនបរទេសនៅទួលស្លែងដោយ «ដុតជាមួយកង់ឡានដើម្បីកុំឲ្យនៅសល់ឆ្អឹង» ។*

*នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៩ នៅក្នុងកិច្ចពិភាក្សាជាមួយអ្នកតំណាងអចិន្ត្រៃយ៍របស់កម្ពុជា ការិយាល័យកិច្ចការច្បាប់បង្ហាញសំណើជូនអង្គការសហប្រជាជាតិដើម្បីឲ្យបង្កើតតុលាការចម្រុះសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ (កំណត់សម្គាល់បង្ហាញពីមូលដ្ឋានគ្រឹះរបស់តុលាការចម្រុះត្រូវបានផ្សព្វផ្សាយ ។)*

*នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩ សភាជាតិរបស់កម្ពុជាយល់ស្របនឹងច្បាប់ថ្មីចំពោះការឃុំខ្លួននៅសវនាការដំបូងពី៦ខែ*

ទៅ៣ឆ្នាំចំពោះអ្នកដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៩ មន្ត្រីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានរិះគន់ពីច្បាប់ដែលបានយល់ស្របដោយសភាជាតិកម្ពុជាដែលអនុញ្ញាតឲ្យមានការឃុំខ្លួនរយៈពេល៣ឆ្នាំនៅសវនាការដំបូងចំពោះជនសង្ស័យដែលត្រូវចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ រ៉ូសម៉ារី ម៉ាក់ក្រីរី ប្រធានការិយាល័យរបស់អភិបាលអង្គការសហប្រជាជាតិជាន់ខ្ពស់សិទ្ធិមនុស្សប្រចាំនៅកម្ពុជាបានថ្លែងថា ការឃុំខ្លួនរយៈពេល៣ឆ្នាំជាការបំពានដល់បទដ្ឋានយុត្តិធម៌អន្តរជាតិ ។

រដ្ឋាភិបាលកម្ពុជាថ្លែងថា ចង់រក្សាការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិចំពោះតុលាការដែលមានលក្ខណៈជាអន្តរជាតិ ។ ឧបនាយករដ្ឋមន្ត្រី សុខ អាន និយាយថា ការកាត់ទោសនឹងបង្កើតឡើងនៅក្នុងតុលាការកម្ពុជា ប៉ុន្តែគាត់ក៏អនុញ្ញាតឲ្យមានការចូលរួមពីចៅក្រមបរទេសនិងអ្នកជំនាញច្បាប់ដែរ ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ រដ្ឋាភិបាលបានបង្កើត «ក្រុមការងារជំនាញសម្រាប់កិច្ចសហប្រតិបត្តិការច្បាប់បរទេសនិងរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម» ដែលមានឧបនាយករដ្ឋមន្ត្រី សុខ អាន ជាប្រធាន ។

ក្រុមការងារបានចាប់ផ្តើមការងាររបស់ខ្លួនដោយការធ្វើសេចក្តីព្រាងច្បាប់ ។ សេចក្តីព្រាងច្បាប់ដំបូងត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ១៩៩៩ ហើយបានប្រគល់ឲ្យគណៈប្រតិភូអង្គការសហប្រជាជាតិដែលដឹកនាំដោយលោក រ៉ាហ្វ ហ្សាក់គ្លីន (Ralph Zacklin) តំណាងលេខាធិការ ហែន កូរែល (Hans Corell) ដែលទទួលបន្ទុកកិច្ចការច្បាប់នៅអង្គការសហប្រជាជាតិ ។ សេចក្តីព្រាងច្បាប់កម្ពុជាទទួលបានវិភាគទានខាងបច្ចេកទេសនិងអ្នកជំនាញការច្បាប់មកពី បារាំង ឥណ្ឌា រុស្ស៊ី អូស្ត្រាលី ព្រមទាំងមានសហរដ្ឋអាមេរិកដែលចេញមកពីអង្គការសហប្រជាជាតិ ។

នៅខែសីហា ឆ្នាំ១៩៩៩ គណៈប្រតិភូដំបូងរបស់អង្គការសហប្រជាជាតិបានសិក្សាពីច្បាប់ព្រាងដំបូង និងច្បាប់ព្រាងរបស់ខ្លួន ។ នៅពេលនោះពុំទាន់មានការយល់ស្របគ្នាទេ ។ ចំណុចខុសគ្នាភាគច្រើនគឺថា ហ្សាគ្លីន ចង់ឲ្យចៅក្រមបរទេសមានសិទ្ធិអំណាចធំ ខណៈពេលដែលកម្ពុជាក៏ចង់ឲ្យចៅក្រមខ្លួនមានសិទ្ធិអំណាចធំដែរ ។

នៅថ្ងៃទី២៥ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ បេសកកម្មដំបូងរបស់អង្គការសហប្រជាជាតិនៅកម្ពុជា គឺស្នើសុំឲ្យមានការដឹកនាំកិច្ចចរចាអំពីច្បាប់និងការអនុវត្តដើម្បីបង្កើតជាតុលាការចម្រុះនៅក្រោមច្បាប់កម្ពុជាដោយមានបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ ការអត្ថាធិប្បាយអំពីសេចក្តីព្រាងច្បាប់កម្ពុជាត្រូវបានដាក់ស្នើ ។

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ អង្គការសហប្រជាជាតិនិងមន្ត្រីកម្ពុជាបានបញ្ចប់កិច្ចចរចាក្នុងរយៈពេលមួយសប្តាហ៍ដោយមិនមានការព្រមព្រៀងគ្នាអំពីរបៀបនៃការបង្កើតតុលាការប្រល័យពូជសាសន៍ ។ ជំនួយការលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ លោក រ៉ាហ្វ ហ្សាគ្លីន (Ralph Zacklin) និយាយថា ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាមិនឆ្ពោះទៅដល់លក្ខខណ្ឌដែលអង្គការសហប្រជាជាតិយល់ថាមានសារសំខាន់ចំពោះតុលាការទេ «អង្គការសហប្រជាជាតិនឹងបញ្ឈប់ដំណើរការនេះ» ។ គណៈប្រតិភូអង្គការសហប្រជាជាតិបានសង្ខេបសារដែលមានសារសំខាន់ៈ

...ប្រសិនបើការកាត់ទោសមេដឹកនាំខ្មែរក្រហមឈានទៅដល់បទដ្ឋានអន្តរជាតិដែលមានយុត្តិធម៌ ភាពមិនលម្អៀង និងដំណើរការច្បាប់សមរម្យ ព្រមទាំងបង្កើនការគាំទ្រនិងយល់ស្របពីសហគមន៍អន្តរជាតិ នោះវាសំខាន់ណាស់ថា សមាសភាពអន្តរជាតិនៃតុលាការមានលក្ខណៈពិសេសដែលនឹងមានប្រសិទ្ធភាពជាលក្ខណៈជាតិក៏ដូចជាអន្តរជាតិ ។ ប្រការនេះមិនអាចសម្រេចបានដោយគ្រាន់តែបន្ថែមចំនួនចៅក្រមបរទេសទៅក្នុងប្រព័ន្ធតុលាការដែលមានស្រាប់នោះទេ ។ មានតែតុលាការមួយពិសេសចម្លែកខុសពីប្រព័ន្ធតុលាការដែលមានស្រាប់ ដែលប្រជាជនកម្ពុជានិងមិនមែនកម្ពុជាអាចបម្រើការជាចៅក្រមព្រះរាជអាជ្ញានិងបុគ្គលិកប្រតិបត្តិ ។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ តាម៉ុក និង ឌុច ត្រូវបានចោទប្រកាន់ពី«បទប្រល័យពូជសាសន៍» នៅក្រោមច្បាប់មាត្រា១ចេញប្រកាសនៅថ្ងៃទី១៥ សីហា ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ អតីតមេដឹកនាំខ្មែរក្រហម អៀងសារី និង នួន ជា ដែលបានចងសម្ព័ន្ធភាពជាមួយ

រដ្ឋាភិបាល ហ៊ុន សែន ធ្វើសេចក្តីថ្លែងការណ៍ថា ប្រសិនបើមានតុលាការកាត់ក្តីមេដឹកនាំខ្មែរក្រហម វាប្រហែលជាបណ្តាលឲ្យកើតមានសង្គ្រាមស៊ីវិល ។ សេចក្តីថ្លែងការណ៍នេះថែមទាំងបានរិះគន់ពីការប្តឹងទាមទាររបស់ក្រុមសិទ្ធិមនុស្សនិងអ្នកនយោបាយគណបក្សប្រឆាំងដែលចង់កាត់ទោស នួន ជា និង អៀង សារី ។

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៩ ខណៈពេលដែលចូលរួមក្នុងមហាសន្និបាតលើកទី៥៤ សម្តេច ហ៊ុន សែន បានបញ្ជូនឯកសារមួយទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដោយរួមមានជម្រើស៣សម្រាប់អង្គការសហប្រជាជាតិនៅក្នុងតុលាការ ។ ១) ផ្តល់ក្រុមអ្នកច្បាប់និងចូលរួមក្នុងការដឹកនាំតុលាការ នៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។ ២) ផ្តល់ជាទីប្រឹក្សាច្បាប់ដោយមិនចូលរួមដោយផ្ទាល់នៅក្នុងតុលាការ និង ៣) ដកខ្លួនចេញពីតុលាការ ។

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ ពេលដែលត្រឡប់មកពីជួបពិភាក្សាជាមួយ កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិអំពីរបៀបនៃការកាត់ទោសអតីតបក្ខពួក ប៉ុល ពត មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់សច្ចាថានឹងដំណើរការការកាត់ទោសដោយផ្ទាល់ ។ ជំនួសមុខដោយការចូលរួមរបស់តុលាការដែលមានបែបបទអន្តរជាតិដែលស្នើដោយអង្គការសហប្រជាជាតិ ឧបនាយករដ្ឋមន្ត្រី សុខ អាន បានថ្លែងថា រដ្ឋាភិបាលកម្ពុជានឹងស្វែងរកយោបល់ពីសហរដ្ឋអាមេរិកនិងអ្នកជំនាញច្បាប់របស់បារាំងដែលមានឯករាជ្យដើម្បីការពារការរិះគន់ថាកម្ពុជាខ្វះខាតប្រព័ន្ធតុលាការ ។ លោក សុខ អាន និយាយថា «យើងនឹងបន្តការងារជាមួយច្បាប់ព្រាងរបស់យើង ហើយខ្ញុំសន្យាថានឹងរក្សាការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិចំពោះដំណើរការនេះ» ។

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៩៩ ក្រសួងការបរទេសរបស់សហរដ្ឋអាមេរិកលុបឈ្មោះខ្មែរក្រហមចេញពីបញ្ជីភេរវករ ពីព្រោះថា «មិនយូរប៉ុន្មានខ្មែរក្រហមនឹងមិនមានវត្តមានជាភេរវករទៀតទេ» ។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន យល់ព្រមតាមសំណើរបស់អង្គការសហប្រជាជាតិចំពោះតុលាការឲ្យមានចៅក្រមកម្ពុជា៣រូបនិងចៅក្រមពីររូបដែលជ្រើសរើសដោយអង្គការសហប្រជាជាតិ ។ សេចក្តីសម្រេចតម្រូវឲ្យ «មានមតិភាគច្រើនលើសលប់» ដែលយ៉ាងហោចណាស់មានចៅក្រមមួយរូបដែលជ្រើសរើសដោយអង្គការសហប្រជាជាតិយល់ស្របនឹងសេចក្តីសម្រេចរបស់តុលាការ ។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនច្បាប់ព្រាងទៅអង្គការសហប្រជាជាតិរៀបរាប់ពីមធ្យោបាយកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងការប្រជុំពិសេសនៅក្នុងតុលាការភ្នំពេញដោយមានចៅក្រមកម្ពុជាភាគច្រើន ដែលមានចៅក្រមបរទេសមួយរូបនិងចៅក្រមខ្មែរមួយរូបធ្វើការសម្រេចចិត្ត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា «កម្ពុជានឹងចាប់ផ្តើមអនុម័តិច្បាប់ទោះបីជាមាន ឬមិនមានការយល់ស្របពីអង្គការសហប្រជាជាតិក៏ដោយ» ។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៩ សុខ អាន និយាយថា «អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានអត្ថាធិប្បាយទៅលើសេចក្តីព្រាង ហើយបញ្ចេញយោបល់ថា អង្គការសហប្រជាជាតិជ្រើសរើសជម្រើសទីពីរនៃអនុស្សរណៈរបស់យើង» ។ (ក្នុងចំណោមជម្រើស៣ដែលសម្តេច ហ៊ុន សែន បានស្នើជូន អាណាន់ កាលពីថ្ងៃទី២០ ខែកញ្ញា) ។

ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានកែប្រែវិសោធនកម្មច្បាប់ថា ការចំណាយពីមុនដែលជាការចំណាយរបស់មូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិទៅលើតុលាការគឺជាការចំណាយរួមដែលមូលនិធិនេះបានមកពីជំនួយរបស់អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល និងប្រទេសដទៃទៀតក្នុងនោះរួមមានរដ្ឋាភិបាលកម្ពុជាផងដែរ ។ សេចក្តីកែប្រែនោះអះអាងថា ប្រសិនបើប្រទេសដទៃចង់បញ្ជូនចៅក្រម ឬព្រះរាជអាជ្ញាមកកាន់អង្គជំនុំជម្រះ ប្រទេសទាំងនោះត្រូវតែចេញថ្លៃចំណាយដោយខ្លួនឯង ។

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ បែនសុន សម័យ មេធាវីរបស់ តាម៉ុក និយាយថា គាត់មានគម្រោង កោះហៅអតីតមេដឹកនាំនៅក្នុងពិភពលោករួមទាំងអតីតប្រធានាធិបតីរបស់សហរដ្ឋអាមេរិកផងដើម្បីសួរចម្លើយអំពីការជួយឧបត្ថម្ភរបបកម្ពុជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ នៅក្នុងនោះគាត់មាន

បំណងកោះហៅ ជីមី ខាធ័រ, រ៉ូណាល់ រីហ្គេន, ហ្សក ប៊ូស, ម៉ាហ្គារេត ថាតឆឺ និង ហេនរី ឃីស៊ីងជឺ ។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ ច្បាប់ព្រាងទីពីររបស់តុលាការត្រូវបានបញ្ជូនទៅឲ្យលេខាធិការដ្ឋានអង្គការសហប្រជាជាតិដោយមានការស្នើសុំផ្សេងទៀតដើម្បីឲ្យមានការឆ្លើយតបភ្លាមៗ ។

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០០ ទីប្រឹក្សាច្បាប់អង្គការសហប្រជាជាតិ លោក ហែន កូរេល បានជួបពិភាក្សាជាមួយអគ្គរាជទូត អ៊ុច បូរិទ្ធ អ្នកតំណាងកម្ពុជានៅអង្គការសហប្រជាជាតិដើម្បីបញ្ជូនការឆ្លើយតបរបស់អង្គការសហប្រជាជាតិអំពីច្បាប់ព្រាងទីពីរពាក់ព័ន្ធនឹងអង្គជំនុំជម្រះ ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០០ ឧបនាយករដ្ឋមន្ត្រីកម្ពុជាយល់ស្របនឹងច្បាប់ព្រាងសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ចំពោះអំពើប្រល័យពូជសាសន៍ ប៉ុន្តែអង្គការសហប្រជាជាតិនៅតែបារម្ភអំពីភាពមានកម្រិតរបស់ចៅក្រមអន្តរជាតិ ។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ ឧបនាយករដ្ឋមន្ត្រីបានកែប្រែច្បាប់ព្រាងរបស់តុលាការដោយអនុញ្ញាតឲ្យមានការចូលរួមពីចៅក្រមបរទេសនៅក្នុងដំណើរការនេះ ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ អង្គការសហប្រជាជាតិទទួលបានច្បាប់ព្រាងដែលកែប្រែរួចអំពីការកាត់ទោសខ្មែរក្រហមជាឯកសារបកប្រែ ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០០ ឯកឧត្តម សុខ អាន បានប្រាប់អ្នកសារព័ត៌មានថា គាត់បានបញ្ជូនច្បាប់ព្រាងរបស់តុលាការទៅកាន់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដើម្បីយកទៅពិភាក្សានៅក្នុងសភាជាតិកម្ពុជា ។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ វេទិកាពិភាក្សាសាធារណៈរបស់កម្ពុជាអំពីតុលាការខ្មែរក្រហមត្រូវបានប្រារព្ធឡើងនៅទិសពាយ័ព្យនៃខេត្តបាត់ដំបង ។ ប្រជាជនប្រហែល១០០នាក់ រួមទាំងមន្ត្រីខ្មែរក្រហមថ្នាក់កណ្តាលបានចូលរួមការពិភាក្សានេះ ។

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០០ អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ខៀវ សំផន និយាយថា គាត់តាំងចិត្តថានឹងមកនិយាយនៅក្នុងវេទិកាសាធារណៈ ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០០ រហូតដល់ពេលនេះ នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនទាន់បានប្រគល់ការត្រួតពិនិត្យអង្គជំនុំជម្រះទៅឲ្យអង្គការសហប្រជាជាតិនៅឡើយទេ ដូច្នេះក្តីសង្ឃឹមរបស់តុលាការពីបទប្រល័យពូជសាសន៍អន្តរជាតិគឺនៅស្រពេចស្រពិល ។ ក្នុងឱកាសនិយាយទៅកាន់អ្នកសារព័ត៌មានបន្ទាប់ពីបិទការប្រជុំ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់ការទាមទាររបស់អង្គការសហប្រជាជាតិឲ្យមាន «ការកាត់ទោសជាអន្តរជាតិទៅលើរបបវាលពិឃាតថាជាកលល្បិចមួយ» និងជំរុញឲ្យពិភពលោកចាប់អារម្មណ៍ទៅលើភាពក្រីក្ររបស់កម្ពុជាវិញ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងថា «ខ្ញុំសូមផ្ញើសារដ៏សំខាន់មួយគឺថា ពិភពលោកគួរតែចាប់អារម្មណ៍ទៅលើសន្តិភាព ការផ្សះផ្សាជាតិ សហគមន៍ជាតិ ការអភិវឌ្ឍសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រជាជាងបង្កើតតុលាការខ្មែរក្រហម» ។

លោកអគ្គលេខាធិការ កូហ្វី អាណាន់ និយាយថា គាត់មិនបានយល់ស្របនឹងច្បាប់ព្រាងកម្ពុជា ដែលយល់ព្រមដោយរាជរដ្ឋាភិបាលកម្ពុជាទេ ។ គាត់បង្ហាញពីបញ្ហាសំខាន់៤គឺ ធានាថាអ្នកដែលត្រូវបានចោទប្រកាន់នឹងត្រូវចាប់ខ្លួន ។ មិនមានការអភ័យទោសឬលើកលែងទោស ហើយមានការតែងតាំងព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមបរទេសភាគច្រើនដោយឯករាជ្យ ។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន មិនយល់ស្របនឹងការឆ្លើយតបរបស់ កូហ្វី អាណាន់ ចំពោះច្បាប់ព្រាងតុលាការខ្មែរក្រហមដោយយល់ថាគ្មានយុត្តិធម៌ ។ នៅក្នុងលិខិតផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ នាយករដ្ឋមន្ត្រីអះអាងថា គាត់មិនបានស្វាគមន៍មុខងារខុសគ្នារវាងអង្គការសហប្រជាជាតិនិងកម្ពុជា ជាពិសេសមុខងារដែលជ្រើសតាំងដោយប្រទេសជាសមាជិក ។

នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០០នៅចំកណ្តាលសន្និសីទពាណិជ្ជកម្មអង្គការសហប្រជាជាតិនៅទីក្រុងបាងកក អគ្គលេខាធិការ កូហ្វី អាណាន់ និយាយថាខ្លួនមានសុទិដ្ឋិនិយមថា បេសកកម្មថ្មីរបស់អង្គការសហប្រជាជាតិនៅកម្ពុជានឹងដោះស្រាយភាពមិនយល់ស្របគ្នាជាមួយរដ្ឋាភិបាលអំពីការបង្កើតតុលាការ ។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០ អតីតរដ្ឋមន្ត្រីការបរទេស

របស់សហរដ្ឋអាមេរិក លោក ហេនរី ឃីស៊ីងជឺ បានឲ្យយោបល់ថា គាត់គួរតែធ្វើជាកសិណសាក្សីនៅក្នុងតុលាការប្រល័យពូជសាសន៍ខ្មែរក្រហមដោយនិយាយថា នយោបាយសង្គ្រាមត្រជាក់អាចបញ្ឈប់កងទ័ពព្រៃកម្ពុជា ។ ឃីស៊ីងជឺ និយាយថា «ខ្ញុំអាចជាសាក្សីម្នាក់ឲ្យព្រះរាជអាជ្ញាខាងចុងចោទ ហើយខ្ញុំជឿថា ប្រជាជនទាំងអស់នៅតំបន់នេះដែលដឹងអំពីកម្ពុជានឹងគាំទ្រការងារនេះ» ។

ថ្ងៃទី៦ ខែមីនា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់អង្គការសហប្រជាជាតិថា អតីតអគ្គលេខាអង្គការសហប្រជាជាតិពីរូបគួរតែទទួលខុសត្រូវចំពោះមុខងាររបស់ខ្មែរក្រហមដែលមានអាសនៈមួយនៅអង្គការសហប្រជាជាតិក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៧០និង១៩៨០ ។ ព្រះអង្គម្ចាស់ រណឫទ្ធិ មានព្រះបន្ទូលប្រាប់អ្នកសារព័ត៌មានថា ព្រះអង្គយល់អំពី «ការពិត» នៃគំណែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែព្រះអង្គម្ចាស់និងព្រះបិតា(សម្ដេចសីហនុ) សង្ឃឹមថា នឹងឆ្ពោះទៅដល់ការសម្របសម្រួលមួយ ។

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិនិងកម្ពុជាបានបើកការប្រជុំចុងក្រោយដើម្បីពិភាក្សាពីភាពខុសគ្នាខ្លាំងនៅក្នុងតុលាការខ្មែរក្រហម ។ បញ្ហាសំខាន់៤ស្ថិតនៅចំពោះមុខ តើអ្នកណានឹងឲ្យឈ្មោះជនសង្ស័យនៅក្នុងអង្គជំនុំជម្រះ? តើរាជរដ្ឋាភិបាលកម្ពុជានឹងចាប់រាល់ជនសង្ស័យទាំងអស់ឬទេ? តើរាជរដ្ឋាភិបាលដែលពាក់ព័ន្ធជាមួយខ្មែរក្រហមនឹងការពារអតីតអ្នកបះបោរពីការកាត់ទោសឬទេ? តើចៅក្រមបរទេសនិងចៅក្រមកម្ពុជានឹងព្រមព្រៀងគ្នាដោយរបៀបណា?

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០០ មានលិខិតឆ្លើយឆ្លងរវាងអ្នកតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការងារច្បាប់ ហែន កូរេល និងឧបនាយករដ្ឋមន្ត្រី សុខ អាន ចំពោះបញ្ហាពាក់ព័ន្ធនឹងការលើកលែងទោស សហព្រះរាជអាជ្ញានិងអំណាចឯករាជ្យ ករណីគ្មានការឯកភាពគ្នា យន្តការនៃការសម្របជម្លោះនៅតែមិនទាន់សម្រេច ។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០០០ កិច្ចចរចាប្រព្រឹត្តទៅអស់រយៈមួយសប្តាហ៍ កម្ពុជានិងអង្គការសហប្រជាជាតិប្រកាសថា គេមិនបានឆ្ពោះទៅការយល់ស្របគ្នាអំពីរបៀបនៃការរៀបចំតុលាការសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ សម្ដេច សីហនុ ប្រកាសថា ទ្រង់មានបំណងប្រឈមមុខនឹងប្រជាជនកម្ពុជា ព្រមទាំងតុលាការអំពើប្រល័យពូជសាសន៍អន្តរជាតិដើម្បីប្រាប់ពីតួនាទីរបស់ទ្រង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០លោក អាណាន់ បានសរសេរលិខិតមួយផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឆ្លើយតបនឹងការគាំទ្រគម្រោងសហរដ្ឋអាមេរិករបស់មេដឹកនាំកម្ពុជាអំពីរបៀបនៃការដោះស្រាយបញ្ហាចំពោះការចោទប្រកាន់មេដឹកនាំនៅក្នុងតុលាការ ។ អ្នកដឹកនាំការចរចា លោក សុខ អាន ឆ្លើយតបនឹងសំបុត្ររបស់លោក អាណាន់ ថា «ខ្ញុំមិនទាន់បានត្រួតពិនិត្យនៅឡើយទេ» ។ លោក អាណាន់ ប្រាប់អ្នកសារព័ត៌មាននៅទីស្នាក់ការអង្គការសហប្រជាជាតិថា «មានតែឆ្លងកាត់ការត្រួតពិនិត្យទើបធ្វើឲ្យមានការបកស្រាយនិងការពិសោធអំពីដំណើរការ ។ មានសំណើមួយចំនួនត្រូវបានរក្សាទុកនៅលើតុ សម្រាប់ឲ្យដោះស្រាយ ប៉ុន្តែមានភាពរាំងស្ទះមួយ គឺរបៀបនៃការរក្សាស្ថានភាពនៅពេលដែលព្រះរាជអាជ្ញាមួយរូបមិនយល់ស្របនឹងគំនិតព្រះរាជអាជ្ញាឯទៀត» និងរបៀបនៃយន្តការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពអាចដំណើរការបាន ។

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបនឹងសំបុត្ររបស់អគ្គលេខាធិការកាលពីថ្ងៃទី១៩ ខែមេសា ដែលក្នុងនោះសម្ដេចអះអាងថា ការឆ្លើយតបនឹងសំបុត្ររវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាមិនអាចធ្វើអ្វីបានទេមុនពេលដែលច្បាប់មិនទាន់បានអនុម័ត ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើសុំឲ្យមាន «សវនាការពិសេស» ដើម្បីដោះស្រាយការមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញា ។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០ លោក អាណាន់ បានផ្ញើលិខិតទីពីរជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឆ្លើយតបនឹងលិខិតកាលពីថ្ងៃ២២ ខែមេសា ដែលជំរុញឲ្យលោកទទួលយកសំណើរបស់អង្គការសហប្រជាជាតិ ។ **(នៅមានត)**

**លី សុផល**

# អតីតកម្មាភិបាលខ្មែរក្រហមភ្នំវល្លិ៍


ស្រី ពៅ

ស្រី ពៅ ជាអតីតកម្មាភិបាលខ្មែរក្រហមផ្តាច់ខ្លួននៅតំបន់ភ្នំវល្លិ៍ក្នុងខេត្តកំពត ។ ពៅ ធ្លាប់បម្រើកងទ័ពតាំងពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៩៦ ។ ពៅ ឆ្លងកាត់នូវបទពិសោធន៍ជាច្រើនស្ទើរពាក់កណ្តាលជីវិតរបស់គាត់ទៅហើយ ។

ស្រី ពៅ ភេទប្រុស អាយុ៥៥ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។ កាលពីក្មេង ពៅ ធ្លាប់រៀនបានត្រឹមថ្នាក់ទី១២សាលាវត្តចក្រីទីងនៅក្នុងស្រុកកំណើតរបស់គាត់ ។ ពៅ កំព្រាឪពុកតាំងពីគាត់អាយុ៧ឆ្នាំម្ល៉េះ ។ ពៅមានប្អូនប្រុសបីនាក់(ប្អូនប្រុសពីរនាក់ជាកូនឪពុកចុង) ឈ្មោះ ហេង ប៉ាត់, ហេង ខន និង ហេង ខុន ។

នៅក្នុងអំឡុងឆ្នាំ១៩៧០ ពៅ រស់នៅស្រុកមួយក្នុងខេត្តកំពតដែលជាស្រុកប្រទាញប្រទង់រវាងទាហានលន់នល់និងទាហានធីវគី ។ ដោយសារតែការរាតត្បាតរវាងទាហានទាំងពីរក្រុមនេះ បានធ្វើឲ្យក្រុមគ្រួសាររបស់ ពៅ រត់ភៀសខ្លួនចុះឡើងៗដើម្បីស្វែងរកកន្លែងសុវត្ថិភាព ។ ជាមួយគ្នានោះក៏មានការឃោសនាមួយលេចឡើងគឺក្នុងន័យការពារទឹកដីវាយលន់នល់និងបណ្តេញចក្រពត្តិអាមេរិកចេញពីទឹកដីកម្ពុជា ។ ពៅ បានជាប់ឈ្មោះជាសមាសភាពឈ្លបឆ្មក់នៅក្នុងភូមិ ។ នៅក្រោយពេលរដ្ឋប្រហារទម្លាក់សម្តេចឆ្នាំ១៩៧០ ពៅ បានចូលបម្រើចលនាខ្មែរក្រហមពេញលក្ខណៈ ។ បងប្អូនទាំងអស់របស់ ពៅ សុទ្ធតែចូលបម្រើកងទ័ព ។ ពៅ បានចូលបម្រើចលនាខ្មែរក្រហមនៅតំបន់ស្រុកកំពត ខេត្តកំពត ចំណែក ខុន បម្រើការនៅតំបន់ប៉ៃលិន ។ ឯ ប៉ាត់ និង ខន បម្រើកងទ័ពខាងសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រចាំការនៅកោះពូឡូវៃតួនាទីកាន់កាំភ្លើងធំនិងដែនទី(ឆ្នាំ១៩៧៩) ។

នៅឆ្នាំ១៩៧៣ ពៅ ត្រូវបានតែងតាំងជាប្រធានក្រុមគ្រប់គ្រងសមាជិក១២នាក់ដើម្បីវែកដីធ្វើទំនប់កោះស្លា ។ (ទំនប់កោះស្លាមានប្រវែងប្រហែលជា២០គីឡូម៉ែត្រគឺចាប់ពីរោងអាត្រាក់ ស្រុកកំពង់ត្រាច មកទល់នឹងវត្តកោះស្លាសព្វថ្ងៃ ។ ទំនប់នេះមានមាត់លើប្រហែល១១ទៅ១២ម៉ែត្រ) ។ ក្រោយមក ពៅ ត្រូវបញ្ជូនទៅលត់ដំឲ្យឃ្វាលហ្វូងគោក្របីជាមួយសមាជិកចំនួន១៥នាក់ទៀត ដោយសារតែបងប្អូនជីដូនមួយរបស់គាត់ត្រូវបានយកទៅសម្លាប់ដោយចោទប្រកាន់ពីបទលួចបាយក្តាំងនៅបាតខ្ទះយកទៅឲ្យពួកចោរព្រៃ ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមកដល់កម្ពុជា ។ ពេលនោះ ពៅ បានរត់ចូលព្រៃជាមួយខ្មែរក្រហម ។

រហូតមកដល់ឆ្នាំ១៩៨០ ក្រុមចលនាខ្មែរក្រហមបានចាប់ផ្តើមប្រមូលកម្លាំងរបស់ខ្លួនសាជាថ្មី ពៅ ក៏បានចូលនៅក្នុងចលនានោះម្តងទៀតរហូតមកដល់ពេលផ្តាច់ខ្លួននៅឆ្នាំ១៩៩៦ ។

នៅឆ្នាំ១៩៨០ដល់ឆ្នាំ១៩៨១ ដោយសារមានស្នាដៃល្អនៅក្នុងពេលឡើងច្បាំងនៅក្នុងសមរភូមិ ពៅ ត្រូវបានដំឡើងឋានៈជាសមាជិកទីបីនៅតំបន់ភ្នំវល្លិ៍ នៅក្នុងនោះមាន ម៉ៃ ជាមេដឹកនាំធំ

បន្ទាប់មក នួន ប៉ែត ហើយទីបីគឺរូបគាត់ ។

ឆ្នាំ១៩៩១ដល់ឆ្នាំ១៩៩៦ ពៅ មានឋានៈជាវរសេនីយ៍ គ្រប់គ្រងកម្លាំងទ័ពជាង៣០០នាក់ ប្រចាំនៅស្រុកកំពត ដែលមានទីតាំងនៅតំបន់កោះស្លា ។

នៅឆ្នាំ១៩៩៧ បន្ទាប់ពីការធ្វើសមាហរណកម្មរវាងរាជរដ្ឋាភិបាលនិងកងទ័ពខ្មែរក្រហម ពៅ បានសម្រេចចិត្តរួមរស់ជាមួយប្រជាជនកម្ពុជាវិញ ។ បទពិសោធន៍របស់គាត់ដែលបានឆ្លងកាត់សង្គ្រាមជិតពាក់កណ្តាលជីវិតនោះបានធ្វើឲ្យ ពៅ រាងចាលនិងខ្លាចរអា ហើយថែមទាំងផ្តែផ្តាំកូនចៅរបស់គាត់និងក្មេងៗជំនាន់ក្រោយថាកុំឲ្យបម្រើនយោបាយគេទៀត ពីព្រោះគ្មានប្រយោជន៍អ្វីឡើយ មានតែការចាញ់បោកប៉ុណ្ណោះ ហើយទីបញ្ចប់រកតែដីស្រែចែកឲ្យកូនចៅធ្វើមិនបានផង ។ មិនតែប៉ុណ្ណោះ សង្គ្រាមបានបន្សល់ទុកនូវពិការភាព ខ្វះខ្វាក់ភ្នែក ពិការដៃជើងថែមទៀត ។ ពៅ បន្តថា គិតតែពីរឿងដាំដុះធ្វើស្រែចម្ការ ហើយរស់នៅជាប្រជាជនធម្មតាបានហើយមិនចាំបាច់បម្រើទ័ពនាំតែពិបាកដេកព្រៃ ព្រាត់ប្រាសកូនចៅនិងពីឪពុកម្តាយប៉ុណ្ណោះ ។

ពៅ យល់ថាការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចជួយឲ្យបងប្អូនជនរងគ្រោះមួយចំនួនអស់ចិត្ត ឬអាចស្ងប់ចិត្ត ពីព្រោះថាអ្នកដែលស្លាប់ទៅក៏មានបងប្អូនឪពុកម្តាយ ប្តី ប្រពន្ធ កូន នៅរស់ចង់ដឹងថាតើឪពុកម្តាយ ប្តី ប្រពន្ធ បងប្អូន កូនចៅរបស់ខ្លួនស្លាប់ដោយសារមូលហេតុអ្វី ហើយនរណាជាអ្នកទទួលខុសត្រូវលើការស្លាប់នោះ? ដូច្នេះ តុលាការខ្មែរក្រហមពិតជាមានសារសំខាន់ណាស់សម្រាប់ជនរងគ្រោះទាំងអស់នោះ ។

តាមការស្ទាបស្ទង់មតិរបស់ ពៅ ទៅលើប្រជាជនដែលបានផ្តាច់ខ្លួន ថាតើប្រសិនបើតុលាការនាំយកមេរបស់ខ្លួនទៅកាត់ទោសតើអាចមានផលប៉ះពាល់ ឬសង្គ្រាមកើតឡើងវិញដែរឬទេ? ពៅ ហ៊ានអះអាងថា មិនអាចទៅរួចទេ ពីព្រោះប្រជាជននៅតំបន់កោះស្លាមិនចង់ឮអ្វីទាំងអស់ សូម្បីតែពាក្យថាសង្គ្រាម ។ អ្នកទាំងនោះចុះចូលជាមួយរាជរដ្ឋាភិបាលគឺក្នុងគោលបំណងចង់បានសេចក្តីសុខជួបជុំក្រុមគ្រួសារញាតិមិត្តបងប្អូនបង្កបង្កើនផលដើម្បីចិញ្ចឹមជីវិត ។ ប្រជាជនទាំងនោះក៏មិនចង់រត់ចុះរត់ឡើងគ្មានជម្រកពិតប្រាកដ ហើយកូនចៅមិនបានរៀនសូត្រនោះទេ ។ ពៅ តែងតែនិយាយរៀបរាប់អំពីប្រវត្តិឈឺចាប់និងការនឿយណាយរបស់គាត់ប្រាប់ដល់ញាតិមិត្តជិតខាងនិងកូនចៅរបស់គាត់ក្នុងគោលបំណងទូន្មានថា របបកុម្មុយនីស្តរស់នៅមិនស្រួលទេ គ្មានសិទ្ធិសេរីភាព ក្នុងការនិយាយស្តី ការហូបចុកមិនគ្រប់គ្រាន់ ធ្វើការហួសកម្លាំង ឪពុកមិនស្គាល់កូន មិនបានរស់នៅជួបជុំក្រុមគ្រួសារ ជាក់ស្តែងមានរបបកម្ពុជាប្រជាធិបតេយ្យជាតឹកតាង ។ ពៅ បន្តថា សូម្បីតែឪពុកម្តាយរបស់គាត់ដែលមានវ័យចាស់ជរាដើរកោងខ្នង ក៏ខ្មែរក្រហមប្រើឲ្យមើលកុមារៗដែរដើម្បីឲ្យឪពុកម្តាយរបស់ក្មេងចេញទៅធ្វើការ ។

បន្ថែមលើពីនោះ ពៅ ចង់ឲ្យមានកម្មវិធីសិក្សាអំពីរបប៣ឆ្នាំ៨ខែនិង២០ថ្ងៃនៅតាមសាលារៀនដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានយល់និងចូលរួមទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត ។

**គង់ សុភគឿន**

## ការចូលរួមរបស់ជនរងគ្រោះ

នៅអំឡុងឆ្នាំ២០០៨មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងចង់ឲ្យជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិច ១០,០០០នាក់ ចូលរួមបំពេញពាក្យបណ្តឹង (ជាឧក្រិដ្ឋកម្ម ឬជាដើមបណ្តឹងរដ្ឋប្បវេណី) មុនពេលចូលទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញពីសកម្មភាពនេះថាជាការជួយដល់ប្រជាជនសាមញ្ញកម្ពុជាឲ្យចូលរួមក្នុងដំណើរការនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោសនៅមុខច្បាប់និងដំណើរការម្តងទៀតនូវ «គណៈកម្មការស្វែងរកការពិត» ជាលក្ខណៈមិនសូវផ្លូវការដែលគណៈកម្មការនេះបានចាប់ផ្តើមតាំងពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ម៉្លេះ ដោយការចុះហត្ថលេខាលើញត្តិរណសិរ្ស ។

សម្រាប់ព័ត៌មានលម្អិតសុំទំនាក់ទំនង លោក ជី ទេរិទ្ធ តាមរយៈលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

# ការឆ្លុះបញ្ចាំងអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងរបបក្រោយៗមកទៀត

នៅថ្ងៃទី១៧មេសា ឆ្នាំ២០០៨នេះ មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំការតាំងពិព័រណ៍ថ្មីមួយដែលឆ្លុះបញ្ចាំងអំពី «របបកម្ពុជាប្រជាធិបតេយ្យនិងរបបក្រោយៗមកទៀត» នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ពិព័រណ៍ថ្មីដែលត្រូវរៀបចំនៅក្នុងអគារចំនួនបីរបស់សារមន្ទីរទួលស្លែងមានគោលបំណងនាំយកអ្នកទស្សនាសារមន្ទីរឲ្យមកមើលទិដ្ឋភាពប្រវត្តិ-សាស្ត្រពិតប្រាកដមួយដែលចាប់ផ្តើមឡើងនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នៅពេលដែលកងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ។ រូបថតពិសេសៗដែលជ្រើសរើសចេញពីបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមើលឃើញនឹងភ្នែកត្រូវបានដាក់តាំងនៅលើជញ្ជាំងបរិយាយអំពីជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការធ្វើទារុណកម្ម ការសម្លាប់ និងប្រព័ន្ធសម្លាប់នៅក្នុងគុក ការរកឃើញនិងគាស់កកាយរណ្តៅសាកសពច្រើនឥតគណនានិងរបៀបជាច្រើនដែលប្រជាជនកម្ពុជាស្វែងរកដើម្បីចងចាំនិងធ្វើបុណ្យរំឭកដល់ជនរងគ្រោះនិងដំណើរការបន្តនិងការស្វែងរកយុត្តិធម៌ ។

ការឆ្លុះបញ្ចាំងនេះនឹងលើកឡើងនូវចម្ងល់ជាច្រើននិងប្រហែលជាធ្វើឲ្យមានការយល់ឃើញកាន់តែច្បាស់អំពីបរិបទប្រវត្តិសាស្ត្រដែលនៅពីក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ឧទាហរណ៍តើមានអ្វីកើតឡើងនៅក្នុងអំឡុងពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃនៃការបង្ហូរឈាម? តើខ្មែរក្រហមចង់បានអ្វី? តើយុទ្ធសាស្ត្រអ្វីដែលខ្មែរក្រហមយកមកអនុវត្តក្នុងការសម្រេចទិសដៅទាំងនោះ? ហើយតើទិសដៅនោះជាអ្វីទើបធ្វើឲ្យប៉ះពាល់ដល់ប្រជាជន? តើការរំឭកអ្វីដែលត្រូវធ្វើឡើងដើម្បីចងចាំដល់អ្នកដែលស្លាប់? តើត្រូវធ្វើអ្វីខ្លះដើម្បីយកជនដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោស?

នៅពេលជាមួយគ្នា ពិព័រណ៍នេះប្រហែលជាបង្កើតចម្ងល់ខ្លះដែលនឹងមិនមានចម្លើយនោះគឺ ថាតើបុគ្គលម្នាក់ៗ សហគមន៍ និងប្រជាជាតិអាចផ្សះផ្សានិងកសាងជីវិតថ្មីដោយរបៀបណា? តើមនុស្សដូចគ្នាចាប់ផ្តើមបែងចែកក្រុមមនុស្សដែលត្រូវសម្លាប់ដាក់ទណ្ឌកម្ម និងអ្នកដែលគ្មានមនុស្សធម៌ដោយរបៀបណា? តើអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម អ្នកមានវត្តមានដឹងឮ ឬក៏ជនរងគ្រោះដែលត្រូវខ្មែរក្រហមបោកបញ្ឆោតទាំងផ្លូវកាយនិងផ្លូវចិត្តឲ្យធ្វើការហើយការប្រឹងប្រែងរបស់ខ្មែរក្រហមគឺដើម្បីបង្កើត «វណ្ណៈសង្គម» មែនឬទេ? តើអំពើឃោរឃៅនេះនឹងបន្តកើតឡើងដោយគ្មានអ្នកបញ្ឈប់ដោយរបៀបណា? ជាសរុប តើមានអ្វីកើតឡើងចំពោះពាក្យសន្យាដែល «មិនអាចមានម្តងទៀត» នូវអំពើប្រល័យពូជសាសន៍?

ការអប់រំស្តីពីអំពើប្រល័យពូជសាសន៍មានសារសំខាន់តាមហេតុផលពីរ ។ ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសម្រាប់ឲ្យសិស្សនិស្សិតសិក្សាដំបូងអះអាងចំពោះ «ការអប់រំស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា» នេះគឺជាមធ្យោ-បាយតែមួយគត់ដើម្បីទប់ស្កាត់អំពើឃោរឃៅរបៀបខ្មែរក្រហមមិនឲ្យកើតមានម្តងទៀត ។ ការអប់រំសិស្សនិស្សិតអំពីអ្វីដែលបានកើតឡើងក្នុងរបបប៉ុលពតអាចធ្វើឲ្យមានការពិភាក្សារវាងសិស្សនិងបងប្អូនរបស់ខ្លួនគឺៈ សិស្សនិស្សិតនឹងដឹងអំពីប្រវត្តិសាស្ត្រដែលបានសិក្សានៅតាមសាលា និងពេលដែលបងប្អូនរបស់ខ្លួននិយាយអំពីរបបនេះ ហើយអាចប្រាប់ព័ត៌មានទៅឲ្យកូនចៅជំនាន់ក្រោយទៀត ។ នៅពេលជាមួយគ្នានេះដែរ ការអប់រំអំពើប្រល័យពូជសាសន៍ប្រហែលជាអាចធ្វើឲ្យការឈឺចាប់របស់ជនរងគ្រោះមានភាពធូរស្បើយ ពីព្រោះការឈឺចាប់អាចក្លាយទៅជា «ការចងចាំនិងចំណេះដឹង» យ៉ាងណាមិញខ្ញុំអាចនឹងទាញហេតុផលថា ការអប់រំស្តីពីអំពើប្រល័យពូជសាសន៍ប្រហែលជាអាចធ្វើឲ្យមានការយល់ចិត្តនិងការអាណិតពីកូនចៅជំនាន់ក្រោយនេះគឺមានសារសំខាន់និមានឥទ្ធិពលចំពោះការធ្វើឲ្យប្រជាជនមានភាពធូរស្បើយពីមុខរបួស ។

ប៉ុន្តែការអប់រំអំពើប្រល័យពូជសាសន៍តាមសៀវភៅរបស់បូលី នៅតែ «មិនបានយកទៅអនុវត្តនៅតាមសាលារៀននៅកម្ពុជា យោងទៅតាមសង្គម នយោបាយ និងបញ្ហាគរុកោសល្យ ។ ជាការពិត សិស្សនៅកម្ពុជាបច្ចុប្បន្នសិក្សាអំពីប្រវត្តិសាស្ត្រដោយ

មិនមានសៀវភៅអានដែលធ្វើឲ្យមានការព្រួយបារម្ភកាន់តែច្រើន និងមានចម្ងល់អំពីការរៀបចំនិងការអប់រំដែលគ្មានប្រសិទ្ធភាព ។

នៅខណៈដែលការរៀបចំថ្នាក់រៀនដែល បូលី បានគាំទ្រ ប្រហែលជាមធ្យោបាយល្អមួយដើម្បីអប់រំយុវជនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តើមានមធ្យោបាយផ្សេងទៀត ដែលអាចប្រើប្រាស់ដើម្បីអប់រំអំពើប្រល័យពូជសាសន៍ខណៈពេលដែលមានឧបសគ្គពីសង្គមផ្សេងគ្នា ឧបសគ្គសេដ្ឋកិច្ច នយោបាយ និងគរុកោសល្យទេ? ខណៈដែលត្រូវផ្តោតទៅលើការកែប្រែកម្មវិធីសិក្សានៅសាកលវិទ្យាល័យនិងវិទ្យាល័យ ផ្លាស់ប្តូរគំនិតរបស់មេដឹកនាំនយោបាយឬផ្គត់ផ្គង់បរិក្ខារសិក្សាដល់គ្រូបង្រៀនជាមួយនឹងឧបករណ៍សម្រាប់អប់រំដែលសំខាន់ដើម្បីអនុវត្តសកម្មភាពដែលមានភាពរាំងស្ទះ ។ ជាការពិតការផ្តល់យោបល់ដែល បូលី បានលើកឡើងនឹងត្រូវយកមកប្រើប្រាស់នៅពេលណាមួយ ។ តើមានអ្វីផ្សេងទៀតដែលអាចបំពេញនៅចន្លោះនេះ?

មជ្ឈមណ្ឌលឯកសារកម្ពុជាបានអប់រំប្រជាជនកម្ពុជារួចមកហើយតាមរយៈមធ្យោបាយផ្សេងៗគ្នាដូចជាតាមខ្សែភាពយន្ត ការចាក់ផ្សាយតាមវិទ្យុ គម្រោងផ្សព្វផ្សាយនៅតាមមូលដ្ឋាននិងដំណើរកម្សាន្ត ព្រមទាំងការចែកចាយទស្សនាវដ្តី ។ នេះប្រហែលជាពេលវេលាដែលពិព័រណ៍សិល្បៈអាចធ្វើការដោយមិនដូវការប្រៀបដូចជា «សៀវភៅអានដែលមានលក្ខណៈមិនបង្ហាញត្រង់ៗ» ក្នុងគោលបំណងសង្ខេបនិងការចងក្រងរឿងជាច្រើនដែលរបបនេះបានរំលោភទៅលើសិទ្ធិមនុស្ស ការដាក់ទណ្ឌកម្មធ្ងន់ និងការបង្កសេចក្តីឈឺចាប់យ៉ាងខ្លាំងដល់ប្រជាជនកម្ពុជាទាំងអ្នកស្លាប់និងទាំងអ្នកនៅរស់ធ្លាប់ឆ្លងកាត់របបនេះ ។ ប៉ុន្តែគ្រាន់តែផ្តល់ព័ត៌មានអំពីអតីតកាលពិព័រណ៍សិល្បៈដែលមានលក្ខណៈជាបន្ទប់សម្រាប់ការពិភាក្សាប្រហែលជាអាចបង្កើតការសន្ទនានិងជំនួយដល់ការពិភាក្សាចំពោះបញ្ហាផ្សេងដែលប្រហែលជាមិនមានចម្លើយ «ស្របនឹងគោលដៅ» ឬ«ពិតត្រឹមត្រូវ» ។ ជាងនេះទៅទៀត ខុសពីសៀវភៅអាន ការផ្សព្វផ្សាយនៅតាមមូលដ្ឋានរបស់ពិព័រណ៍មិនត្រឹមតែមិនមានកំណត់ចំពោះសិស្សនិស្សិតដែលរៀននៅវិទ្យាល័យឬសាកលវិទ្យាល័យទេ ថែមទាំងអាចរីកសាយភាយដល់កូនចៅជំនាន់ក្រោយដែលនៅក្រៅប្រទេសនិងធ្វើឲ្យអ្នកដែលមិនចេះអានឬសរសេរអំពីប្រវត្តិសាស្ត្រ ។

ថ្មីៗនេះនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងមានពិព័រណ៍រូបថតមួយចំនួននៅជាន់ទីពីរៈ អំពីអ្នកដែលនៅរស់ជនរងគ្រោះឬក៏អ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម? ហើយអ្នកធ្វើកោសល្យវិច័យលលាដ៍សាកសពបានផ្តល់ឲ្យអ្នកទស្សនាសារមន្ទីរនូវព័ត៌មានទាក់ទងនឹងលលាដ៍ក្បាលនូវសេចក្តីសង្ខេបយ៉ាងតិចតួចបំផុត ។ ការស្ទាបស្ទង់មតិថ្មីៗនេះបាននិយាយថា អ្នកទស្សនាសារមន្ទីរប្រល័យពូជសាសន៍ជាតិនិងអន្តរជាតិ និងអ្នកឆ្លើយតបភាគច្រើនបានសង្កត់ធ្ងន់ថាមានព័ត៌មានមិនគ្រប់គ្រាន់អំពីហេតុផលដែលនៅពីក្រោយខ្មែរក្រហមនិងជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពេលមានសួរសំណួរថា «តើអ្នកចង់ដឹងពីរបបខ្មែរក្រហមច្រើនជាងនេះទេ?» ស្ទើតែរាល់ចម្លើយទាំងអស់ឆ្លើយថា «ចង់» ។

នេះប្រហែលជាករណីដែលធ្វើឲ្យការឆ្លុះបញ្ចាំងការតាំងពិព័រណ៍ថ្មីមានសារសំខាន់ ប៉ុន្តែនេះគ្រាន់តែជំហានតូចមួយដើម្បីស្វែងរកមធ្យោបាយអប់រំប្រជាជនខ្មែរក៏ដូចជាសហគមន៍អន្តរ-ជាតិឲ្យយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងរបបក្រោយៗទៀត ។ ប្រសិនបើទទួលបានជ័យជម្នះនោះ ពិព័រណ៍នៅសារមន្ទីរក៏ដូចជាការកែប្រែកម្មវិធីសិក្សាដែលជាគំនិតរបស់ បូលី ប្រហែលជាត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវពីរបបខ្មែរក្រហមនៅថ្ងៃខាងមុខ ដែលបណ្តាលឲ្យមានការពិភាក្សាក្នុងចំណោមអ្នកដែលនៅរស់និងកូនរបស់ខ្លួននិងធ្វើឲ្យមានការយល់ដឹងពីអំពើឃោរឃៅ ហើយជំរុញឲ្យមានការចូលរួមនៅក្នុងការស្រាវជ្រាវស្វែងរក«ការពិត» និងយុត្តិធម៌ពីដំណើរជីវិត ។

ប៉ុន្តែនៅពេលជាមួយគ្នា ពិព័រណ៍រូបភាពក៏មានលទ្ធភាពដើម្បីបញ្ជាក់និងបង្ហាញពីបទពិសោធន៍អតីតកាលរបស់អ្នកដែលធ្លាប់រងទុក្ខវេទនានៅក្នុងរបបខ្មែរក្រហម ដែលនេះប្រហែលជាការឆ្លុះបញ្ចាំងពីទិដ្ឋភាពសំខាន់ៗនិងជាមូលដ្ឋាន ។ រ៉ូលែន បាដស៍ បង្កើតទ្រឹស្តីនៅក្នុងម៉ាស៊ីនថតរូបលូសីដាថា រូបថតដែលត្រូវដាក់តាំងដើម្បីឆ្លុះបញ្ចាំង ប្រហែលជាពិតជាមានអានុភាពនិងលទ្ធភាពធ្វើឲ្យមានឥទ្ធិពល«ទៅលើអ្នកមិនស្ថិតក្នុងស្ថានភាពនោះមានអារម្មណ៍ថាខ្លួនឯងធ្លាប់ឆ្លងកាត់របបនោះ» ។ នៅក្នុងការចង្អុលបង្ហាញអំពីទំនាក់ទំនងជីវិតរវាង «វត្ថុពិត» និងរូបភាពជារូបថត បាដស៍ អះអាង

ថា «រាល់រូបទាំងអស់ពេលខ្លះមានលក្ខណៈជាធម្មជាតិអមជាមួយអំណះអំណាង» ឬរូបភាពនៅក្នុងរូបថត មានភាព «ពិត» ពីព្រោះថាបើមិនមាន «ស្ថានភាពពិតទេនោះវាក៏មិនអាចចេញជារូបថតបានដែរ» ។ យោងទៅតាម បាដស៍ រូបថតគឺជាការអះអាងមួយដែលមានរូបភាពពិត «ហាក់ដូចជាមនុស្សធ្លាប់ឆ្លងកាត់រឿងនោះ» ទោះបីជាគេ «មិននៅក្នុងសាច់រឿងក៏ដោយ» ។ ជាងនេះទៅទៀត ស៊ូសាន សុនថេច ធ្វើការនៅកន្លែងថតរូប បន្តធ្វើការតាមគំនិតនៃរូបថតធម្មជាតិនេះបានអះអាងថា រូបថតខុសប្លែកពីរូបគំនូរពីព្រោះរូបថតមាន «លក្ខណៈពិសេសមួយភ្ជាប់ជាមួយការពិត» ។ ហេតុអ្វីបានជារូបថតមួយសន្លឹកអាចបង្កើតឲ្យមាន«រូបភាពពិត» ឬក៏អាចធ្វើជាភស្តុតាងដែលអាចពន្យល់បាន? អ្នកស្រី សូឡូម៉ង ហ្គូដូ ជាអ្នកវាយតម្លៃរូបថតសម័យទំនើបនៅដុក(១៩៩១) បានផ្តល់យោបល់ពីហេតុផលថា ហេតុអ្វីបានជារូបថតដែលប្រហែលជាត្រូវបានគិតថាស្របនឹងអ្វីដែលបាននិយាយពី «លក្ខណៈពិសេស»: «ខុសពីរូបភាពដែលគូសដោយដៃដែលរូបភាពសម្រាប់ពណ៌នាស្ថិតនៅលើផ្ទៃក្រដាសឬផ្ទៃរូបភាពនៅក្នុងរូបថតស្ថិតនៅជាប់នឹងផ្ទៃរូបភាព ប៉ុន្តែអ្នកមិនអាចយករូបភាពចេញពីផ្ទៃរូបថតបានទេ» ។

វាពិតជាមានការរិះគន់សាលាថតរូបសម័យទំនើប ។ ការរិះគន់ជាច្រើនរបស់អ្នកទំនើបនិយមទៅលើទ្រឹស្តីនៃការថតប្រឆាំងថា រូបថតមិនបានបង្កើតជា «រឿងពិត» ដូចដែលបាដស៍ បានសង្កត់ធ្ងន់នោះទេ ប៉ុន្តែរូបថតគឺជាឯកសារសម្រាប់ពិចារណាដែលការពិតនិងតថភាពត្រូវបានបង្ហាញ និងមានកំណត់តាមវប្បធម៌ចិត្តសាស្ត្រ និងដំណើរការសង្គមនាំឲ្យរូបភាពមានទីតាំងនៅ ។ ចន ថេច អ្នកទទួលបន្ទុកខាងបង្ហាញនិយាយថា យើងមិនអាចសម្លឹងទៅលើ«មន្តអាគម»ដែលពិត យើងត្រូវតែយល់ដឹងអំពី «ដំណើរការដែលមាននិងមិនមានការអនុវត្តនិងការស្តាបនាតាមរយៈដែលរូបថតអាចធ្វើឲ្យមានការយល់ដឹង ស្គាល់ពីអត្តន័យនិងប្រសិទ្ធភាពនៃការប្រើប្រាស់» ។

ថេច បានលើកឡើងពីភាពខុសគ្នារវាង បាដស៍ និង សុនថេច ។ យោងទៅតាមការជឿនលឿនផ្នែកបច្ចេកវិទ្យានៅសតវត្សរ៍ទី២០ និង២១ ការថតរូបតាមប្រព័ន្ធឌីជីថល ហើយអាចកាត់ត និងកែតម្រូវរូបភាព ឬក៏មនុស្សនៅក្នុងរូប ដែល ថេច លើកឡើងហាក់ដូចជាត្រឹមត្រូវ ។ ប៉ុន្តែវានៅតែមានភស្តុតាងមួយចំនួន ឬក៏ការអះអាងដែលមាននៅក្នុងរូបថតដោយមិនប្រាសចាកពីការយល់ឃើញ ។ សុនថេច និយាយថា «អ្វីដែលយើងបានឮ ប៉ុន្តែមិនច្បាស់ហាក់ដូចជាពេលដែលយើងត្រូវបានបង្ហាញរូបថតឲ្យឃើញ ... រូបថតបង្កើតឲ្យមានភស្តុតាងដែលមិនអាចប្រកែកបានអំពីអ្វីដែលបានកើតឡើង ។ រូបភាពប្រហែលជាមានភាពច្របូកច្របល់ ប៉ុន្តែនៅតែមានការសន្មតអំពីអ្វីដែលកើតឡើង ឬបានកើតមានដែលស្របទៅនឹងរូបភាព» ។

ខណៈពេលនេះវាពិតចំពោះករណីដែលថាមនុស្សម្នាក់គួរតែយល់ដឹងអំពីកត្តាខាងក្រៅដែលបានបង្កើតជារូបភាពជាក់លាក់ ឬកន្លែងច្បាស់លាស់ អាចជារូបថតឬក៏ការតាំងពិព័រណ៍រូបថតដែលអាចចាប់ផ្តើមឆ្លើយតបនឹងចម្ងល់ទាំងឡាយ ទទួលស្គាល់ប្រវត្តិរឿង និងស្គាល់ពីសេចក្តីឈឺចាប់និងផ្តល់ជាភស្តុតាងដែលគាំទ្រចម្លើយផ្ទាល់មាត់របស់អ្នកដែលនៅរស់ ។ ក្នុងការផ្តល់ការពិតដែលថាការអប់រំអំពើប្រល័យពូជសាសន៍នឹងមិនអាចមាននៅសាលាក្នុងពេលអនាគតខាងមុខនេះ ការអប់រំអំពីសារមន្ទីរអាចបង្កើតបរិបទដើម្បីអប់រំសិស្សទាំងប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិ ។ នៅពេលជាមួយគ្នា សារមន្ទីរអាចបង្កើតបរិបទសង្គមនិងកន្លែងសុវត្ថិភាពដល់ជនដែលនៅរស់និងបុគ្គលដែលមិនបានឆ្លងកាត់របបខ្មែរក្រហមចូលរួមធ្វើជាសាក្សីអំពីអំពើឃោរឃៅដែលកើតមាន ។ ដូឌីត ឡឺវីស ហឺមែន នៅក្នុងការឈឺចាប់និងភាពធូរស្បើយបានដកស្រង់ថា «ដើម្បីនាំយករបួសពិតឲ្យអ្នកដទៃទទួលស្គាល់តម្រូវឲ្យមានបរិបទសង្គមដែលអះអាងបញ្ជាក់និងការពារជនរងគ្រោះនិងធ្វើឲ្យមានការចូលរួមរបស់ជនរងគ្រោះនិងសាក្សីនៅក្នុងក្រុមធម្មតា» ។ ខ្ញុំអាចនឹងបន្តអះអាងថា ឯកសារបង្ហាញនៅក្នុងការតាំងពិព័រណ៍មានអំណាចផ្តល់វេទិកាពិភាក្សាពីសង្គមដល់អ្នកដែលនៅរស់មកជួបជុំគ្នាដើម្បីចងសម័ន្ធភាពរវាងអ្នកនៅរស់ក៏ដូចជា «អ្នកក្រៅ» សម្ព័ន្ធភាពដែលអនុញ្ញាតឲ្យអ្នកដែលនៅរស់និង «អ្នកខាងក្រៅ»ដែលមកពីជំនាន់ផ្សេងគ្នាមានទីតាំងភូមិសាស្ត្រនិងប្រវត្តិវប្បធម៌ដូចគ្នាដើម្បីចែករំលែកបទពិសោធន៍ជាមួយគ្នា និងធ្វើឲ្យបទពិសោធន៍របស់គេមានការបញ្ជាក់និងត្រឹមត្រូវតាមច្បាប់ ។

**សារ៉ា ចន ឌីគីន**

# ឌិត ប្រាន : ជនរងគ្រោះនៃរបបវាលពិឃាត មរណភាពដោយជំងឺមហារីកលំពែង



ឌិត ប្រាន

លោក ឌិត ប្រាន ជាអ្នកសារព័ត៌មានកម្ពុជាមួយរូបដែលមានប្រវត្តិរឿងដ៏ឈឺចាប់និងការរត់គេចចេញពីបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧៩ បានមរណកាលនៅថ្ងៃអាទិត្យ ទី៣០ ខែមីនា ឆ្នាំ ២០០៨ ក្នុងអាយុ៦៥ឆ្នាំ ដោយជំងឺមហារីកលំពែងនៅមន្ទីរពេទ្យញូវជឺស៊ី សហរដ្ឋអាមេរិក ។ រឿងរ៉ាវដ៏ជូរចត់របស់ ប្រាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចងក្រងជាខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា «របបវាលពិឃាត» ។ ខ្សែភាពយន្តនេះត្រូវបានចាក់ផ្សាយដើម្បីប្រាប់ពិភពលោកឲ្យដឹងពីអំពើដ៏ឃោរឃៅរបស់ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ ។

ឌិត ប្រាន កើតនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៤៥ នៅក្នុងខេត្តសៀមរាប ។ ប្រាន បានទទួលការសិក្សាភាសាអង់គ្លេសនិងភាសាបារាំង ហើយបម្រើការជាអ្នកបកប្រែភាសាឲ្យមន្ត្រីអាមេរិកនៅក្នុងទីក្រុងភ្នំពេញ ។

បន្ទាប់ប្រមុខដឹកនាំកម្ពុជា សម្តេចព្រះនរោត្តម សីហនុ ផ្តាច់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៥ ប្រាន ធ្វើការងារនៅកន្លែងផ្សេងទៀត ។ នៅពេលរដ្ឋប្រហារទម្លាក់សម្តេច សីហនុ កងទ័ពកម្ពុជាបានបន្តសង្គ្រាមជាមួយកងទ័ពខ្មែរក្រហម ។

ក្នុងឆ្នាំ១៩៧២ ប្រាន និង ស្កែនប៊ើក គឺជាអ្នកសារព័ត៌មានដំបូងបង្អស់ដែលបានរកឃើញភាពមហន្តរាយមួយដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅអ្នកលឿងជាតំបន់ទន្លេឆ្លងកាត់ដ៏សំខាន់ដែលតភ្ជាប់ផ្លូវពីទីក្រុងភ្នំពេញទៅភាគខាងកើតនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រាន បានរំឭកនៅក្នុងអត្ថបទមួយដែលចុះផ្សាយនៅឆ្នាំ២០០៣ អ្វីដូចដែលគាត់បានឃើញយន្តហោះសហរដ្ឋអាមេរិកកំពុងវាយប្រហារមកលើសត្រូវថា «ប្រសិនបើអ្នកមិនគិតអំពីគ្រោះថ្នាក់របស់វាទេ មើលទៅហាក់ដូចជាការសម្តែងមួយ ។ វាប្រៀបដូចជាកាំជ្រួចដ៏ស្រស់ស្អាត ។ សង្គ្រាមមានភាពរំភើបតក់ស្លុតប្រសិនបើអ្នកមិនស្លាប់ទេនោះ ។ ដោយសារតែអ្នកដឹងថាវាសម្លាប់មនុស្សនោះវានឹងលែងល្អរំភើបតក់ស្លុតទៀតហើយ» ។

ឌិត ប្រាន បានក្លាយជាអ្នកបកប្រែនិងជាជំនួយការរបស់ ស្កែនប៊ើក នៅភ្នំពេញដែលជារាជធានីភ្នំពេញនៅខណៈពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ។



នៅក្នុងដំណាក់កាលនោះ ស្កែនប៊ើក បានជួយក្រុមគ្រួសាររបស់ ប្រាន ឲ្យចាកចេញផុតពីប្រទេស ប៉ុន្តែគាត់ត្រូវបង្ខំចិត្តទុកមិត្តភក្តិរបស់គាត់ (ប្រាន) ឲ្យនៅក្នុងប្រទេសបន្ទាប់ពីរាជធានីត្រូវបានដួលរំលំ ។

បន្ទាប់ពីកងកម្លាំងវៀតណាមចូលមកដល់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៩ ឌិត ប្រាន បានភៀសខ្លួនចេញពីឃុំមួយក្បែរខេត្តសៀមរាបក្នុងដំណើរដ៏សែនលំបាក ដែលមានចម្ងាយប្រហែល៤០ គីឡូម៉ែត្រដើម្បីគេចចេញពីកងកម្លាំងវៀតណាមនិងកងទ័ពខ្មែរក្រហមដើម្បីឆ្ពោះទៅកាន់ជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ ។ (តទៅទំព័រ៤៥)

00172269

A104/II/4

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

**សំណុំរឿងព្រហ្មទណ្ឌលេខៈ ០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៥)**

**ចំពោះមុខ** ចៅក្រម ប្រាក់ គឹមសាន , ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka RAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNKUHET

**កាលបរិច្ឆេទ** ២១ មីនា ២០០៨

---

**សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អំពីសិទ្ធិចូលជួប**

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 03 / 2008
ម៉ោង (Time/Heure): 10:45'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNKUHET

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michiel G. KARNAVAS

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥) -២៣-២១៩-៨១៤ ទូរសារ: (៨៥៥) -២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00172270

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៥)

A104/II/4

១. **អង្គបុរេជំនុំជំរះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (អ.វ.ត.ក) បានទទួលបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០៨ ដែលបានដាក់ដោយសហមេធាវីជនត្រូវចោទ ប្រឆាំងនឹងលិខិតរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨។

២. តាមរយៈលិខិតនេះ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបនឹងលិខិតរបស់សហមេធាវី ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០០៧ ដែលស្នើសុំការអនុញ្ញាតអោយជនត្រូវចោទជួបជាមួយប្រពន្ធរបស់គាត់ (ជនជាប់ឃុំ អៀង ធីរិទ្ធ) ។

៣. នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់ដល់សហមេធាវីអោយដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ និងអនុញ្ញាតអោយសហព្រះរាជអាជ្ញាអោយដាក់សេចក្តីសន្និដ្ឋានតប។

៤. សហមេធាវីបានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួននៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ ហើយសហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបរបស់ខ្លួននៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៨។

៥. នៅក្នុងលិខិតចុះនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៨ របស់សហចៅក្រមស៊ើបអង្កេត ដែលជនត្រូវចោទបានធ្វើឧទ្ធរណ៍ បានបញ្ជាក់ថា៖

*ឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ទាក់ទងនឹងសំណើសុំការ អនុញ្ញាតអោយ អៀង សារី ចូលសួរសុខទុក្ខ អៀង ធីរិទ្ធ យើងសូមជំរាបថា ដោយសារតែការស៊ើបអង្កេត សំណុំរឿងលេខ ០២/១៩-០៩-២០០៧-អវតក-កសចស នៅកំពុងតែបន្ត យើងមិនមានផែនការផ្លាស់ប្តូរលក្ខខណ្ឌនៃការចូលសួរសុខទុក្ខ ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះទេ។ ដូច្នេះហើយ ជំនួបរវាង អៀង ធីរិទ្ធ និងកូនក្តីរបស់លោក មិនអាចធ្វើទៅបានទេនាពេលបច្ចុប្បន្ន។*

៦. ដោយផ្អែកលើសេចក្តីសន្និដ្ឋានសហមេធាវី និងចម្លើយតបរបស់សហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសំរេចនៅក្នុងលិខិតរបស់សហចៅក្រមស៊ើបអង្កេត តាមអនុភាពរបស់វា ទំនងជាដីកាបង្គាប់អោយដាក់នៅដាច់ដោយឡែកពីគ្នា។

៧. អង្គបុរេជំនុំជម្រះបានកត់សំគាល់នូវបញ្ញត្តិមួយចំនួនដែលមានចែងក្នុង៖

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.T.C.

សេចក្តីសំរេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ 2/4

00172271

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៥)

A104/II/4

- វិធាន៣ នៃសេចក្តីព្រាង បទបញ្ជាស្តីពីការគ្រប់គ្រងពន្ធនាគារដើម្បីរង់ចាំសំរាប់ការកាត់សេចក្តី ឬ បណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ ការឃុំខ្លួនដោយអំណាចនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- នីតិវិធីនៃមន្ទីរឃុំឃាំង លេខ ៣ ស្តីពីការដាក់នៅអោយដាច់ពីគ្នានៃទណ្ឌិត ដែលបានប្រកាសអោយ ប្រើ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៣)
- មាត្រា ៣ និង៧ នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ លេខ ២១៧ ប្រ.ក, ចុះថ្ងៃទី៣១ មីនា ១៩៩៨
- វិធាន៥៧ វិធាននៃបទដ្ឋានអប្បបរមា សំរាប់ការថែទាំទណ្ឌិត[1]
- មាត្រា៧ គោលការណ៍ជាមូលដ្ឋានក្នុងការថែទាំងទណ្ឌិត[2] , និង
- នីតិវិធីក្នុងការបំបែក និងការដាក់នៅអោយដាច់ពីគ្នាដោយបង្ខំ នៅតុលាការអន្តរជាតិមួយចំនួន។

៨. អង្គបុរេជំនុំជម្រះក៏បានយល់ឃើញថា វិធាន ២១(២) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក ចែងថា៖

*វិធានការចាប់បង្ខំទាំងឡាយចំពោះបុគ្គលណាម្នាក់ត្រូវធ្វើឡើងដោយ ឬស្ថិតនៅក្រោមការត្រួតពិនិត្យដោយ យកចិត្តទុកដាក់អំពីអាជ្ញាធរមានសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ។វិធានការនេះត្រូវតែកម្រិតត តឹងរ៉ឹងបំផុត សំរាប់តែតម្រូវការនៃដំណើរការនីតិវិធី ដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើសដែលចោទប្រកាន់ និង ដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិអោយបានពេញលេញ។*

៩. អង្គបុរេជំនុំជម្រះយល់ថា អំណះអំណាងរបស់សហមេធាវី អាចត្រូវបានគេមើលឃើញថា ជាការតវ៉ាប្រឆាំង នឹងវិធានដ៏តឹងរឹងធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលមិនបានគោរពដល់សេចក្តីថ្លៃថ្នូរពេញលេញ របស់ ជនត្រូវចោទ។

១០. ទាក់ទងនឹងសិទ្ធិក្នុងការគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការលើកយកមកពិចារណានូវកាតព្វកិច្ច ដូចដែលបានបញ្ញត្តនៅក្នុងវិធាន ២១(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍ គឺស្ថិត ក្រោមការអនុវត្តនៃវិធាន ៧៤(៣)(ច) នៃវិធានផ្ទៃក្នុង។

១១. ដោយការពិចារណាទៅលើលក្ខខណ្ឌសុខភាពរបស់ជនត្រូវចោទ ដូចដែលបានអះអាងដោយសហមេធាវី និងការបញ្ជាក់ដោយសហព្រះរាជអាជ្ញា ពេលវេលាក្នុងការដាក់សេចក្តីសន្និដ្ឋានត្រូវបានកំណត់ក្នុងរយៈពេលចំនួន ៥ថ្ងៃ ទោះបីមានការស្នើសុំលើសពីនេះក៏ដោយ។ ភាគីទាំងឡាយត្រូវដាក់សេចក្តីសន្និដ្ឋានរបស់ពួកគេជាភាសាខ្មែរ និងជាភាសា ផ្លូវការមួយទៀតរបស់តុលាការ។

[1] Approved by the Economic and Social Council by its resolutions 663 C(XXIV) of 31 July 1957 and 2076 (LXXII) of 13 May 1977.
[2] GA Res A/RES45/111, 20 December 1990.

00172272

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៥)

A 104/II/4

**ដូច្នេះអង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

១. ទទួលយកបណ្តឹងឧទ្ធរណ៍ ។

២. សហមេធាវីរបស់ជនត្រូវចោទ អាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ទៅលើបញ្ហានៃបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេល៥ថ្ងៃ ។

៣. សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់សេចក្តីសន្និដ្ឋានតបក្នុងរយៈពេល ៥ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងនៃការទទួលបាននូវសេចក្តីសន្និដ្ឋានរបស់សហមេធាវីជនត្រូវចោទ ជាភាសាផ្លូវការរបស់ អ.វ.ត.ក ដែលភាគីបានដាក់ដោយអនុលោមតាម មាត្រា ២.២ នៃសេចក្តីណែនាំការអនុវត្ត នៅចំពោះមុខ អ.វ.ត.ក។ ៕

ភ្នំពេញ, ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING | នំយ ថុល | Katinka LAHUIS | ហួត វុធី | ប្រាក់ គឹមសាន

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា

ព័ត៌មាន និងគំនិតយោបល់ផ្សេងៗពីបណ្តាជនរងគ្រោះ និងអង្គការសង្គមស៊ីវិលនានា បានធ្វើឲ្យមានការដាក់ជូននូវសេចក្តីសន្និដ្ឋានបន្ថែម ធ្វើឡើងដោយសហព្រះរាជអាជ្ញានៃ អ.វ.ត.ក ដោយអំពាវនាវឲ្យមានការស៊ើបសួរថ្មីៗទៅលើបទឧក្រិដ្ឋនៃរបបខ្មែរក្រហមបន្ថែមទៀត ។ សហព្រះរាជអាជ្ញានៃ អ.វ.ត.ក បានស្នើកាលពីថ្ងៃពុធថា សហចៅក្រមស៊ើបអង្កេត បើកការស៊ើបសួរទៅលើការចោទប្រកាន់នៃបទឧក្រិដ្ឋនានា ដែលបានប្រព្រឹត្ត នៅឯមណ្ឌលសន្តិសុខមួយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាទីកន្លែងដែលមានពលរដ្ឋកម្ពុជាជាច្រើននាក់ត្រូវបានគេឃុំខ្លួនដោយខុសច្បាប់ ទទួលរងនូវស្ថានភាពអមនុស្សធម៌ និងការងារដោយបង្ខំ អំពើទារុណកម្ម និងការកាប់សម្លាប់ នៅរវាងចន្លោះ ឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។ “ការចោទប្រកាន់ជាក់ស្តែងទាំងនេះ ប្រសិនបើរកឃើញ អាចនឹងរួមបង្កើតបានជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវផ្តន្ទាទោសនៅក្រោមច្បាប់ អ.វ.ត.ក ហើយយើងក៏បានធ្វើការចោទប្រកាន់ដូច្នេះរួចហើយដែរនៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង” នេះបើតាមប្រសាសន៍របស់សហព្រះរាជអាជ្ញា លោក Robert PETIT ។

សហព្រះរាជអាជ្ញា បានស្នើបន្ថែមទៀតថា ជនត្រូវចោទ **នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ** និង **កាំង ហ្កេចអ៊ាវ** ដែលក្នុងពេលបច្ចុប្បន្ន អ្នកទាំងនេះបាននឹងកំពុងស្ថិតនៅក្រោមការឃុំខ្លួនរបស់ អ.វ.ត.ក ត្រូវមានការស៊ើបសួរអំពីការចូលរួមពាក់ព័ន្ធរបស់ពួកគេនៅក្នុងបទឧក្រិដ្ឋទាំងនេះ ។ មិនមានជនសង្ស័យបន្ថែមទៀតឡើយដែលត្រូវបានកំណត់នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែម ។ លោក Petit បានមានប្រសាសន៍ថា “សេចក្តីសន្និដ្ឋាននេះ បន្ថែមពីលើសំណើពីលើកមុនដែលបានស្នើឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបសួរទៅលើស្ថានភាពពិតប្រាកដចំនួន ២៥ មានចរិតស្រដៀងៗគ្នា ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ” ។ សំណើពីដំបូងនោះ គឺជា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញា ត្រូវបានបញ្ជូនកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។

សំណើនេះ បានដាក់អមទៅជាមួយនូវឯកសារគាំទ្រជាង៣០ ដែលរួមបញ្ចូលគ្នាមានប្រហែល ១,៥០០ទំព័រនៃរបាយការណ៍វិភាគ កំណត់ហេតុនៃបទសម្ភាសន៍សាក្សី និងឯកសារផ្សេងៗទៀត នៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ភាគច្រើននៃភស្តុតាងទាំងនេះ បានប្រមូលដោយមានជំនួយពី មជ្ឈមណ្ឌល

ឯកសារកម្ពុជា ។ “ជាសំខាន់ សំណើនេះត្រូវបានបញ្ជូនដោយសារមានការផ្តល់ព័ត៌មានដោយផ្ទាល់របស់ជនរងគ្រោះមកឲ្យតុលាការ តាមរយៈជំនួយរបស់អង្គការ អាដហុក (ADHOC) ដែលជាអង្គការសិទ្ធិមនុស្សមួយនៅកម្ពុជា” នេះបើតាមប្រសាសន៍របស់លោកស្រី **ជា លាង** ។ “តាមរយៈចរិតដ៏ពិស្តារ និងទម្រង់បែបបទផ្តល់ព័ត៌មានដ៏ច្បាស់លាស់ យើងមានលទ្ធភាពវាយតម្លៃ និងធ្វើសកម្មភាពទៅលើព័តមាននេះ បានយ៉ាងឆាប់រហ័ស” ។ លោកបានមានប្រសាសន៍ទៀតថា សហព្រះរាជអាជ្ញាបានបន្តលើកទឹកចិត្តដល់ជនរងគ្រោះឲ្យចូលរួមជាបន្តទៅទៀត ។

ក្នុងខណៈដែលមិនមែនបទឧក្រិដ្ឋ ឬ ឧក្រដ្ឋិជនទាំងអស់សុទ្ធតែនឹងត្រូវបានចោទប្រកាន់ និងដោយសារតែចរិតភាពមានកំហិតរបស់ អ.វ.ត.ក លោកស្រី **ជា លាង** បានធានាចំពោះជនរងគ្រោះថា រាល់ពាក្យបណ្តឹងទាំងអស់នឹងត្រូវបានពិនិត្យ និងវាយតម្លៃសំរាប់ភស្តុតាងគាំទ្រសំខាន់ៗ ។ “បើគ្មានការចូលរួមរបស់ជនរងគ្រោះ និងសាក្សីទេ លទ្ធភាពរបស់តុលាការដើម្បីស្វែងរកការពិត ទាក់ទិនវិសាលភាពនៃបទឧក្រិដ្ឋ និងបុគ្គលដែលមានការទទួលខុសត្រូវ នឹងត្រូវកាត់បន្ថយយ៉ាងសំខាន់ជាមិនខាន” ។

## ***លិខិតពីមិត្តអ្នកអាន***

***សូមគោរពលោកនាយកមជ្ឈមណ្ឌលឯកសារស្វែងរកការពិតពីចម្ងាយ!***

*ខ្ញុំបាទមានកិត្តិយសសូមប្រកាសជូនដំណឹងអំពីការស្រាវជ្រាវរកជនរងគ្រោះ!*

*នៅសម័យខ្មែរក្រហម ខ្ញុំរស់នៅភូមិតាឥន្ទ (បច្ចុប្បន្នហៅភូមិត្រពាំងវែងខាងលិច) ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត ។ កាលនោះខ្ញុំនៅកុមារតូចនៅឡើយ ។ ថ្ងៃមួយខ្ញុំបានជួបបុរសម្នាក់មាឌក្រអាញសាច់ដុំធំៗ សម្បុរស្រអែម គាត់ឈ្មោះ ឡុង អានជាអ្នកប្រដាល់កាលពីសង្គមចាស់ ។ ពេលខ្ញុំបានជួបនិងឃើញគាត់ អ្នកស្រុកខ្ញុំបានសុំឲ្យគាត់សាកបញ្ចេញក្បាច់ប្រដាល់មើល គាត់ក៏បានធ្វើឲ្យមើលដូចជាក្បាច់ចាប់ទាត់ធាក់យ៉ាងស្ទាត់ជំនាញគួរឲ្យចង់មើលនិងស្ញើចសរសើរពីវិជ្ជារបស់គាត់ ។ គាត់ជាប្រជាជនថ្មីមិនដឹងគាត់ជម្លៀសមកពីភូមិឃុំស្រុកខេត្តណាទេ មកនៅភូមិតារាជ្យជាប់នឹងភូមិរបស់ខ្ញុំ ។ ក្រោយមកខ្ញុំបានសាកសួររកឈ្មោះគាត់អ្នកភូមិបានប្រាប់ខ្ញុំថា គាត់ត្រូវគេយកទៅសម្លាប់បាត់ហើយ តែខ្ញុំមិនបានសួរថាតើគេយកគាត់ទៅសម្លាប់នៅកន្លែងណាទេ ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែនឹកឃើញគាត់និងសែនស្រណោះអំពីជីវិតរបស់គាត់ក៏ដូចបងប្អូនពូមីងខ្ញុំនិងជនរួមជាតិដែលទទួលរងគ្រោះត្រូវឃ្លបសម្លាប់ដូចសត្វធាតុ ។*

*ព័ត៌មានដែលខ្ញុំបានដឹងខាងលើចាត់ទុកជាការជូនដំណឹងដល់បងប្អូន សាច់ញាតិ ឪពុកម្តាយរបស់គាត់បានជ្រាបនឹងដឹងព្ទខះៗតែប៉ុណ្ណោះ ។ ប្រសិនបើបងប្អូនមិនទាន់បានដំណឹងនេះ ហើយចង់ដឹងព័ត៌មានលម្អិតសូមអញ្ជើញទៅជួបអ្នកភូមិខាងលើប្រហែលនឹងបានដំណឹងបន្ថែមទៀតជាពុំខាន ។*

*សូមអរគុណក្នុងការចុះផ្សាយនូវដំណឹងនេះទុកជាប្រយោជន៍ដល់គ្រួសារទៅតាមផ្លូវធម៌ ឬជាប្រវត្តិសាស្ត្រផងដែរ ។*

**គុនរ៉ា**

# អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា នៅក្នុងបញ្ហានៃការធ្វើបណ្តឹងឧទ្ធរណ៍ដោយ នួន ជា ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ស្តីអំពីបញ្ហានៃការចូលរួមដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន

## សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស អបជ០១

### I. *អ្នកផ្តល់សារណា*

*អ៊ែន ហាញ់ឌល ជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ អ៊ែន ហាញ់ឌល ធ្លាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អស់រយៈពេលជាង១០ឆ្នាំ និងជាសមាជិកគណៈមេធាវីនៅរដ្ឋកាលីហ្វញ៉ា នៃសហរដ្ឋអាមេរិក ។ យោបល់ដែលបញ្ចេញនៅក្នុងសារណានេះគឺជាយោបល់ផ្ទាល់ខ្លួន និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ សារ៉ា ថមម៉ាស (David W. Leebron International Human Rights Fellow) នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ បានចូលរួមចំណែកក្នុងការរៀបចំសារណានេះ ។*

### II. *សេចក្តីសង្ខេបអំណះអំណាង*

*សារណានេះត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងជាសាធារណៈរបស់អង្គបុរេជំនុំជម្រះនៃ(អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ដែលអនុញ្ញាតឲ្យមានការផ្តល់សារណាដោយអ្នកមិនមែនជាភាគីនៃរឿងក្តីដើម្បីដោះស្រាយបញ្ហាតុល្យភាពរវាងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទនិងសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបរិបទនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។*

*ជនរងគ្រោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានអនុញ្ញាតឲ្យចូលរួមជាភាគីពេញលេញនៅក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញ និងមានផលប្រយោជន៍ក្នុងការចូលរួមនៅក្នុងសវនាការផ្សេងៗមុនពេលជំនុំជម្រះពិតប្រាកដ ។ តួនាទីរបស់ជនរងគ្រោះទាំងនេះគឺខុសគ្នាខ្លះទៅនឹងតួនាទីរបស់ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិនេះ ជនរងគ្រោះមិនមានសិទ្ធិចូលរួមពេញលេញទេ ប៉ុន្តែជនរងគ្រោះត្រូវដាក់ដាក់ពាក្យសុំចូលរួមនៅក្នុងដំណាក់កាលផ្សេងៗនៃដំណើរការជំនុំជម្រះដោយត្រូវចង្អុលបង្ហាញថាតើផលប្រយោជន៍ផ្ទាល់ខ្លួននឹងត្រូវប៉ះពាល់យ៉ាងដូចម្តេច ។ អង្គជំនុំជម្រះវិសាមញ្ញមិនគួរអនុវត្តតាមតុលាការព្រហ្មទណ្ឌអន្តរជាតិបែបនេះទេ ។ មិនមានការឯកសារណាមួយដែលតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញដាក់ពាក្យស្នើសុំជាថ្មីម្តងទៀតដើម្បីចូលរួមនៅក្នុងដំណាក់កាលផ្សេងៗនៃសវនាការទេ ។ វិធីដែលប្រើប្រាស់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិគឺចំណាយពេលវេលាច្រើន និងតម្រូវឲ្យមានចំណាយធនធានច្រើន ដោយតុលាការ ដោយភាគី និងអ្នកចូលរួមដែលជាជនរងគ្រោះ ។ ជាងនេះទៅទៀត ភាសាប្រើប្រាស់នៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានគាំទ្រនូវគំនិតថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមនៅគ្រប់បណ្តឹងជំទាស់របស់អង្គបុរេជំនុំជម្រះដែលរួមមានទាំងបណ្តឹងជំទាស់ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន*

ផងដែរ ។ ចុងក្រោយបំផុត វិធានផ្ទៃក្នុងបានចែងយ៉ាងច្បាស់ថា ផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះមិនមែនកំណត់ឲ្យនៅត្រឹមតែទទួលសំណងជំងឺចិត្តនោះទេ ប៉ុន្តែថែមទាំងមានការគាំទ្រខាងព្រះរាជអាជ្ញានៅក្នុងដំណាក់កាលស៊ើបអង្កេតផង ។ ដោយសារមូលហេតុទាំងនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរតែត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងបណ្តឹងជំទាស់ទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ។

ទោះជាយ៉ាងណាក៏ដោយ ការចូលរួមដោយជនរងគ្រោះនៅក្នុងការជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញ ជានិច្ចកាលគួរតែថ្លឹងថ្លែងទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះយុត្តិធម៌ ។ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានចែងអំពីមធ្យោបាយមួយចំនួនដើម្បីថែរក្សាឲ្យមាននូវតុល្យ-ភាពនេះ ។ ទីមួយ និយមន័យអំពីភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានកម្រិតការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមកត្រឹមតែជនរងគ្រោះដែលទទួលរងព្យសនកម្មដែល«ជាលទ្ធផលដោយផ្ទាល់ពីឧក្រិដ្ឋកម្មជាព្យសនកម្មដោយផ្ទាល់ ហើយព្យសនកម្មនោះបានកើតឡើងពិតប្រាកដមកដល់បច្ចុប្បន្ន» ។ បន្ទាប់ពីមានការអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ សហចៅក្រមស៊ើបអង្កេតគួរតែបញ្ជាក់ឲ្យច្បាស់ពីលក្ខណៈសម្បត្តិនេះនិងពន្យល់អំពីរបៀបដែលអ្នកទាំងនោះ បានយកមកប្រើប្រាស់ទាក់ទងនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូបដែលត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងសំណុំរឿង នួន ជា ។ ទីពីរ អង្គបុរេជំនុំជម្រះគួរតែអនុវត្តឲ្យតឹងតែងក្នុងការតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការជាមុននូវអំណះអំណាងនៃសវនាការណាមួយដែលពួកគេចង់ចូលរួមដើម្បីចៀសវាងកុំឲ្យមានការភ្ញាក់ផ្អើលដែលបង្កជាឥទ្ធិពលមិនល្អ ។ ទីបី អង្គបុរេជំនុំជម្រះគួរតែកំណត់អន្តរាគមន៍ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីឲ្យផ្តោតតែទៅលើបញ្ហាជាក់លាក់ដែលមានលើកឡើងនៅក្នុងបណ្តឹងជំទាស់ ។ ចុងបញ្ចប់ អង្គបុរេជំនុំជម្រះគួរតែជំរុញ និងនៅពេលដែលចាំបាច់តម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមានផលប្រយោជន៍ស្រដៀងគ្នាចូលជាក្រុម និងបញ្ចេញការយល់ឃើញរបស់ខ្លួនតាមរយៈអ្នកតំណាងរួមគ្នា ដើម្បីចៀសវាងការពន្យារពេល និងការលើកឡើងដដែលៗនៅក្នុងពេលសវនាការ ។

## III. **អំណះអំណាង**

ក) វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ជាក់លាក់នៅក្នុងសំណុំរឿងដែលពួកគេចូលរួម

១) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យជនរងគ្រោះទាំងអស់ដែលទទួលរងនូវព្យសនកម្មដោយសារឧក្រិដ្ឋកម្មមួយស្ថិតក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញដើម្បីអនុវត្តសិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណីនៅពេលដែលព្យសនកម្មរបស់ពួកគេគឺ«ផ្ទាល់ខ្លួន សម្ភារៈ ឬផ្លូវចិត្ត» និងជា «ផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្ម ជាព្យសនកម្មដោយផ្ទាល់ ហើយព្យសនកម្មនោះបានកើតឡើងពិតប្រាកដមកដល់បច្ចុប្បន្ន» ។ នៅក្នុងសវនាការ បណ្តឹងជំទាស់ដីកាឃុំខ្លួនរបស់លោកនួន ពាក្យសុំតាំងខ្លួនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤ត្រូវសហចៅក្រមស៊ើបអង្កេតយល់ព្រម ។ ប៉ុន្តែមិនមានសេចក្តីសម្រេចណាមួយធ្វើឡើងជាសាធារណៈពន្យល់អំពីរបៀបបកស្រាយលក្ខណៈសម្បត្តិ [ជ្រើសរើសភាគីដើមបណ្តឹងរដ្ឋប្បវេណី]នៅពេលធ្វើការវាយតម្លៃពាក្យសុំតាំងខ្លួនធ្វើជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬ ពន្យល់ពីហេតុផលដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីបំពេញបានតាមលក្ខណៈសម្បត្តិនោះទេ ។

២) ផ្ទុយទៅវិញ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលជាសាលាជំនុំជម្រះក្តីអន្តរជាតិតែមួយគត់មានចែងពីការចូលរួមដោយជនរងគ្រោះ មានសេចក្តីសម្រេចជាសាធារណៈមួយចំនួនទាក់ទងនឹងការផ្តល់និយមន័យអំពី«ជនរងគ្រោះ» ។ វិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងថា ទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលអាចត្រូវបានទទួលស្គាល់ថាជាជនរងគ្រោះ ។ រូបវន្តបុគ្គលត្រូវបានផ្តល់និយមន័យថាជាជនរងគ្រោះ នៅពេលដែលពួកគេជា«មនុស្សពីធម្មជាតិដែលទទួលរងនូវព្យសនកម្ម ដោយសារការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ[ព្រហ្មទណ្ឌអន្តរជាតិ]» ។ ផ្ទុយទៅវិញ នីតិបុគ្គលក៏អាចជាជនរងគ្រោះបានដែរ តែក្នុងករណីដែលបុគ្គលនោះទទួលរងនូវ

«ព្យសនកម្មដោយផ្ទាល់» ។ «ការប្រើប្រាស់ការបកស្រាយណាមួយ» ទៅនឹងបញ្ញត្តិទាំងនេះ អង្គជំនុំជម្រះនៃសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានកំណត់ថា «មនុស្សអាចជាជនរងគ្រោះដោយផ្ទាល់ ឬដោយប្រយោលនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ» ។

៣) ទាំងអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះនៃសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានធ្វើការវិភាគលក្ខខណ្ឌនៃវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិថា ជនរងគ្រោះត្រូវតែទទួលរងនូវព្យសនកម្ម«ដែលជាលទ្ធផលនៃការប្រព្រឹត្តឧក្រិដ្ឋ-កម្មទាំងឡាយដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ» ។ អង្គបុរេជំនុំជម្រះបានរកឃើញថា ភាសានេះតម្រូវឲ្យមានទំនាក់ទំនងដែលបង្កជាដើមហេតុ រវាងព្យសនកម្មដែលទទួលរងគ្រោះដោយជនរងគ្រោះ និងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ។ ប៉ុន្តែថ្មីៗនេះ អង្គជំនុំជម្រះនៃសាលាដំបូងបានបកស្រាយលក្ខខណ្ឌនេះទូលាយជាងមុន និងបានរកឃើញថា «ជនរងគ្រោះនៃឧក្រិដ្ឋកម្មណាមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការអាចចូលរួមយ៉ាងសកម្ម» ប្រសិនបើគេអាចបង្ហាញទំនាក់ទំនងជាភស្តុតាងរវាងជនរងគ្រោះនិងភស្តុតាងដែលតុលាការនឹងយកមកពិចារណាឬផលប្រយោជន៍ផ្ទាល់របស់ជនរងគ្រោះ «គឺពិតជាមានទំនាក់ទំនងនឹងបញ្ហាមួយដែលនឹងកើតឡើងនៅក្នុងដំណើរការជំនុំជម្រះ» ។

៤) ការវិភាគភាសាសរសេរនៅក្នុងវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញថា ភាគីរដ្ឋប្បវេណីត្រូវតែទទួលរងគ្រោះព្យសនកម្ម«ដោយផ្ទាល់» «ផ្ទាល់ខ្លួន» និង«ពិតប្រាកដ» ។ ប៉ុន្តែតាមការអនុវត្ត តើពាក្យទាំងអស់នេះមានន័យយ៉ាងណានោះគឺមិនទាន់ច្បាស់លាស់ទាំងស្រុងទេ ជាពិសេស នៅពេលប្រើប្រាស់ទៅលើសមាជិកក្រុមគ្រួសាររបស់ជនរងគ្រោះ ។ វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក៏មិនច្បាស់លាស់ដែរ ទាក់ទងនឹងទំនាក់ទំនងពិសេសរវាងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនិងព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ ។ ភាសានៅក្នុងសេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមដោយជនរងគ្រោះ *(Practice Direction on Victim Participation)* ដែលចែងថា «ជនរងគ្រោះនៃឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញអាចចូលរួមសវនាការក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងមួយដែលទាក់ទងនឹងបទឧក្រិដ្ឋកម្មនោះ» បានបង្ហាញថា អ្នកដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញទំនាក់ទំនងជាដើមហេតុរវាងបទចោទប្រកាន់និងព្យសនកម្មដែលទទួលរងគ្រោះពីបទឧក្រិដ្ឋដែលចោទប្រកាន់នោះ ។

៥) ដោយសារសហចៅក្រមស៊ើបអង្កេតមិនទាន់បានបញ្ចេញសេចក្តីសម្រេចចិត្តដែលវិភាគទាក់ទងនឹងប្រភេទព្យសនកម្មអ្វីដែលត្រូវតែបង្ហាញដើម្បីអាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងជាក់លាក់ណាមួយនោះ វាមិនទាន់ច្បាស់លាស់នៅឡើយទេថាតើសហចៅក្រមស៊ើបអង្កេតធ្វើការបកស្រាយលក្ខណៈសម្បត្តិដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងវិធានផ្ទៃក្នុងបានទូលាយ ឬចង្អៀតយ៉ាងណា ។ សិទ្ធិទទួលបានការជំនុំជម្រះយុត្តិធម៌របស់លោក នួន អាចត្រូវបានរំលោភបំពាន ប្រសិនបើគាត់មិនបានទទួលការពន្យល់អំពីមូលដ្ឋាននៃផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ ។ និយមន័យ ច្បាស់លាស់ជាក់លាក់នៃដើមបណ្តឹងរដ្ឋប្បវេណីគឺជាជំហានទីមួយយ៉ាងសំខាន់ក្នុងការថ្លឹងថ្លែងសិទ្ធិចូលរួមរបស់ជនរងគ្រោះ និងសិទ្ធិទទួលបានការជំនុំជម្រះយុត្តិធម៌និងមិនលម្អៀង ។ ដូចដែលបានលើកឡើងដោយចៅក្រមម្នាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិៈ

វាមានសារសំខាន់ណាស់ក្នុងការចងចាំថា ជនរងគ្រោះមិនមែនជានីតិបុគ្គលដែលមិនមានរូបរាងនោះទេ ប៉ុន្តែជារូបវន្តបុគ្គលមានរូបរាង ឬជាក្រុមបុគ្គលដែលបានទទួលរងនូវព្យសនកម្មនៅក្នុងករណី ឬស្ថានភាពណាមួយ ហើយសិទ្ធិរបស់ជននោះត្រូវតែការពារ ។ មធ្យោបាយល្អបំផុតក្នុងការការពារសិទ្ធិទាំងនោះគឺធានាថា ជាចំណុចចាប់ផ្តើមសមហេតុផលមួយនោះ យើងបានឲ្យនិយមន័យយ៉ាងច្បាស់លាស់ តើនរណាដែលអាចទទួលបានងារជាជនរងគ្រោះ ។ មានតែតាមរយៈមូលដ្ឋាននោះទេទើបអាចគ្រប់គ្រងសិទ្ធិចូលរួមរបស់ជនរងគ្រោះបាន ។

### ១) ភាគីដើមបណ្តឹងរដ្ឋប្បវេណីអង្គជំនុំជម្រះវិសាមញ្ញមានផលប្រយោជន៍ក្នុងការចូលរួមនៅក្នុងបណ្តឹងជំទាស់នឹងដីកាឃុំខ្លួន

១. ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនគួរតម្រូវឲ្យដាក់ពាក្យសុំចូលរួមជាច្រើនលើកច្រើនសានៅក្នុងសវនាការបណ្តឹងជំទាស់ដីកាឃុំខ្លួន

៦) នៅពេលដែលជនរងគ្រោះត្រូវបានរកឃើញថាបានបំពេញតាមលក្ខណៈសម្បត្តិរបស់វិធានផ្ទៃក្នុងអាចចូលរួមនៅក្នុងសំណុំរឿងជាដើមបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះនោះ«បានក្លាយទៅជាភាគីមួយនៃសវនាការព្រហ្មទណ្ឌ»ដែលមានសិទ្ធិស្រដៀងគ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទដែរ ដែលរួមទាំងសិទ្ធិយ៉ាងទូលំទូលាយចូលរួមនៅក្នុងដំណាក់កាលស៊ើបអង្កេត ក៏ដូចជានៅក្នុងដំណាក់កាលក្រោយៗមក ទៀតនៃការជំនុំជម្រះ ។ បើធ្វើការប្រៀបធៀបនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះមិនត្រូវបានចាត់ទុកជាភាគី«ពិតប្រាកដ»ទេ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យបញ្ចេញ«ការយល់ឃើញ និងការព្រួយបារម្ភ…ត្រឹមតែនៅក្នុងដំណាក់កាលនៃសវនាការដែលតុលាការសម្រេចថាសមរម្យ» នៅពេលដែល«ផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវទទួលរងប៉ះពាល់» ។ ដូចដែលបានលើកឡើងដោយចៅក្រមអង្គជំនុំជម្រះនៃសាលាកំពូលម្នាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិៈ

*សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមដូចដែលបានចែងនៅក្នុងមាត្រា៦៨(៣) [នៃលក្ខន្តិកៈក្រុងរ៉ូម] មិនមានអ្វីល្អជាងឬអាក្រក់ជាង ឬទំនាក់ទំនងអ្វីជាមួយការចូលរួមរបស់ជនរងគ្រោះនៅក្នុងសវនាការព្រហ្មទណ្ឌនៅក្នុង…ប្រព័ន្ធច្បាប់រ៉ូម៉ាំណូ-ដ្យឺម៉ានីក ដែលនៅក្នុងប្រព័ន្ធនេះ ជនរងគ្រោះនៅក្នុងតួនាទីជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬជាព្រះរាជអាជ្ញាជំនួយមានសិទ្ធិយ៉ាងទូលំទូលាយក្នុងការចូលរួមនៅក្នុងសវនាការព្រហ្មទណ្ឌ ។*

៧) អង្គជំនុំជម្រះកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានរកឃើញថា ភាសាដែលមានសរសេរនៅក្នុងលក្ខន្តិកៈក្រុងរ៉ូម «បានផ្តល់ឲ្យអង្គជំនុំជម្រះកំពូលនូវការសម្រេចចិត្តពិសេសមួយថាការចូលរួមរបស់ជនរងគ្រោះគឺសមរម្យនៅក្នុងសវនាការបណ្តឹងជំទាស់ណាមួយដែលកំពុងពិចារណា» ។ ដោយសារហេតុផលនេះជនរងគ្រោះត្រូវតែដាក់ពាក្យសុំការអនុញ្ញាតចូលរួមនៅក្នុងសវនាការបណ្តឹងជំទាស់នោះ ដោយផ្តល់ជូនតុលាការនូវ «អំណះអំណាងទាក់ទងនឹងថាតើផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវប៉ះពាល់យ៉ាងដូចម្តេចនៅក្នុងសវនាការបណ្តឹងជំទាស់ណាមួយក៏ដូចជាថាតើហេតុអ្វីបានជាភាពសមរម្យដែលអង្គជំនុំជម្រះកំពូលត្រូវអនុញ្ញាតឲ្យជនរងគ្រោះបញ្ចេញនូវការយល់ឃើញ និងការព្រួយបារម្ភនៅក្នុងតុលាការ» ។ ដូច្នេះនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិដែលខុសគ្នាពីអង្គជំនុំជម្រះវិសាមញ្ញ «ការចូលរួមគឺមិនមែនជាព្រឹត្តការណ៍ដែលធ្វើឡើងតែមួយលើករួចរាល់នោះទេ ប៉ុន្តែការចូលរួមគឺត្រូវតែសម្រេចទៅតាមភ័ស្តុតាង ឬបញ្ហាដែលកំពុងពិចារណានៅក្នុងពេលវេលាជាក់លាក់ណាមួយនៅក្នុងដំណើរការ» ។ មិនមានភាសាសរសេរណាមួយដែលតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញដើរតាមតុលាការព្រហ្មទណ្ឌអន្តរជាតិនៅត្រង់បញ្ហានេះនោះទេ ជាងនេះទៅទៀត វានឹងមិនសមស្របទៅនឹងតួនាទីរបស់ភាគីរដ្ឋប្បវេណីនិងតួនាទីជាភាគីពេញលេញនោះទេ ។

៨) គួរឲ្យកត់សម្គាល់ថា សូម្បីតែនៅក្នុងចំណោមចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏មិនចុះសម្រុងគ្នាអំពីវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលត្រូវចំណាយពេលវេលាច្រើនទាក់ទងនឹងការចូលរួមដោយជនរងគ្រោះ ។ ជាឧទាហរណ៍ចៅក្រម sugJudge Song) បានលើកឡើងថា ការដែលតម្រូវឲ្យជនរងគ្រោះបង្ហាញពីរបៀបដែលផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវប៉ះពាល់ម្តងហើយម្តងទៀត «បានបង្កជានីតិវិធីមិនចាំបាច់ដែលទំនងជាពន្យឺតដំណើរការជំនុំជម្រះ» ។ ជាងនេះទៅទៀត ចៅក្រមប្លេត មែន (Judge Blattmann) បាននិយាយថា ការតម្រូវឲ្យមានការដាក់ពាក្យសុំជាច្រើនដង«បានដាក់បន្ទុកយ៉ាងធំធេងហួសហេតុទៅលើជនរងគ្រោះ» និងថា «វាគួរតែអាចទៅរួចដែលជនរងគ្រោះដាក់ពាក្យសុំចូលរួមពេញលេញតែម្តងនៅក្នុងពាក្យសុំដើមដំបូងរបស់ពួកគេ» ។

៩) តាមរយៈបទពិសោធន៍កន្លងមកនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ ការតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីអង្គជំនុំជម្រះវិសាមញ្ញពន្យល់អំពីផលប្រយោជន៍របស់ខ្លួននៅក្នុងគ្រប់សវនាការអង្គបុរេជំនុំជម្រះនឹងដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរទៅខាងមេធាវីនិងខាងការិយា

ល័យព្រះរាជអាជ្ញា ។ មានការរាយការណ៍ថា នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០០៧ ការិយាល័យព្រះរាជអាជ្ញា ក្រុមមេធាវី អ្នកតំណាងជនរងគ្រោះ បានដាក់ជូនតុលាការប្រមាណជា៦០សេចក្តីថ្លែងអំណះអំណាង ចំណែកឯអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះនៃសាលាកំពូលបានចេញប្រមាណជា៣០សេចក្តីសម្រេចដែលគ្រប់សេចក្តីសម្រេចនីមួយៗសុទ្ធតែដោះស្រាយសំណើដោយជនរងគ្រោះដើម្បីចូលរួមនៅក្នុងបុរេសវនាការ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញធ្វើតាមរបៀបតុលាការព្រហ្មទណ្ឌអន្តរជាតិ សវនាការជំនុំជម្រះនឹងប្រាកដជាត្រូវពន្យារពេល ហើយវាទំនងណាស់ដែលថា ជនជាប់ចោទមួយចំនួននឹងមិនអាចនៅមានជីវិតរហូតដល់ពេលចេញសាលក្រមចុងក្រោយឡើយ ។

(២) ដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ជាប់មកជាមួយតែមួយក្នុងការចូលរួមនៅក្នុងសវនាការនៃបណ្តឹងជំទាស់ដីកាឃុំខ្លួន

១០) វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញមិនទំនងជាបានគិតដល់ការចូលរួមដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការសួរដេញដោលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនៃសាលាដំបូងនោះទេ ។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនៃសាលាដំបូងក៏មិនទំនងជាអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចជុំវិញការឃុំខ្លួននោះដែរ ។ ទោះជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងអាចត្រូវបានបកស្រាយដោយមានបញ្ចូលសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងគ្រប់សវនាការលើបណ្តឹងជំទាស់របស់អង្គបុរេជំនុំជម្រះដែលរួមទាំងសវនាការទាក់ទងនឹងការឃុំខ្លួន ។ ជាក់ស្តែងវិធានផ្ទៃក្នុងបានចែងថា «បន្ទាប់ពីសហចៅក្រមបានអានរបាយការណ៍ [ស្តីអំពីអង្គហេតុដែលមានបញ្ហានិងការលម្អិតនៃសេចក្តីសម្រេច ដែលត្រូវប្តឹងឧទ្ធរណ៍] សហព្រះរាជអាជ្ញានិងមេធាវីរបស់ភាគីអាចធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយសង្ខេប» ។

១១) គួរកត់សម្គាល់ស៊ូម្បីតែនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជនរងគ្រោះមិនមែនជាភាគីពេញលេញនៅក្នុងសវនាការ ជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសវនាការបណ្តឹងជំទាស់ទៅនឹងដីកាឃុំខ្លួន ។ នៅក្នុងសំណុំរឿងលូបាងហ្គា (Lubanga) អង្គជំនុំជម្រះសាលាកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការពិចារណាថាតើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលចូលរួមត្រូវប៉ះពាល់ដោយសារបណ្តឹងជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្នឬទេ និងបានរកឃើញថា ជនរងគ្រោះនៅក្នុងសំណុំរឿងនោះមានផលប្រយោជន៍នៅក្នុង«សវនាការបណ្តឹងជំទាស់ដែលទាក់ទងទៅនឹងការសម្រេចថា តើជនកំពុងស្វែងរកចាប់ខ្លួនគួរតែអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្នឬទេ» ។ ការព្រួយបារម្ភដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿងនោះគឺស្រដៀងគ្នាទៅនឹងការព្រួយបារម្ភដែលកំពុងមានបញ្ហានៅក្នុងបណ្តឹងជំទាស់របស់នួន ជា ដែរ ដែលរួមទាំងគ្រោះថ្នាក់ដែលថា ប្រសិនបើត្រូវដោះលែងជនជាប់ចោទ អាចរារាំងដល់ការស៊ើបអង្កេត ។

១២) ជាងនេះទៅទៀត ផលប្រយោជន៍ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការបញ្ចេញយោបល់អំពីបញ្ហាឃុំខ្លួនបណ្តោះអាសន្នគឺត្រូវបានទទួលស្គាល់ដោយប្រយោលនៅក្នុងវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ បន្ថែមទៅលើការលើកឡើងអំពីផលប្រយោជន៍នៃភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការស្វែងរកសំណងជំងឺចិត្ត និងជារួមវិធានផ្ទៃក្នុងបានសង្កត់ធ្ងន់ទៅលើផលប្រយោជន៍របស់ភាគីដើមបណ្តឹងនៅក្នុង «ការចូលរួមនៅក្នុងសវនាការព្រហ្ម-ទណ្ឌតាមរយៈការគាំទ្រខាងព្រះរាជអាជ្ញា» ។ តួនាទីទាំងពីរនេះត្រូវបានកត់សម្គាល់ស្រដៀងគ្នាដែរនៅក្នុងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការសិទ្ធិមនុស្សអឺរ៉ុប (*European Court of Human Rights*) ។ ជាក់ស្តែង អង្គជំនុំជម្រះនៃសាលាដំបូងបានសង្កត់ធ្ងន់ថា ផលប្រយោជន៍របស់ជនរងគ្រោះចូលរួមនៅក្នុងសវនាការតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺហួសពីការទទួលបានសំណងជំងឺចិត្តនិង «គួរតែរួមបញ្ចូលផលប្រយោជន៍ផ្ទាល់ខ្លួន-របស់ជនរងគ្រោះនៅក្នុងរបៀបមួយទូលាយយ៉ាងសមរម្យ» ។ នៅក្នុងសំណុំរឿងមួយទៀត ចៅក្រមអង្គជំនុំជម្រះកំពូលម្នាក់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានធ្វើការកត់សម្គាល់ថា លក្ខន្តិកៈ

ក្រុងរ៉ូមបានទទួលស្គាល់ផលប្រយោជន៍របស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ដែល«ហួសពីផលប្រយោជន៍ទូទៅដែលសមាជិកសង្គមទាំងឡាយក៏អាចមានដែរនោះ ក្នុងការមើលឃើញជនល្មើសទទួលខុសត្រូវតាមផ្លូវច្បាប់» ។ លោកចៅក្រមបានរកឃើញការគាំទ្រយោបល់នេះនៅក្នុងសំណុំរឿងគីលីកនិងទួរគី (*Kilic* និង *Turkey*) ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា សិទ្ធិទទួលបានដំណោះស្រាយយ៉ាងមានប្រសិទ្ធភាព *Effective Remedy*) នៅក្នុងកតិកាសញ្ញាអឺរ៉ុប (*European Convention*) តម្រូវឲ្យមានៈ បន្ថែមទៅលើការចំណាយលើសំណងជំងឺចិត្តនៅពេលសមរម្យ ការស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងមានប្រសិទ្ធភាពដែលអាចនាំទៅដល់ការកំណត់អត្តសញ្ញាណនិងទណ្ឌកម្មចំពោះអ្នកដែលទទួលខុសត្រូវចំពោះការដកហូតជីវិតនិងដែលរួមមានទាំងសិទ្ធិយ៉ាងមានប្រសិទ្ធភាពរបស់ម្ចាស់បណ្តឹងក្នុងការចូលរួមក្នុងនីតិវិធីស៊ើបអង្កេត ។

១៣) ជាផលវិបាកនៃការទទួលស្គាល់របស់គាត់ចំពោះការយល់ឃើញយ៉ាងទូលំទូលាយចំពោះផលប្រយោជន៍ផ្ទាល់ខ្លួន ចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិបានរកឃើញផ្ទុយពីមតិភាគច្រើនថា ផលប្រយោជន៍របស់ជនរងគ្រោះត្រូវបានពង្រីកទៅដល់ការចូលរួមនៅក្នុងសវនាការជំនុំជម្រះលើបញ្ហាតូចតាច ថាតើគួរតែអនុញ្ញាតឲ្យមានបណ្តឹងជំទាស់ទៅនឹងបទចោទប្រកាន់លើជនជាប់ចោទឬទេ ។ នៅក្នុងយោបល់របស់គាត់ នៅចុងបញ្ចប់ «បណ្តឹងជំទាស់ដែលទទួលបានជោគជ័យនឹងកាត់បន្ថយក្តីសង្ឃឹមរបស់ជនរងគ្រោះក្នុងការទទួលបានសំណងជំងឺចិត្តនិងទទួលបានយុត្តិធម៌» ។

១៤) ភាសាទូលាយស្រដៀងគ្នានេះដែលទាក់ទងនឹងផលប្រយោជន៍ ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានផ្តល់ឲ្យដោយលក្ខខណ្ឌជាដើមបណ្តឹងរដ្ឋប្បវេណីដែលជាភាគីពេញលេញទៅនឹងសវនាការនិងការទទួលស្គាល់ជាក់លាក់នៅក្នុងវិធានផ្ទៃក្នុងដែលថា ពួកគេមានផលប្រយោជន៍ក្នុងការគាំទ្រខាងព្រះរាជអាជ្ញា ។ ជាជាងការមិនអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងប្រភេទសវនាការខ្លះ ការលម្អៀងណាមួយចំពោះជនជាប់ចោទអាចត្រូវបានកាត់បន្ថយដោយការចែងឲ្យបានសមរម្យនូវទំហំនៃអន្តរាគមន៍របស់ជនរងគ្រោះ ។

### ក) ទំហំនៃសិទ្ធិក្នុងការចូលរួមក្នុងសវនាការរបស់ជនរងគ្រោះត្រូវតែថ្លឹងថ្លែងទៅនឹងសិទ្ធិទទួលបានយុត្តិធម៌របស់ជនជាប់ចោទ

១៥) នៅក្នុងសវនាការអង្គជំនុំជម្រះវិសាមញ្ញទាំងអស់ សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមត្រូវតែថ្លឹងថ្លែងទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទដែលរួមមានទាំង សិទ្ធិក្នុងការសន្មតជាមុនថាគ្មានទោសនិងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ។ ដូចដែលបានកត់សម្គាល់ដោយអ្នកអត្ថាធិប្បាយម្នាក់ៈ

ប្រសិនបើជនរងគ្រោះអាចអនុវត្តសិទ្ធិ[ចូលរួម]ដោយសេរីដោយគ្មានការកំណត់ដោយចៅក្រមនោះ សវនាការជំនុំជម្រះអាចចំណាយពេលយូរមិនអាចកំណត់បានដែលនាំទៅដល់ការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទ ។ ចំនួនជនរងគ្រោះនៅក្នុងសំណុំរឿងឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាញឹកញាប់មានចំនួនរហូតដល់ទៅរាប់ពាន់នាក់ ឬអាចដល់រាប់ម៉ឺននាក់ទៀតផង ។ ជាងនេះទៅទៀត ចរិតនៃព្យសនកម្មដែលជនរងគ្រោះទទួលរងបានបន្ថែមទៅលើឥទ្ធិពលនៃការរំជួលចិត្តនៃអន្តរាគមន៍នៅក្នុងសវនាការ ។ ប្រសិនបើគ្មានការគ្រប់គ្រងនោះទេ ការចូលរួមរបស់ជនរងគ្រោះអាចធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តដ៏រលូននៃការជំនុំជម្រះនិងសិទ្ធិរបស់ជនជាប់ចោទក៏ដូចជាការស្វែងរកការពិត ។

គ.១ អង្គបុរេជំនុំជម្រះគួរតែតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដាក់ជូនតុលាការជាមុននូវសេចក្តីសន្និដ្ឋានដែលនឹងលើកឡើងនៅក្នុងពេលសវនាការ

១៦) ដើម្បីការពារកុំឲ្យមានការលម្អៀងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ នៅមុនពេលសវនាការលើបណ្តឹងជំទាស់អង្គបុរេជំនុំជម្រះគួរតែតម្រូវយ៉ាងតឹងរ៉ឹងឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីដាក់ជូនតុលាការជាមុននូវអំណះអំណាងដែលខ្លួនបម្រុងនឹងលើកឡើងនៅក្នុងពេលសវនាការដូចដែលតម្រូវឲ្យធ្វើដោយវិធានផ្ទៃក្នុងនិងសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ (*Practice Direction on the Filing of*

*Documents)* ។ ការមិនគោរពតាមលក្ខខណ្ឌនេះ នៅក្នុងសវនាការបណ្តឹងជំទាស់របស់ នួន ជា អង្គបុរេជំនុំជម្រះបានប្រថុយប្រថានក្នុងការលម្អៀងទៅលើសិទ្ធិរបស់ជនជាប់ចោទ និងបានបើកឱកាសឲ្យខាងមេធាវីអាចធ្វើការជំទាស់ផ្ទាល់មាត់ភ្លាមៗ ទៅនឹងការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានដាក់អំណះអំណាងពីដំបូងជូនតុលាការ ។

គ.២ អង្គបុរេជំនុំជម្រះគួរតែដាក់កម្រិតអន្តរាគមន៍ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី មកនៅត្រឹមតែចំណុចបញ្ហាជាក់លាក់ដែលប្តឹងជំទាស់

១៧) អង្គជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញគួរតែដាក់កម្រិតផងដែរលើសេចក្តីសន្និដ្ឋាន ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីមកនៅត្រឹមតែផ្តោតលើបញ្ហាដែល«ទាក់ទងជាពិសេសទៅនឹងចំណុចប្តឹងជំទាស់ជាជាងសេចក្តីសន្និដ្ឋានដែលផ្តោតជាទូទៅ» ។ ជាក់ស្តែងអង្គជំនុំជម្រះកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានតម្រូវឲ្យជនរងគ្រោះដែលចូលរួមបង្ហាញពី«ទំនាក់ទំនងរវាងសេចក្តីសន្និដ្ឋានរបស់ខ្លួនទៅនឹងបញ្ហាដែលកំពុងត្រូវប្តឹងជំទាស់» ។ អង្គជំនុំជម្រះកំពូលនេះបានថ្លែងថាៈ

ជារឿងមិនសមរម្យទេដោយគ្រាន់តែលើកឡើងដដែលម្តងទៀតនូវភ័ស្តុតាងដែលមានរួចហើយនៅក្នុងអង្គបុរេជំនុំជម្រះ ឬដោយបង្ហាញភ័ស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះកំពូល ដោយមិនមានបង្ហាញអំពីទំនាក់ទំនងថាតើភ័ស្តុតាង ថ្មីនេះអាចមានឥទ្ធិពលដូចម្តេចខ្លះទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះជុំវិញបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងជំទាស់ ។

ជាងនេះទៅទៀត នៅពេលដែលចំណុចរបស់ជនរងគ្រោះបានលើកឡើងមិនបានផ្តល់ជាជំនួយដល់សេចក្តីសម្រេចលើបញ្ហាដែលត្រូវប្តឹងជំទាស់អង្គជំនុំជម្រះកំពូលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនយកចំណុចទាំងនេះជាមូលដ្ឋានក្នុងការសម្រេចទេ ។

១៨) ការកំណត់កម្រិតទាំងនេះគឺជារឿងត្រឹមត្រូវសូម្បីតែទាក់ទងទៅនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាភាគីដើមបណ្តឹងរដ្ឋប្បវេណីជាភាគីពេញលេញទៅនឹងការជំនុំជម្រះក្តីក៏ដោយ ។ ជាក់ស្តែង តុលាការសិទ្ធិមនុស្សអឺរ៉ុបបានទទួលស្គាល់ថា ទំហំនៃសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមសវនាការតុលាការអាចត្រូវបានកំណត់ «ដោយពិនិត្យមើលអំពីតួនាទីនៃបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ និងអំពីផលប្រយោជន៍បន្ទាប់បន្សំនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី និងខាងព្រះរាជអាជ្ញា... តួនាទីនិងគោលបំណងរបស់ពួកគេគឺខុសគ្នាច្បាស់ក្រឡែត» ។ ប៉ុន្តែ «ការកំណត់កម្រិតទាំងនេះ ត្រូវតែមិនកំហិត ឬកាត់បន្ថយសិទ្ធិចូលរួមរបស់បុគ្គលតាមរបៀបបែបនោះ ឬដល់កម្រិតដែលត្រូវប៉ះពាល់សិទ្ធិរបស់គេនោះទេ» ។ ជាងនេះទៅទៀត ការកំណត់កម្រិតណាមួយត្រូវតែមានគោលបំណងសមស្របតាមច្បាប់ និងមាន«ទំនាក់ទំនងសមហេតុសមផលនៃសមាមាត្ររវាងមធ្យោបាយប្រើប្រាស់ និងគោលដៅដែលចង់សម្រេចឲ្យបាន» ។

១៩) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានរកឃើញថា ភាគីរឿងក្តីទាំងអស់មានសិទ្ធិ «ដាក់សេចក្តីសន្និដ្ឋានដែលខ្លួនយល់ថាជាប់ពាក់ព័ន្ធនឹងសំណុំរឿងរបស់ខ្លួន» ហើយតុលាការមាន«កាតព្វកិច្ចពិនិត្យមើលសេចក្តីសន្និដ្ឋាន អំណះអំណាងនិងភ័ស្តុតាងដែលដាក់ជូនដោយភាគី» និងផ្តល់ហេតុផលចំពោះសេចក្តីសម្រេចនេះ ។ ទោះបីជាយ៉ាងនេះក៏ដោយ តុលាការអាចធ្វើការវាយតម្លៃថាតើ សេចក្តីសន្និដ្ឋានរបស់ភាគីទាក់ទងនឹងរឿងក្តីឬអត់ និងមិនចាំបាច់ផ្តល់«ចម្លើយពិស្តារ»ទៅគ្រប់អំណះអំណាងនោះវិញទេ ។

៣) អង្គជំនុំជម្រះអាចតម្រូវឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសអ្នកតំណាងជារួមម្នាក់

២០) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានចែងថា «ភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមអាចជ្រើសរើសមេធាវីមួយរូបធ្វើជាអ្នកតំណាងចេញពីបញ្ជីឈ្មោះមេធាវីដែលចេញដោយអង្គភាពជនរងគ្រោះ» ។ ជាងនេះទៅទៀត សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចរៀបចំការធ្វើតំណាងនេះដោយៈ ទី១) ស្នើសុំឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសមេធាវីរួមគ្នា ទី២) ស្នើសុំឲ្យអង្គភាពជនរងគ្រោះជ្រើសរើសមេធាវីរួមមួយសម្រាប់ភាគីដើមបណ្តឹង និងទី៣) «នៅពេលដែលគេយល់ថា យុត្តិធម៌តម្រូវឲ្យធ្វើដូច្នោះ» [សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះខ្លួនឯង] ចាត់តាំងមេធាវីតំណាងរួមឲ្យក្រុមនោះតែម្តង ។

(២១) អំណាចក្នុងការរៀបចំភាគីដើមបណ្តឹងរដ្ឋប្បវេណីជាក្រុមនេះបានផ្តល់ឲ្យតុលាការនូវមធ្យោបាយយ៉ាងសំខាន់ដែលអាចស្វែងរកតុល្យភាពសមរម្យរវាងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ ។ មកទល់នឹងពេលនេះ យើងមិនទាន់ដឹងថាមានជនរងគ្រោះប៉ុន្មាននាក់ដែលនឹងដាក់ពាក្យបណ្តឹងសុំធ្វើភាគីដើមបណ្តឹងរដ្ឋប្បវេណីនិងថាតើប៉ុន្មាននាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមបណ្តឹងរដ្ឋប្បវេណី ។ ទោះជាយ៉ាងណាក៏ដោយ បទឧក្រិដ្ឋកម្មដែលត្រូវបានចោទទៅលើជនជាប់ចោទ ដាក់ស្តែងមានជនរងគ្រោះរាប់លាននាក់ ហើយសវនាការអាចមានចំនួនភាគីដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើននៅក្នុងរយៈពេលនៃដំណើរការជំនុំជម្រះនេះ ។ ដូចដែលទទួលស្គាល់ដោយអង្គជំនុំជម្រះនៃសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិថា «ការណ៍ដែលជនរងគ្រោះមានចំនួនច្រើនលើសលប់ បង្ហាញមុខនោះអាចធ្វើឲ្យប៉ះពាល់ដល់ល្បឿន និងភាពត្រឹមត្រូវនៃការជំនុំជម្រះ» និងបង្កជាការពន្យារពេលតទៅទៀត ។ ដោយសារមូលហេតុនេះ ប្រសិនបើភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំចូលរួមនៅក្នុងសំណុំរឿងនៃអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះអាចជំរុញនិងក្នុងករណីដែលចាំបាច់តម្រូវឲ្យមានការបែងចែកជាក្រុមជាយន្តការចាំបាច់ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនិងភាពត្រឹមត្រូវនៃការជំនុំជម្រះដោយមិនភ្លេចពីផលប្រយោជន៍បុគ្គលនៃភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនោះទេ ។

(២២) វិធានផ្ទៃក្នុងបានចែងថា «សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនិងអង្គភាពជនរងគ្រោះនឹងចាត់វិធានការសមហេតុផលទាំងអស់ដើម្បីធានាថា នៅក្នុងការជ្រើសរើសមេធាវីផលប្រយោជន៍ដោយឡែកៗពីគ្នានៃភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេតំណាងឲ្យ និងថា វិសមភាពមិនកើតមានទេ» ។ បញ្ញត្តិស្រដៀងគ្នានេះក្នុងការរៀបចំជនរងគ្រោះជាក្រុមតាមរយៈអ្នកតំណាងរួមក៏មានចែងនៅក្នុងវិធាននីតិវិធី និងភ័ស្តុតាង (**Rules of Procedure and Evidence**) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរ ។ នៅក្នុងសេចក្តីសម្រេចថ្មីៗនេះ អង្គជំនុំជម្រះនៃសាលាដំបូងបានគាំទ្រ «មធ្យោបាយទន់ភ្លន់មួយ»ក្នុងការរៀបចំជាក្រុម និងបានកំណត់យោបល់ថាមានសារសំខាន់នៅក្នុងពេលជ្រើសរើសៈ «ភាសាដែលជនរងគ្រោះនិយាយ(និងអ្នកតំណាងណាមួយដែលត្រូវបានស្នើរួមគ្នាដោយជនរងគ្រោះ), ទំនាក់ទំនងរវាងជនរងគ្រោះដូចជាពេលវេលា ទីកន្លែង និងស្ថានភាព និងប្រភេទនៃបទឧក្រិដ្ឋដែលខ្លួនគិតថាបានជួបប្រទះ» ។

(២៣) ជាពិសេស នៅពេលដែលមានការជំទាស់ពីដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមអាចតម្រូវឲ្យមានការរៀបចំជាក្រុមតែនៅពេលដែលខ្លួនគិតថា «ភាពយុត្តិធម៌»តម្រូវឲ្យធ្វើដូច្នោះ ។ ដូច្នេះរហូតដល់ពេលដែលការរៀបចំចូលជាក្រុមនេះជារឿងចាំបាច់បំផុតនោះ គេគួរតែជំរុញឲ្យមានការចូលជាក្រុមដោយការស្ម័គ្រចិត្តដើម្បីចៀសវាងការលើកឡើងដដែលៗនៅក្នុងពេលសវនាការ ។ ទន្ទឹមនោះដែរ អង្គជំនុំជម្រះអាចរកឃើញថា វាជារឿងចាំបាច់ក្នុងដាក់កំហិតឲ្យអ្នកតំណាងក្រុម ឬសមាជិក ក្រុមតែម្នាក់ ឬច្រើនជាងនេះប៉ុណ្ណោះអាចធ្វើការអះអាងដោយផ្ទាល់មាត់នៅក្នុងពេលសវនាការ ប្រសិនបើចំនួននៃការលើកឡើងនៅក្នុងពេលសវនាការនេះអាចបង្កជាការពន្យារពេលច្រើន ឬអាចបង្កជាការលម្អៀងដល់ជនជាប់ចោទ ។

## IV. សេចក្តីសន្និដ្ឋាន

(២៤) ដោយសារអង្គជំនុំជម្រះវិសាមញ្ញទំនងជាឱកាសតែមួយសម្រាប់ជនរងគ្រោះដែលអាចប្រឈមមុខនឹងអ្នកដែលធ្វើបាបខ្លួននិងក្រុមគ្រួសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នករួចរស់ជីវិតពីរបបនោះរាប់ពាន់នាក់ប្រហែលជាអាចដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ។ ការចូលរួមបែបនេះអាចជាការរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែទំហំនៃអន្តរាគមន៍ដោយដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែចាត់ចែងឲ្យបានប្រុងប្រយ័ត្នបំផុតដោយអង្គជំនុំជម្រះ បើមិនដូច្នោះទេ ការជំនុំជម្រះនេះអាចបាត់បង់ការផ្តោតអារម្មណ៍និងអាចបង្កអូសបន្លាយពេលវេលា ដែលការណ៍នេះអាចនាំទៅដល់ការកាត់បន្ថយគោលបំណងនៃផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ពោលគឺជួយដល់ខាងព្រះរាជអាជ្ញានិងទទួលបានយុត្តិធម៌ ។

**អ៊ែន ហាញឌុល**

# រូបថតក្នុងរបបសាធារណរដ្ឋខ្មែរ (លន់ នល់)

រូបថតដោយ ខុនរ៉ាដ អាឌេណូអ័រ















# កងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញ
## ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥











# ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ផលវិបាក ការវិភាគ និងអនុសាសន៍

## សេចក្តីផ្តើម

ខ្ញុំសួរខ្លួនឯងថាតើកូនខ្មែរជំនាន់ក្រោយជឿថាឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមពិតជាកើតមានឡើងនៅក្នុងប្រទេសកម្ពុជាដែរឬអត់? តើពួកគេជឿនូវការរៀបរាប់អំពីការឈឺចាប់របស់ឪពុកម្តាយនិងជីដូនជីតានៅពេលនោះដែរឬទេ? តើមានអ្នកនិពន្ធឬអ្នកប្រវត្តិសាស្ត្រណាម្នាក់បានចងក្រងប្រវត្តិសាស្ត្រនេះដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីផ្លូវការរបស់សាលាហើយឬនៅ?

នេះគឺជាចំណាប់អារម្មណ៍ដ៏សោកសៅរបស់អ្នកស្រី សុះ សីហា មេដឹកនាំសហគមន៍អ៊ីស្លាមមកពីខេត្តក្រចេះ បន្ទាប់ពីបានដើរទស្សនាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមរបស់ខ្មែរក្រហម (គុកទួលស្លែង) និងវាលពិឃាតជើងឯក ។ សមាជិកមួយចំនួនរបស់អ្នកស្រីបានស្លាប់និងបាត់ខ្លួននៅក្នុងរយៈកាលនៃការគ្រប់គ្រងអំណាចរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ ការខ្វល់ខ្វាយរបស់អ្នកស្រីអំពីការយល់ដឹងរបស់កូនខ្មែរជំនាន់ក្រោយ បានលើកជាសំណួរមួយថា ៖ តើកូនខ្មែរជំនាន់ក្រោយគួរសិក្សាអំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មនិងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្នុងថ្នាក់រៀនដែរឬទេ?

ការសិក្សាពីអំពើប្រល័យពូជសាសន៍ គឺជាវិធីដ៏មានប្រសិទ្ធភាពតែមួយគត់ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដទៃទៀតនាពេលអនាគត ជំរុញការផ្សះផ្សារវាងជនរងគ្រោះនិងជនដៃដល់និងបន្តពិភាក្សាអំពីបញ្ហាយុត្តិធម៌ នៅក្នុងប្រទេសដែលជួបប្រទះនឹងអំពើប្រល័យពូជសាសន៍ ។ កម្ពុជាមិនអាចនិយាយអំពីយុត្តិធម៌និងការផ្សះផ្សាបានទេ នៅពេលដែលការឈឺចាប់របស់ជនរងគ្រោះមិនត្រូវបានទទួលស្គាល់ ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលអាចកើតមានឡើងនាពេលអនាគត កូនខ្មែរជំនាន់ក្រោយត្រូវតែសិក្សាស្វែងយល់ឲ្យបានច្បាស់ថាតើអំពើប្រល័យពូជសាសន៍កើតឡើងដោយរបៀបណា និងដោយមូលហេតុអ្វី និងសិក្សាអំពីផលប៉ះពាល់និងលទ្ធផលនៃអំពើប្រល័យពូជសាសន៍ ។ ការសិក្សាពីអំពើប្រល័យពូជសាសន៍ជួយរក្សាការចងចាំអំពីសោកនាដកម្មក្នុងរបបខ្មែរក្រហមបង្កើនតម្លៃសីលធម៌របស់ប្រជាពលរដ្ឋនិងជំរុញដល់ដំណើរការប្រជាធិបតេយ្យនិងការគោរពច្បាប់ នៅក្នុងប្រទេសដែលទទួលរងនូវវប្បធម៌និទ្ទណ្ឌភាពជាយូរយារណាស់មកហើយ ។ ជាងនេះទៅទៀត ការសិក្សាស្វែងយល់អំពីព្រឹត្តិការណ៍ប្រវត្តិសំខាន់ៗនឹងជួយឲ្យប្រជាជន ជាពិសេសក្មេងៗជំនាន់ក្រោយមានលទ្ធភាពចូលរួមក្នុងដំណើរការសាលាក្តីខ្មែរក្រហម ដែលជួយជំរុញឲ្យមានការទទួលខុសត្រូវចំពោះការរំលោភបំពាននៅក្នុងរយៈកាលនោះ ។

ទោះជាយ៉ាងនេះក្តី ប្រធានបទដ៏មានសារសំខាន់និងដែលប៉ះពាល់ដល់ផ្លូវចិត្តរបស់ប្រជាជនខ្មែរគ្រប់រូបនេះនៅតែបន្តអវត្តមានពីកម្មវិធីសិក្សារបស់សាលានៅកម្ពុជា ។ ឧបសគ្គចម្បងៗនៅក្នុងការដាក់ឲ្យមានការសិក្សាពីអំពើប្រល័យពូជសាសន៍នៅក្នុងថ្នាក់រៀនរួមមាន ឧបសគ្គផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ និងគរុកោសល្យ ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ សិស្សសាលាត្រូវបានបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍ក្នុងលក្ខណៈជាការឃោសនាផ្នែកនយោបាយ ដែលមានបំណងចង់បណ្តុះគំនិតក្នុងការបង្កឲ្យមានអំពើហិង្សា ការស្អប់ខ្ពើម និងការសងសឹកនៅក្នុងផ្នត់គំនិតរបស់សិស្ស ។ ដោយសារនៅពេលនោះសង្គមកម្ពុជាដាក់អាទិភាពទៅលើការស្រោចស្រង់សេដ្ឋកិច្ច ទុក្ខវេទនារបស់ប្រជាជនកម្ពុជាបានក្លាយទៅជារឿងនិទានសម្រាប់កូនខ្មែរជំនាន់ក្រោយដែលកើតក្រោយការដួលរលំនៃរបបខ្មែរក្រហម ។ បន្ទាប់ពីសន្តិភាពត្រូវបានស្តារឡើងវិញនៅឆ្នាំ១៩៩៣ ប្រធានបទពីអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមត្រូវបានដកចេញពីកម្មវិធីសិក្សារបស់សាលាដើម្បីជាប្រយោជន៍ដល់ការផ្សះផ្សានិងស្ថិរភាពនយោបាយ ។ នៅឆ្នាំ២០០២ រដ្ឋាភិបាលបានបញ្ជាឲ្យដកប្រវត្តិ

សាស្ត្រសម័យទំនើបរបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៩៣ដល់ការបោះឆ្នោតជាតិឆ្នាំ១៩៩៨ ដែលរួមមានទាំងប្រវត្តិសាស្ត្រខ្មែរក្រហមចេញពីកម្មវិធីសិក្សារបស់សាលារដ្ឋ ដោយសារតែជម្លោះផ្ទៃក្នុងរវាងគណបក្សនយោបាយធំៗពីរទៅលើបញ្ហានៃការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ។ ការសិក្សាជាបន្តបន្ទាប់មកទៀតបានបង្ហាញឲ្យឃើញថា ក្មេងជំនាន់ក្រោយបានដឹងតិចតួចណាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ កូនខ្មែរជាច្រើនមិនជឿថាឪពុកម្តាយនិងសាច់ញាតិរបស់ខ្លួនបានជួបប្រទះនូវការលំបាកនិងការឈឺចាប់ដែលថ្លែងមិនចេញបែបនេះនៅក្នុងរយៈកាលនោះទេ ។ បន្ថែមពីលើជម្លោះនយោបាយនេះ ក្រសួងអប់រំយុវជននិងកីឡាបានអះអាងថា ក្រសួងមានការខ្វះខាតប្រភពធនធានដើម្បីបង្រៀនប្រវត្តិនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ជាងនេះទៀតលោកគ្រូអ្នកគ្រូដែលមានលទ្ធភាពក្នុងការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រនេះនៅមានចំនួនតិច ហើយមិនទាន់ទទួលបានការហ្វឹកហាត់ឲ្យបានគ្រប់គ្រាន់ដើម្បីអាចបង្រៀនពីអំពើប្រល័យពូជសាសន៍ឲ្យមានប្រសិទ្ធភាពនៅឡើយ ។

អវត្តមាននៃការសិក្សាពីអំពើប្រល័យពូជសាសន៍គឺជាសញ្ញាមួយបង្ហាញថា ស្រមោលនៃអំពើប្រល័យពូជសាសន៍នៅតែបន្តលងប្រទេសកម្ពុជានៅឡើយ ។ ការផ្តល់ឲ្យនូវរូបភាពទាំងមូលអំពីអ្វីដែលបានកើតឡើង ហេតុអ្វីបានជាវាកើតមានឡើង តើវាកើតឡើងដោយរបៀបណា តើអំពើនោះបង្កឲ្យមានផលវិបាកអ្វីខ្លះ នឹងផ្តល់ជាមូលដ្ឋានសម្រាប់សិស្សក្នុងការចែករំលែកអ្វីដែលខ្លួនបានរៀននៅសាលាជាមួយឪពុកម្តាយបងប្អូននិងមិត្តភក្តិ ។ ការសិក្សាពីអំពើប្រល័យពូជសាសន៍ក៏នឹងជួយសម្រាលការឈឺចាប់របស់ជនរងគ្រោះដោយអនុញ្ញាតឲ្យគាត់មានឱកាសចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយកូនចៅ ហើយប្រការនេះនឹងធានាឲ្យបានថា ទុក្ខវេទនានិងការឈឺចាប់របស់គាត់នឹងត្រូវបានចងចាំនិងទទួលស្គាល់ ។ អវត្តមាននៃការសិក្សាពីអំពើប្រល័យពូជសាសន៍បង្ហាញឲ្យឃើញថា ក្មេងជំនាន់ក្រោយអាចនឹងទទួលរងនូវអំពើប្រហាក់ប្រហែលនេះ ។ ដូច្នេះការសិក្សាស្រាវជ្រាវនេះនឹងពិនិត្យមើលទៅលើឧបសគ្គផ្នែកសង្គមសេដ្ឋកិច្ច នយោបាយ និងគរុកោសល្យក្នុងការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសមួយដែលទើបនឹងងើបចេញពីសោកនាដកម្ម ។

## ផលវិបាកផ្នែកសង្គមនិងសេដ្ឋកិច្ច

របបខ្មែរក្រហមដែលគ្រប់គ្រងប្រទេសកម្ពុជាពីខែមេសាឆ្នាំ១៩៧៥ ដល់ខែមករាឆ្នាំ១៩៧៩ បានបំផ្លិចបំផ្លាញស្ទើរតែទាំងអស់នូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ទ្រព្យសម្បត្តិសាធារណៈនិងឯកជន និង ប្រព័ន្ធអប់រំរបស់ជាតិ ។ របបនេះបានមើលឃើញការសិក្សានៅតាមសាលារៀននិងសាកលវិទ្យាល័យថាជាការចំណាយពេលឥតប្រយោជន៍ និងគ្មានបានជួយអ្វីទាល់តែសោះដល់បដិវត្តន៍និងការអភិវឌ្ឍប្រទេស ។ ជាលទ្ធផល ខ្មែរក្រហមបានបិទចោលនូវរាល់ស្ថាប័នសិក្សាទាំងអស់ តាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ។ គ្រូបង្រៀន វេជ្ជបណ្ឌិត និងអ្នកចេះដឹងផ្សេងៗទៀត (រួមទាំងអ្នកពាក់វ៉ែនតានិងអ្នកចេះនិយាយភាសាបរទេសផង) ត្រូវបានសម្លាប់ជាប្រព័ន្ធ ដោយសារតែអ្នកទាំងនេះត្រូវបានខ្មែរក្រហមចាត់ទុកថាជាសមាសភាពមិនល្អ ដែលអាចបង្កឲ្យមានអំពើអយុត្តិធម៌ អំពើពុករលួយ និងការកេងប្រវ័ញ្ចនៅក្នុងសង្គម និងធ្វើសង្គមជាតិធ្លាក់ទៅក្នុងអាណានិគមនិងចក្រពត្តិនិយមរបស់បរទេស ។

កូនក្មេងទាំងអស់មិនត្រូវបានបញ្ជូនឲ្យទៅសាលារៀនទេ ។ ក្មេងៗត្រូវបានបង្ខំឲ្យធ្វើការងារពលកម្មនិងចូលរួមវគ្គសិក្សាមនោគមវិជ្ជា ។ ខ្មែរក្រហមបានអះអាងថា «ដងចបជាស្លាបប៉ាកកា ហើយវាលស្រែជាសៀវភៅ ។ បើចង់បាន បាក់អង បាក់ឌុបត្រូវទៅយកនៅទំនប់ប្រឡាយ» ។ លទ្ធផលគឺ មានការខូចខាតទាំងស្រុង ។ ប្រជាជនកម្ពុជាប្រមាណជាពីរលាននាក់បានស្លាប់ដោយការសម្លាប់ ការអត់អាហារ ការធ្វើការហួសកម្លាំង ការធ្វើទារុណកម្ម និងជំងឺដែលគ្មានការព្យាបាលឲ្យបានត្រឹមត្រូវ ។ របបនេះបានបន្សល់ទុកនូវស្ត្រីមេម៉ាយនិងកុមារកំព្រារាប់ម៉ឺននាក់ក្នុងសភាពក្រខ្សត់និងអវិជ្ជា ។ ប្រជាជនខ្មែររាប់សែននាក់ផ្សេងទៀតបានរត់ចេញពីប្រទេសហើយក្លាយទៅជាជនភៀសខ្លួន ។ ប្រទេសកម្ពុជាបន្ទាប់ពីឆ្នាំ១៩៧៩ស្ថិតក្នុងសភាពចលាចល ដោយសារតែប្រជាជនបានធ្វើដំណើរខ្វាត់ខ្វែងពេញផ្ទៃប្រទេសដើម្បីស្វែងរកសមាជិកគ្រួសារដែលបាត់ខ្លួន ។ សង្គ្រាមស៊ីវិលរវាងភាគីជម្លោះកម្ពុជាកាន់តែមានសភាពខ្លាំងក្លាឡើង ។ ខ្មែរក្រហមបានបំផ្លាញ

បោលស្ទើរតែមូលដ្ឋានគ្រឹះស្ទើរទាំងអស់របស់ជាតិ ។ រដ្ឋាភិបាលបន្តបន្ទាប់ ក្រោយមកទៀតបានចាប់ផ្តើមកសាងប្រព័ន្ធសិក្សាអប់រំឡើងវិញនៅក្នុងប្រទេស ។

វត្តមានរបស់កងកម្លាំងវៀតណាមនៅឆ្នាំ១៩៧៩ បានបញ្ចប់អំពើឃោរឃៅរបស់ខ្មែរក្រហម និងបានបង្កើតរបបថ្មីមួយទៀត គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅពេលនោះប្រជាជនទទួលបាននូវសិទ្ធិជាមូលដ្ឋានមួយចំនួន និងមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើផ្ទះសំបែង គោក្របី និងសម្ភារៈកសិកម្ម ។ ទោះបីជាប្រជាជននៅបន្តធ្វើស្រែចម្ការរួមក្នុងទ្រង់ទ្រាយជា «ក្រុមប្រវាស់ដៃឬក្រុមសាមគ្គី» ក៏ដោយ ក៏កសិករភាគច្រើនបានមើលឃើញស្ថានភាពនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានលក្ខណៈប្រសើរជាងរបបខ្មែរក្រហមដែរ ។ ដោយមានជំនួយពីវៀតណាម និងការសហការពីប្រជាជនក្នុងតំបន់ការសិក្សាអប់រំត្រូវបានស្តារឡើងវិញ ។ សាលាបឋមសិក្សាត្រូវបានរៀបចំកសាងឡើងវិញនៅទូទាំងប្រទេស ។ ការអប់រំជាមូលដ្ឋានដែលរួមមានទាំងការអប់រំពីរបបខ្មែរក្រហមផងត្រូវបានដាក់ឲ្យសិក្សានៅតាមសាលារៀន ។ សាលាបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានរៀបចំរៀចំជាថ្មីនៅទូទាំងប្រទេស ហើយអ្នកអប់រំមួយចំនួនត្រូវបានបញ្ជូនឲ្យទៅសិក្សានៅបរទេសជាពិសេសប្រទេសវៀតណាមនិងអតីតសហភាពសូវៀត ។

ទោះជាយ៉ាងនេះក្តី កម្ពុជានៅបន្តជួបប្រទះវិបត្តិធ្ងន់ធ្ងរផ្នែកសិក្សាអប់រំដដែល ។ អ្នកចេះដឹងដែលនៅរស់រានមានជីវិតភាគច្រើនបានរត់ចេញពីប្រទេសទៅព្រំដែន ។ ក្រសួងអប់រំជាតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជារួមមានមន្ត្រីបម្រើការមួយចំនួនតូច ដែលមិនមានសមត្ថភាពគ្រប់គ្រាន់និងមានបទពិសោធន៍និងជំនាញវិជ្ជាជីវៈតិចតួចក្នុងការអប់រំ ។ របបនេះមិនមានអ្នកជំនាញក្នុងការរៀបចំកម្មវិធីសិក្សា ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាពឹងផ្អែកទាំងស្រុងទៅលើជំនាញការនិងទីប្រឹក្សាវៀតណាមក្នុងការអប់រំនិងជ្រើសរើសគ្រូបង្រៀន ក៏ដូចជាការរៀបចំកម្មវិធីសិក្សានៅគ្រប់កម្រិតសិក្សាទាំងអស់ ។ រចនាសម្ព័ន្ធនិងការគ្រប់គ្រងការអប់រំមានលក្ខណៈប្រហាក់ប្រហែលទៅនឹងប្រព័ន្ធគ្រប់គ្រងនៅវៀតណាម ។ កម្មវិធីសិក្សាបានដាក់បញ្ចូល «វគ្គសិក្សានយោបាយ» ដែលមានបំណងបណ្តុះគំនិតសង្គមនិយមដល់កូនក្មេងក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងកម្ពុជាឲ្យទៅជារដ្ឋសង្គមនិយមមួយ ។

ក្នុងការខិតខំប្រឹងប្រែងជ្រើសរើសគ្រូបង្រៀនបន្ថែម សាធារណរដ្ឋប្រជាមានិតកម្ពុជាបានអំពាវនាវដល់អ្នកចេះដឹងទាំងអស់នៅទូទាំងប្រទេសឲ្យមកចុះឈ្មោះធ្វើជាគ្រូបង្រៀន ។ យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការសង្គ្រោះវិស័យអប់រំនៅពេលនោះគឺ «អ្នកចេះបង្រៀនអ្នកមិនសូវចេះ ហើយអ្នកមិនសូវចេះបង្រៀនអ្នកមិនចេះ» ។ រហូតមកដល់ដើមទសវត្សរ៍ឆ្នាំ១៩៨០ ចំនួនសិស្សដែលបានមកចុះឈ្មោះចូលរៀននូវគ្រប់កម្រិតមានជាងមួយលាននាក់ ហើយគ្រូបង្រៀនប្រមាណជា៣៧០០០នាក់ត្រូវបានជ្រើសរើសនិងហ្វឹកហាត់ ។ ជាអកុសល ក្នុងចំណោមគ្រូបង្រៀនទាំងនេះ មានតែ១០ភាគរយប៉ុណ្ណោះដែលមានកម្រិតវិជ្ជាក្នុងការអប់រំត្រឹមត្រូវ ។ អ្នកទាំងនេះធ្លាប់បានរៀនសូត្រចេះដឹងនៅមុនសម័យបដិវត្តន៍ គឺក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៥០និង១៩៦០ ។ ជាងនេះទៅទៀត បទពិសោធន៍ក្នុងរបបខ្មែរក្រហមបានបង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជាទាំងអស់ ។ គ្រូបង្រៀនភាគច្រើនមិនអាចផ្តោតការយកចិត្តទុកដាក់ទៅលើការបង្ហាត់បង្រៀនរបស់ខ្លួនទេ ដោយសារតែមានការព្រួយបារម្ភពីការបាត់ខ្លួនរបស់សមាជិកគ្រួសារនិងការប្រកបមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ។ ដោយទទួលរងនូវការឈឺចាប់ពីការធ្វើទុក្ខបុកម្នេញក្នុងរបបខ្មែរក្រហមនិងទទួលបានការហ្វឹកហ្វឺនតិចតួចផងគ្រូបង្រៀនភាគច្រើនបង្រៀនសិស្សអំពីរបបខ្មែរក្រហមទៅតាមអារម្មណ៍ឈឺចាប់របស់ខ្លួន ។ បន្ថែមពីលើសមត្ថភាពតិចតួចក្នុងការបង្ហាត់បង្រៀនប្រទេសកម្ពុជានៅពេលនោះជួបប្រទះនឹងបញ្ហាជាច្រើនផ្សេងទៀតដូចជាកង្វះខាតសម្ភារៈសិក្សា ហេដ្ឋារចនាសម្ព័ន្ធអប់រំ ប្រភពធានធានសម្រាប់គ្រូបង្រៀននិងសៀវភៅសិក្សា ។ នៅថ្នាក់ឧត្តមសិក្សាមានសិស្សប្រមាណ១០០នាក់ ក្នុងមួយឆ្នាំទទួលបានអាហារូបករណ៍ទៅសិក្សានៅតាមបណ្តាប្រទេសសង្គមនិយមមួយចំនួនដែលរួមមាន ប្រទេសវៀតណាម អតីតសហភាពសូវៀត អតីតអាល្លឺម៉ង់ខាងកើតនិងគុយបា ។ ការជ្រើសរើសត្រូវធ្វើឡើងដោយប្រយ័ត្នប្រយែងបំផុត ។

ជាទូទៅ ស្ថានភាពអប់រំក្នុងរយៈកាលនៃរបបសាធារណរដ្ឋ

ប្រជាមានិតកម្ពុជាស្ថិតក្នុងដំណើរការយឺតយ៉ាវ ។ របបនេះមិនត្រឹមតែតស៊ូដើម្បីដាក់កូនក្មេងឲ្យទទួលបានការរៀនសូត្រនៅតាមសាលាប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រយុទ្ធតទល់នឹងគ្រោះអវិជ្ជាក្នុងចំណោមមនុស្សវ័យជំទង់និងមនុស្សចាស់ បន្ថែមពីលើបញ្ហាសង្គមជាច្រើនផ្សេងទៀត ដែលរួមមានការវាយឆ្មក់ពីសំណាក់ក្រុមខ្មែរក្រហមជារៀងរាល់ថ្ងៃ និងទណ្ឌកម្មសេដ្ឋកិច្ចពីអន្តរជាតិ ។ ដោយសារតែជម្លោះនយោបាយអន្តរជាតិនិងឥទ្ធិពលពីសង្គ្រាមត្រជាក់ សាធារណរដ្ឋប្រជាមានិតកម្ពុជាមិនបានទទួលអាសនៈនៅអង្គការសហប្រជាជាតិទេ ។ របបនេះក៏មិនបានទទួលជំនួយអន្តរជាតិដែរ ដោយទទួលបានតែជំនួយមនុស្សធម៌ពីអង្គការអន្តរជាតិមួយចំនួនដូចជាអង្គការយូនីសេហ្វនិងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តីអង្គការទាំងនេះមិនអាចជួយអ្វីបានច្រើនទៅលើបញ្ហាអប់រំដែលកើតមានរួចទៅហើយ ដែលរួមទាំងការអប់រំពីរបបខ្មែរក្រហមផងទេ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានទទួលមរតកគឺបញ្ហានៃការអប់រំពីរបបខ្មែរក្រហម ។ ដោយរួមជាមួយនឹងបញ្ហាអសន្តិសុខចលាចលក្នុងសង្គមនិងប្រព័ន្ធសេដ្ឋកិច្ចគ្រប់គ្រងដោយរដ្ឋដ៏ទន់ខ្សោយផង សាធារណរដ្ឋប្រជាមានិតកម្ពុជាបានជួបប្រទះនូវពេលវេលាមួយដ៏លំបាកក្នុងការស្តារនីតិសម្បទានិងកសាងជាតិ ក៏ដូចជាកសាងប្រព័ន្ធអប់រំឡើងវិញនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ។ មេរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមមិនត្រូវបានកែសម្រួលឲ្យប្រសើរជាងមុន ហើយមិនដែលក្លាយទៅជាកង្វល់របស់ជាតិទេនៅពេលនោះ ។ ដូចដែលនឹងបញ្ជាក់នៅក្នុងផលវិបាកផ្នែកនយោបាយ កម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលរៀបចំឡើងដោយក្រសួងអប់រំជាតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺគ្រាន់តែជាឧបករណ៍នយោបាយដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃវត្តមានរបស់វៀតណាមនៅកម្ពុជាប៉ុណ្ណោះ ។

ការអប់រំក៏មានការរីកចម្រើនតិចតួចដែរ នៅក្នុងរយៈកាលអន្តរកាលនៃសម័យកាលអ៊ុនតាក់ ។ ដើម្បីរក្សាបរិយាកាសនយោបាយអព្យាក្រឹតនៅកម្ពុជា អ៊ុនតាក់បានធ្វើការគ្រប់គ្រងទៅលើក្រសួងសំខាន់ៗចំនួនប្រាំ ដែលរួមមានក្រសួងសន្តិសុខជាតិ ក្រសួងការពារជាតិ ក្រសួងការបរទេស ក្រសួងកិច្ចការ អគ្គកុងស៊ុល និងក្រសួងសេដ្ឋកិច្ច ។ អ៊ុនតាក់មិនបានត្រួតពិនិត្យមើលទៅលើក្រសួងអប់រំទេ ។ គ្រប់ភាគីនយោបាយទាំងអស់ផ្តោតការយកចិត្តទុកដាក់តែទៅលើស្ថិរភាពនយោបាយ សន្តិសុខជាតិ កំណែទម្រង់ប្រទេស យុទ្ធនាការឃោសនាបោះឆ្នោត និងអំណាចនយោបាយ និងយោធា ។ វត្តមានរបស់អ៊ុនតាក់ត្រូវបានរៀបចំឡើងដើម្បីធានាឲ្យបាននូវការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ដើម្បីស្វែងរកដំណោះស្រាយនយោបាយរួមមួយនៅកម្ពុជា ។ សិទ្ធិអំណាចរបស់អ៊ុនតាក់រួមមាន «បញ្ហាទាក់ទងនឹងសិទ្ធិមនុស្ស ការរៀបចំចាត់តាំងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោត ការរៀបចំកងកម្លាំងយោធា រដ្ឋបាលស៊ីវិល រក្សាការគោរពច្បាប់និងសណ្តាប់ធ្នាប់សង្គម ការធ្វើមាតុភូមិនិវត្តន៍ និងការតាំងទីលំនៅជាថ្មីរបស់ជនភៀសខ្លួន ជនគ្មានទីជម្រក និងការស្តារនីតិសម្បទា ហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា» ។ អ៊ុនតាក់មានអំណាចតិចតួចណាស់ក្នុងការធ្វើអន្តរាគមន៍ទៅលើកំណែទម្រង់ប្រព័ន្ធអប់រំ ។ ប្រព័ន្ធអប់រំបានបន្តដំណើរការនៅក្រោមរដ្ឋបាលគ្រប់គ្រងរបស់រដ្ឋកម្ពុជាដែលមានស្រាប់ ។ ហេតុដូច្នេះមានការផ្លាស់ប្តូរទៅលើការសិក្សាអប់រំបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងរយៈកាលអន្តរកាលនេះ ។ សិស្សបន្តសិក្សាតាមកម្មវិធីសិក្សាចាស់ ។ ការប្រឹងប្រែងណាមួយដើម្បីកែសម្រួលការអប់រំពីអំពើប្រល័យពូជសាសន៍មិនដែលស្ថិតក្នុងបញ្ជីអាទិភាពរបស់រដ្ឋាភិបាលនៅពេលនោះទេ ។

បន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ១៩៩៣ រដ្ឋាភិបាលថ្មីបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការអប់រំនៅគ្រប់កម្រិតទាំងអស់ ។ រហូតមកទល់ឆ្នាំ២០០៧ សាលាសម្រាប់កម្រិតបឋមសិក្សានិងមធ្យមសិក្សារាប់ពាន់កន្លែងត្រូវបានកសាងឡើងនៅទូទាំងប្រទេស ទោះបីជាគុណភាពនៃការអប់រំនិងជីវភាពរស់នៅរបស់គ្រូបង្រៀនមិនទាន់ត្រូវបានយកចិត្តទុកដាក់នៅឡើយក៏ដោយ ។ រហូតមកទល់នឹងបច្ចុប្បន្ននេះ មានសាកលវិទ្យាល័យរដ្ឋនិងឯកជនយ៉ាងតិចចំនួន៦០ត្រូវបានបង្កើតឡើង ។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការសម្រេចឲ្យបាននូវផែនការជាយុទ្ធសាស្ត្រនៃការអប់រំ ដែលមានគោលដៅធានាឲ្យបានថាកុមារទាំងអស់នឹងមានលទ្ធភាពទទួលបានការអប់រំស្មើៗគ្នានៅឆ្នាំ២០១៥ ។

ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានដោះ

ស្រាយបញ្ហាសង្គមនិងសេដ្ឋកិច្ច ដែលកត្តានេះនឹងនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើគោលដៅនៃការអប់រំនៅឡើយ ។ សំខាន់ជាងនេះទៅទៀត ប្រសិនបើរាជរដ្ឋាភិបាលមិនអាចដោះស្រាយបញ្ហាទាំងអស់នេះបាន វានឹងមិនអាចទៅរួចទេដែលថារាជរដ្ឋាភិបាលនឹងអាចលើកយកបញ្ហាសំខាន់របស់ជាតិផ្សេងៗទៀតមកដោះស្រាយ ដូចជាការអប់រំសិស្សពីអំពើប្រល័យពូជសាសន៍និងសិទ្ធិមនុស្ស ដែលមានសារសំខាន់ក្នុងការធានាឲ្យបានសន្តិភាព ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងការគោរពច្បាប់នៅកម្ពុជា ក៏ដូចដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ដែលអាចកើតមានឡើងនាពេលអនាគត ។ ដូច្នេះ តើអ្វីខ្លះជាផលវិបាកផ្នែកសង្គមនិងសេដ្ឋកិច្ចសម្រាប់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ននេះ? តើរាជរដ្ឋាភិបាលគួរធ្វើអ្វីខ្លះដើម្បីដោះស្រាយនូវផលវិបាកទាំងអស់នេះ?

មកទល់នឹងឆ្នាំ២០០២ ដោយមានជំនួយពីសហគមន៍អន្តរជាតិ ជាពិសេសពីធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលអាចចំណាយ១២ភាគរយនៃថវិកាជាតិទៅលើការអប់រំ ។ ទោះជាយ៉ាងនេះក្តីគ្រប់គម្រោងផែនការទាំងអស់ គឺផ្តោតតែទៅលើការអប់រំទូទៅ ហើយមានការខិតខំប្រឹងប្រែងតិចតួចក្នុងការពិភាក្សាអំពីការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហម ។

**(នៅមានត)**

**ឌី ខាំបូលី**

***(តមកពីទំព័រ២៤)*** នៅជំរំជនភៀសខ្លួន ប្រន បានផ្ញើសំបុត្រមួយទៅ ស្តែនបឺក ។ ស្តែនបឺក បានចាកចេញពីសហរដ្ឋអាមេរិកយ៉ាងប្រញាប់ប្រញាល់ដើម្បីទៅជួបមិត្តភក្តិរបស់គាត់នៅជំរំដែលបានបែកគ្នាអស់រយៈពេលជាងបួនឆ្នាំ ។

បន្ទាប់ពី ប្រន បានមកដល់សហរដ្ឋអាមេរិក កាសែតថៃមស៍បានឲ្យគាត់បម្រើការនៅក្នុងការិយាល័យថតរូប ។

ប្រន គឺជាមនុស្សដំបូង បង្ហាញពី «វាលពិឃាត» ដែលមានសាកសពជាច្រើនដ៏គួរឲ្យភ័យខ្លាច និងផ្លូវរបស់ជនរងគ្រោះ ហើយគាត់ព្យាយាមធ្វើដំណើរដោយអស់សង្ឃឹមដើម្បីស្វែងរកសេរីភាព ។

ប្រន តែងតែរៀបរាប់និងសរសេរអំពីបទពិសោធន៍ឆ្លងកាត់នៅក្នុងអំឡុងពេលសង្គ្រាម និងទិតៀនដោយឥតលាក់លៀមអំពីរបបខ្មែរក្រហម ។

នៅពេល ប៉ុល ពត ស្លាប់នៅឆ្នាំ១៩៩៨ ប្រន បានសម្តែងការសោកស្តាយដែលអ្នកកាន់លទ្ធិផ្តាច់ការរូបនេះមិនបានទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ។

ស្តែនបឺក និយាយថា «ប្រន គឺជាអ្នកសារព័ត៌មានស្វែងរកការពិតម្នាក់សម្រាប់ប្រជាជន ។ ពេលដែលជំងឺមហារីករបស់គាត់ធ្វើទុក្ខ គាត់ព្យាយាមរស់ម្តងទៀត ។ គាត់ធ្វើខ្លួនឲ្យនៅស្ងប់និងក្លាហានដូចជាព្រះពុទ្ធ ទឹកចិត្តដ៏ល្អរបស់គាត់ធ្វើឲ្យគាត់មានលក្ខណៈពិសេស» ។

អ្នកថតរូបឲ្យសារព័ត៌មាន អេភី ឈ្មោះ ពល សាគូម៉ា ដែលស្គាល់ ប្រន តាមរយៈធ្វើការនៅសមាគមអ្នកកាសែតអាស៊ី-អាមេរិកនិយាយថា ប្រន គឺជា «អ្នកថតរូបអាមេរិកដែលស្នេហាជាតិ ដែលខ្ញុំមិនដែលបានជួបដែលតែងតែនិយាយថាគាត់ស្រឡាញ់អាមេរិកក្រៃលែង» ។



ឌិត ប្រន

បងប្អូនប្រុសបីនាក់របស់ ប្រន ត្រូវខ្មែរក្រហមសម្លាប់នៅក្នុងរបបនោះ ។ ចំណែកអ្នកដែលនៅរស់ មានមិត្តភក្តិរបស់គាត់ ឈ្មោះ បេទីប៉ាស្ទ័រ, ប្រពន្ធដើមរបស់គាត់ ឈ្មោះ មឿន សើ ឌិត បងស្រីឈ្មោះ សមព្រីថ ឌិត ណុប ។ កូនប្រុសឈ្មោះ ទីតូនី, ទីតូណាត, ទីតូណែល និងកូនស្រីឈ្មោះ ហែមការ៉េ ឌិត តន និងចៅៗជាច្រើននាក់ ។

**សរសេរដោយ លី សុផល**

# រូបថតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ











# ប្រវត្តិនិងតម្លៃញត្តិរណសិរ្សចំពោះដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា

នៅឆ្នាំ១៩៨២និងឆ្នាំ១៩៨៣ ប្រជាជនរាប់រយនាក់ក្នុងចំណោមប្រជាជនរាប់ពាន់នាក់ដែលរស់រានមានជីវិតពីរបបខ្មែរក្រហមបានសរសេរនិងចុះហត្ថលេខាលើញត្តិដើម្បីឆ្លើយតបនឹងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបង្កើតឡើងដោយវៀតណាម ព្រមទាំងស្នើសុំឲ្យអង្គការសហប្រជាជាតិទទួលស្គាល់ឧក្រិដ្ឋកម្មដ៏ឃោរឃៅរបស់ខ្មែរក្រហម និងដកអ្នកតំណាងខ្មែរក្រហមចេញពីកៅអីរបស់អង្គការសហប្រជាជាតិ ។ ញត្តិជាច្រើនដែលប្រមូលបានពីជនរងគ្រោះត្រូវបានស្គាល់ជាឯកសារណសិរ្សនិងដែលមានចំនួនច្រើនរាប់ពាន់ច្បាប់ ។

ជាញឹកញាប់ អ្នកសរសេរញត្តិបានរៀបរាប់អំពីសេចក្តីលម្អិតគួរឲ្យភ័យខ្លាចនិងទុក្ខវេទនារបស់ខ្លួន ព្រមទាំងប្រជាជនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។ ញត្តិតែងតែបានកត់ត្រាពីចំនួនប្រជាជននៅក្នុងភូមិដែលបានស្លាប់ ឬបាត់ខ្លួន ការខូចខាតផ្ទះសម្បែង ការសម្លាប់សត្វ យុទ្ធសាស្ត្រនៃការដាក់ទណ្ឌកម្មរបស់ខ្មែរក្រហម ទីតាំងនៃរណ្តៅសាកសពនិងការប្រមាថទៅលើវត្តអារាមព្រះពុទ្ធសាសនាជាដើម ។ ដោយសារញត្តិមានព័ត៌មានជាច្រើនដែលមានតម្លៃ ដូច្នេះឯកសាររណសិរ្សគឺជាឯកសារមួយសំខាន់និងមានសារប្រយោជន៍ទាក់ទងនឹងខ្មែរក្រហម ។ ឯកសារនេះថែមទាំងបានបញ្ចូលបញ្ជីឈ្មោះនិងលំនៅស្ថានរបស់ជនរងគ្រោះដែលមានសារសំខាន់ចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ***ការបង្កើតគណៈកម្មាធិការស្រាវជ្រាវ និង របាយការណ៍***

ញត្តិរណសិរ្សត្រូវបានសរសេរនិងចងក្រងចាប់តាំងពីខែសីហាដល់តុលាឆ្នាំ១៩៨៣ ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ពីខ្មែរក្រហមបាត់បង់អំណាច ។ ដំណើរការដែលបង្កឲ្យមានញត្តិតាំងពីថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៨២ គឺនៅពេលដែលក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលជាអង្គភាពរបស់រដ្ឋាភិបាលសាធារណរដ្ឋ



*សកម្មភាពបំពេញពាក្យបណ្តឹងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា*

ប្រជាមានិតកម្ពុជាបានបង្កើតគណៈកម្មាធិការស្រាវជ្រាវឧក្រិដ្ឋកម្មមានភារកិច្ចស៊ើបអង្កេតឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ ក្រុមរណសិរ្សសាមគ្គីបង្កើតជាគណៈកម្មាធិការស្រាវជ្រាវ គឺដើម្បីរៀបរៀងជាស្ថិតិច្បាស់លាស់មួយអំពីចំនួនប្រជាជនដែលបានស្លាប់ បែបបទនៃទណ្ឌកម្មចំពោះប្រជាជននិងទំហំនៃការខូចខាតទ្រព្យសម្បត្តិ ។

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៨៣ បន្ទាប់ពីការស្រាវជ្រាវរយៈពេល៩ខែ គណៈកម្មាធិការស្រាវជ្រាវបានបោះពុម្ពផ្សាយរបាយការណ៍មួយ (របាយការណ៍គណៈកម្មាធិការស្រាវជ្រាវ) ដោយមានតារាងសង្ខេបស្ថិតិចំនួនប្រជាជនដែលបានស្លាប់នៅតាមខេត្តនីមួយៗ ។ គណៈកម្មាធិការបានបង្ហាញថា អ្នកធ្វើញត្តិជាងមួយលាននាក់ក្នុង១៩ខេត្តបានផ្តល់ព័ត៌មាននៅក្នុងរបាយការណ៍ ។ របាយការណ៍នេះត្រូវបានបង្ហាញនៅចំពោះមុខក្រុមរណសិរ្សសាមគ្គីនិងសភាជាតិនៅខែសីហា ឆ្នាំ១៩៨៣ ។ ទាំងក្រុមរណសិរ្សសង្គ្រោះជាតិនិងសភាជាតិបានយល់ព្រម និងចេញសេចក្តីសម្រេចជាផ្លូវការថា យល់ព្រមទទួលស្គាល់របាយការណ៍និងសេចក្តីសម្រេចនេះ ។

## សន្និសីទនៃបញ្ញវន្តនិងព្រះសង្ឃកម្ពុជា

បន្ទាប់ពីសភាជាតិបានពន្យល់និងបកស្រាយឲ្យយល់អំពីរបាយកាណ៍ស្រាវជ្រាវរបស់គណៈកម្មាធិការស្រាវជ្រាវឃើញថារបាយការណ៍នេះសំដៅផ្ទាល់ទៅលើប្រជាជនកម្ពុជាដើម្បីឲ្យប្រជាជន «បង្ហាញ»ពីឧក្រិដ្ឋកម្មនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។ ប៉ុន្មានសប្តាហ៍ក្រោយមកនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៣ ក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបើកសន្និសីទមួយនៅភ្នំពេញដែលមានចំណងជើងថា «សន្និសីទនៃបញ្ញវន្តនិងព្រះសង្ឃកម្ពុជា» ។ នៅថ្ងៃនោះ មានបញ្ញវន្តជាង៣០០នាក់ ព្រះសង្ឃ និងក្រុមអ្នកតំណាងប្រជាជនកម្ពុជាមួយចំនួនបានប្រមូលផ្តុំគ្នាដើម្បីស្តាប់សេចក្តីសម្រេចអំពីរបាយការណ៍គណៈកម្មាធិការស្រាវជ្រាវ ព្រមទាំងគោរពតាមសេចក្តីសម្រេចរបស់ក្រុមរណសិរ្សសង្គ្រោះជាតិកម្ពុជានិងសភាជាតិ ។ បន្ទាប់មក ក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងសភាជាតិបានឆ្លើយតបនឹងលិខិតដែលត្រូវបានផ្ញើឲ្យបញ្ញវន្ត ព្រះសង្ឃ អង្គការអន្តរជាតិនិងប្រជាជនទូទាំងប្រទេសដើម្បីធ្វើឲ្យគេជឿថា ខ្មែរក្រហមគួរតែបណ្តេញចេញពីអាសនៈនៅអង្គការសហប្រជាជាតិ ។ សន្និសីទនេះបានសរសេរលិខិតចំនួន៧ដែលបង្ហាញពីយោបល់និងការព្រួយបារម្ភចំពោះអ្នកអប់រំ អ្នកជំនាញការសុខភាព សិល្បករ ព្រះសង្ឃ ប្រជាជនកម្ពុជាមួយចំនួនតូច គ្រួសារព្រះរាជវង្ស និងសន្និសីទទាំងមូល ។

## ការជួបពិភាក្សាជាសាធារណៈនិងញត្តិព្រាង

នៅអំឡុងពេល២ខែនៃសន្និសីទរបស់បញ្ញវន្តនិងព្រះសង្ឃកម្ពុជា ក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរៀបចំការប្រជុំជាសាធារណៈនៅកម្ពុជា ។ ការជួបពិភាក្សាទាំងនេះបានបង្កើតឡើងតាមភូមិនិងឃុំដើម្បីជួបពិភាក្សាអំពីរបាយការណ៍របស់គណៈកម្មាធិការស្រាវជ្រាវ សេចក្តីសម្រេចរបស់សភាជាតិនិងលិខិតចំហសន្និសីទ ។ វានៅតែមិនទាន់ច្បាស់ថា មានអ្នកចូលរួមប៉ុន្មាននាក់នៅក្នុងការប្រជុំនេះ ។ ប៉ុន្តែអនុប្រធានភូមិម្នាក់ដែលបានចូលរួមក្នុងការប្រជុំមួយបាននិយាយថា មានប្រជាជនរាប់រយនាក់នៅក្នុងភូមិគាត់ចូលរួម ។

ប្រជាជនដែលចូលរួមប្រជុំបានពិភាក្សាគ្នាអំពីការយល់ឃើញរបស់ខ្លួនចំពោះការអធិប្បាយនិងការសរសេរញត្តិជាសមូហភាពឬដោយម្នាក់ៗ ដែលទាំងអស់នេះក្លាយជាផ្នែកមួយនៃការប្រមូលញត្តិរណសិរ្ស ។ ស្ទើរតែគ្រប់ញត្តិទាំងអស់ដែលអាជ្ញាធរបានត្រួតពិនិត្យបានអះអាងថា មុននឹងមានហត្ថលេខាយល់ព្រមនៅក្នុងញត្តិនីមួយៗ អ្នកសរសេរញត្តិបានស្តាប់របាយការណ៍គណៈកម្មាធិការស្រាវជ្រាវ សេចក្តីសម្រេចរបស់សភាជាតិនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៣ និងលិខិតចំហមុនពេលដែលចុះហត្ថលេខា ។ អ្នកចូលរួមមួយចំនួនបានគាំទ្រដំណើរនៃព្រឹត្តិការណ៍នេះ ។

ញត្តិព្រាងដំបូងត្រូវបានចងក្រងនិងបញ្ជូនទៅឲ្យក្រុមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ ក្រុមរណសិរ្សសាមគ្គីបានសរុបចំនួនញត្តិនិងហត្ថលេខា ហើយបែងចែកញត្តិនេះទៅតាមខេត្តនិងក្រសួងរដ្ឋាភិបាល ។ បន្ទាប់មកបង្កើតជាសេចក្តីសម្រេចនៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ១៩៨៣ ដែលមានចំណងជើងថា «សេចក្តីសង្ខេបនៃញត្តិគាំទ្រសេចក្តីសម្រេចរបស់សភាជាតិនិងលិខិតចំហរបស់បញ្ញវន្តនិងព្រះសង្ឃ» ។ សេចក្តីសង្ខេបនៅក្នុងញត្តិបានបញ្ជាក់ថាញត្តិត្រូវបានប្រមូលមកពីខេត្តចំនួន១២និង២២មកពីក្រសួងរដ្ឋ

ជាសរុបមាន៨៨៣២ញត្តិនិងមានហត្ថលេខាចំនួន៩៦០.១៩៤ ។

អ្វីដែលកើតឡើងចំពោះញត្តិបន្ទាប់ពីក្រុមរណសិរ្សសាមគ្គីបានប្រមូលគឺនៅតែជាអាថ៌កំបាំង ។ ទោះបីជាញត្តិភាគច្រើនមានបំណងចង់ឲ្យអង្គការសហប្រជាជាតិបណ្តេញខ្មែរក្រហមចេញពីអាសនៈកម្ពុជា ប៉ុន្តែញត្តិមិនបានបញ្ជូនទៅឲ្យអង្គការសហប្រជាជាតិទេដោយមានហេតុផលអាថ៌កំបាំងខ្លះ ។ ញត្តិមួយចំនួនធំត្រូវបានរក្សាទុកនៅការិយាល័យក្រុមរណសិរ្សសាមគ្គីរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជារហូតដល់ឆ្នាំ១៩៩៧ ទើបញត្តិនេះត្រូវបានប្រគល់មកឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ស្ទើរតែ៩០០០ញត្តិគឺជាញត្តិព្រាង ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលស្គាល់តែញត្តិប្រហែលជា១២៥០ប៉ុណ្ណោះ ឯញត្តិដែលនៅសល់មិនត្រូវបានទទួលស្គាល់ទេ ។

**ការពិពណ៌នាពីញត្តិរណសិរ្សនិងមាតិការបស់ញត្តិ**

ញត្តិរណសិរ្សភាគច្រើនគឺជាញត្តិក្រុមដែលអាចបែងចែកជា៣ផ្នែក ។ ផ្នែកទីមួយគឺផ្អែកទៅលើទីតាំងភូមិសាស្ត្រដូចជាតាមភូមិ ឃុំ ស្រុក និងខេត្ត ។ ផ្នែកទីពីរបង្ហាញពីក្រុមការងារ ដូចជាកម្មករដាំកៅស៊ូនៅកម្ពុជា ការិយាល័យអប់រំនិងសម្ភារៈថ្នាំពេទ្យ ។ ផ្នែកតូចមួយដែលជាផ្នែកពិសេសនៃញត្តិបង្ហាញពីសាសនាផ្សេងៗគ្នានិងក្រុមមួយចំនួនតូច ។ សណ្ឋានទូទៅនៃញត្តិនៅក្នុងផ្នែកនេះគឺជាព្រះសង្ឃខាងសាសនាព្រះពុទ្ធ និងសមាជិកចាមមូស្លីមភាគតិចមួយចំនួន ។ ជាទីបញ្ចប់ ការប្រមូលឯកសាររណសិរ្សរួមមានទាំងញត្តិជាច្រើនត្រូវបានត្រួតពិនិត្យនិងហត្ថលេខាម្នាក់ៗ ។

ទោះបីជាឯកសាររណសិរ្សទាំងអស់នេះ ត្រូវបានបង្កើតឡើងដោយក្រុមបុជាលក្ខណៈម្នាក់ៗក៏ដោយ ក៏វានៅតែមានលក្ខណៈដូចគ្នាមួយចំនួនដែរ ។ ស្ទើរតែគ្រប់ញត្តិសុទ្ធតែបរិហារ «ប៉ុលពតអ្នកនៅក្រោមបង្គាប់និងអ្នកវិត្ថារនិយមប៉េកាំង» ហើយបង្ហាញពីការគាំទ្រចំពោះបក្សកម្មុយនីស្តនិងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ញត្តិភាគច្រើនក៏បានរួមបញ្ចូលការប្តឹងតវ៉ាដោយផ្ទាល់ទៅកាន់អង្គការសហប្រជាជាតិ សភាជាតិប្តិភពលោក ដើម្បីដាក់សម្ពាធឲ្យ «បណ្តេញ ប៉ុល ពត ចេញពីអាសនៈនៅអង្គការសហប្រជាជាតិព្រមទាំងសុំឲ្យអង្គការសហប្រជាជាតិផ្តល់អាសនៈទៅឲ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាវិញ» ។ តួយ៉ាងដូចជា ញត្តិបុគ្គលម្នាក់ៗសុំឲ្យ «សម័យប្រជុំលើកទី៣៨របស់អង្គការសហប្រជាជាតិសុំបណ្តេញបិសាចហុតឈាមនេះចេញពីអាសនៈនៅអង្គការសហប្រជាជាតិជាបន្ទាន់» ។ ញត្តិផ្សេងទៀតបានសរសេរថា នាងត្រូវបានបង្ខំឲ្យសន្យាថានឹង «ដើរតាមលទ្ធិម៉ាកលេនីនជារៀងរហូត» ។ ហើយថានាងទទួលស្គាល់តែបក្សសាធារណរដ្ឋប្រជាមានិតកម្ពុជាមួយគត់ថាជា «រដ្ឋាភិបាលស្របច្បាប់» ។ ព្រះសង្ឃមួយក្រុមពីភូមិអង្គស្នោតខេត្តតាកែវបានស្នើឲ្យសភាជាតិ «បញ្ជូនញត្តិរបស់ខ្លួនទៅកាន់អង្គការសហប្រជាជាតិដើម្បីបណ្តេញបក្សពួកប៉ុលពតចេញពីអាសនៈនៅអង្គការសហប្រជាជាតិ» ។ ក្រុមព្រះសង្ឃផ្សេងទៀតនៅខេត្តកំពតស្នើសុំ «ពិភពលោកបង្ខំឲ្យអ្នកវិត្ថានិយមប៉េកាំងនិងពួកចក្រពត្តិអាមេរិក ព្រមទាំងអ្នកមិនចង់ឲ្យមានការផ្លាស់ប្តូរ-នយោបាយមួយចំនួនបញ្ឈប់ជំនួយឧបត្ថម្ភបក្សពួកប៉ុលពត និងបណ្តេញចេញពីអង្គការសហប្រជាជាតិមួយរំពេច» ។

ក្រៅពីរបាយការណ៍ដែលរៀបរាប់ដដែលៗនេះ ញត្តិមានភាពខុសគ្នាជាច្រើនចំពោះរយៈពេលនិងសេចក្តីសង្ខេប ។ ញត្តិខ្លះពណ៌នាពីការជួបពិភាក្សាចំពោះការអានរបាយការណ៍គណៈកម្មា-ធិការស្រាវជ្រាវនិងការសរសេរញត្តិ ។ ខ្លះកត់ត្រាពីចំនួនប្រជាជនដែលបានស្លាប់នៅក្នុងតំបន់ជាក់លាក់ណាមួយ ខ្លះបង្ហាញពីយុត្តិសាស្ត្រដែលប្រជាជនត្រូវបានសម្លាប់ ខ្លះបង្ហាញពីទីតាំងនៃរណ្តៅសាកសពរួម ។ ដូចជា ព្រះសង្ឃមួយក្រុមនៅស្រុកត្រាំកក់ខេត្តតាកែវ បានសរសេរញត្តិមួយដែលមានរាប់បញ្ចូលចំនួនវត្តដែលត្រូវបានបំផ្លាញនៅក្នុងឃុំរបស់ខ្លួន ចំនួនព្រះសង្ឃដែលត្រូវបានបង្ខំឲ្យសឹកនិងចំនួនរណ្តៅសាកសពរួមហើយនិងចំនួនសាកសពនៅក្នុងរណ្តៅនីមួយៗ ។

ញត្តិមួយចំនួនធំមិនបានផ្តល់ពីព័ត៌មានផ្ទាល់ខ្លួនឡើយ ។ ដូចជាញត្តិមួយពីខេត្តកំពតគ្រាន់តែរៀបរាប់ពីបញ្ហាធម្មតាដូចជាកម្មាភិបាលខ្មែរក្រហមសម្លាប់អ្នកធ្វើការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិ ព្រមទាំងប្រើប្រាស់សាលារៀននិងវត្តធ្វើជាគុកប្រក្រាលសត្វ ។ ស្រដៀងគ្នានេះដែរ ក្រុមតំណាងជនជាតិភាគតិចចាមនៅខេត្តសៀមរាបបានសរសេរញត្តិមួយពិពណ៌នាពីបទពិសោធន៍ទូទៅរបស់ចាមនៅទីនោះ ។ ញត្តិរៀបរាប់អំពីដំណើរដែលមូស្លីមត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ហើយប្រសិនបើខ្លួន

បដិសេធនឹងត្រូវសម្លាប់ចោល ។ ព្រះវិហារអ៊ីស្លាមដែលត្រូវបានកែប្រែទៅជាទ្រុងសត្វឬក៏កន្លែងដាក់លាមក កម្មាភិបាលខ្មែរក្រហមប្រើប្រាស់គម្ពីគូរ៉ានធ្វើជាក្រដាសប្រើក្នុងបន្ទប់ទឹកនិងក្រដាសមូរបារី ។ ប៉ុន្តែញត្តិនេះមិនបានបញ្ចូលសេចក្តីលម្អិតពីព្រឹត្តិការណ៍ដែលកើតឡើងជាពិសេសចំពោះខ្លួនឡើយ ។

ផ្ទុយមកវិញ ញត្តិម្នាក់ៗតែងតែមានរួមបញ្ចូលការសម្ងាត់ផ្ទាល់ខ្លួនដោយមានសេចក្តីលម្អិតពីមួយទៅពីរទំព័រទាក់ទងនឹងបទពិសោធន៍ផ្ទាល់របស់អ្នកសរសេរញត្តិ ។ យ៉ាងណាមិញ អ្នកធ្វើញត្តិម្នាក់បានសរសេររៀបរាប់ពីការដែលគាត់ត្រូវបានបង្ខំឲ្យចេញពីទីក្រុងភ្នំពេញ ប៉ុន្តែគាត់ត្រូវបានហាមឃាត់មិនឲ្យត្រឡប់ទៅរស់នៅផ្ទះរបស់គាត់វិញឡើយ ។ គាត់និយាយថា ប្តីរបស់គាត់ត្រូវបានហៅឲ្យទៅធ្វើការ ប៉ុន្តែក្រោយមកបែរជាត្រូវសម្លាប់ទៅវិញ ហើយបងប្រុសនិងបងស្រីរបស់គាត់ក៏ត្រូវបានស្លាប់ដែរ ។ គាត់ថែមទាំងបកស្រាយទៀតថា នៅឆ្នាំ១៩៧៧ ប្រជាជននៅក្នុងភូមិគាត់ត្រូវបានបំបែកជាពីរក្រុម គឺប្រជាជនចាស់និងប្រជាជនថ្មី ។ ជាឧទាហរណ៍មួយទៀតអ្នកសរសេរញត្តិម្នាក់ទៀតបានរៀបរាប់លម្អិតអំពីខ្លួនគាត់បានជាប់គុកនិងការទទួលទណ្ឌកម្មរបស់គាត់ ។

## តម្លៃរបស់ញត្តិរណសិរ្សចំពោះដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មានការផ្តល់យោបល់ថា ការបង្ហាញការគាំទ្រសាធារណរដ្ឋប្រជាមានិតកម្ពុជា និងការបរិហារកេរ្តិ៍ខ្មែរក្រហមនៅក្នុងញត្តិប្រហែលជាធ្វើឲ្យញត្តិនេះមិនអាចប្រើការនៅក្នុងអង្គជំនុំជម្រះ ។ វាពិតថា ញត្តិត្រូវបានបង្កើតឡើងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ភាសាដូចៗគ្នានៅក្នុងញត្តិបង្ហាញឲ្យឃើញថាភាសាទាំងនេះគឺជាលទ្ធផលនៃការប្រើងប្រែងត្រួតពិនិត្យកម្រិតខ្ពស់ ។ ជាងនេះទៅទៀត អ្នកធ្វើញត្តិម្នាក់បានអះអាងនៅក្នុងការសម្ភាសមួយថា គាត់បានទទួលការណែនាំពីក្រុមរណសិរ្សសាមគ្គីចំពោះភាសាដែលគួរតែបញ្ចូលនៅក្នុងញត្តិ ។ យ៉ាងណាមិញ ទិដ្ឋភាពនយោបាយរបស់ញត្តិមិនគួរបន្ថយតម្លៃនិងការជឿទុកចិត្តចំពោះមាតិការឿងរបស់អ្នកធ្វើញត្តិឡើយ ។ របបខ្មែរក្រហមបានបញ្ចប់នៅក្នុងរយៈពេលតែប៉ុន្មានឆ្នាំមុនពេលដែលអ្នកភូមិព្រះសង្ឃ និងកម្មករកម្ពុជាបានសរសេរនិងចុះហត្ថលេខាលើញត្តិដូច្នេះការចងចាំនិងការឈឺចាប់របស់ខ្លួនហាក់ដូចជានៅថ្មីៗ ។ រហូតមកដល់សព្វថ្ងៃនេះប្រជាជនកម្ពុជាមិនមានឱកាសប្រាប់ពិភពលោកអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន ហើយប្រជាជនជាច្រើនយល់ថា ញត្តិជាឱកាសមួយដើម្បីបង្ហាញពិភពលោក ។ ជាងនេះទៅទៀត ការខំប្រឹងប្រែងធ្វើញត្តិប្រហែលអាចចាត់ទុកជាសកម្មភាពក្រៅផ្លូវការមួយរបស់ «គណៈកម្មការស្វែងរកការពិត» ។ នៅពេលថ្មីៗនេះ ប្រជាជនភាគច្រើនដែលត្រូវបានសម្ភាសន៍អំពីការចូលរួមបង្កើតញត្តិបង្ហាញថា ការចុះហត្ថលេខាលើញត្តិគឺជាការស្ម័គ្រចិត្តហើយមិនមែនជាភារកិច្ចឬត្រូវបានបង្ខំទេ ។ លើសពីនេះទៀត អ្នកធ្វើញត្តិជាច្រើនបានអះអាងថា ព័ត៌មានដែលបានសរសេរនៅក្នុងញត្តិគឺជាការពិត ហើយនៅតែអាចបញ្ជាក់ថាវាពិតរហូតដល់សព្វថ្ងៃ ។ ជាឧទាហរណ៍ អ្នកធ្វើញត្តិម្នាក់បាននិយាយថា គាត់មិនត្រូវបានបង្ខំឬដាក់សម្ពាធឲ្យសរសេរញត្តិរបស់គាត់ទេ ។ គាត់សរសេរញត្តិនេះដោយការស្ម័គ្រចិត្ត ហើយគាត់បានអះអាងថា ព័ត៌មានទាំងអស់នៅក្នុងញត្តិគឺជាការពិត ។ ដូច្នេះហើយ រឿងរ៉ាវរបស់គាត់គួរតែមានតម្លៃជាឯករាជ្យដោយមិនពាក់ព័ន្ធនឹងនយោបាយរបស់រដ្ឋាភិបាលនៅពេលនោះទេ ។

បន្ថែមទៅតម្លៃរបស់ញត្តិដែលជាភស្តុតាងដ៏មានសារសំខាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ញត្តិអាចធ្វើជាយុត្តិសាស្ត្រដើម្បីស្វែងរកជនរងគ្រោះដែលចង់ចូលរួមដំណើរការអង្គជំនុំជម្រះ ។ ដូចដែលបានពិភាក្សានៅក្នុងអត្ថបទរបស់ សារ៉ាថូម៉ាស និង សូហ្វារីណា ចំពោះបញ្ហានេះបានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមគម្រោងចូលរួមរបស់ជនរងគ្រោះដែលមានជំនួយពីញត្តិរណសិរ្ស គម្រោងនេះនឹងជួយឲ្យដឹងពីទីលំនៅរបស់អ្នកដែលនៅរស់ពីរបបខ្មែរក្រហមហើយផ្តល់ព័ត៌មានឲ្យអ្នកនៅរស់គិតថានឹងចូលរួមដំណើរការកាត់ក្តីឬក៏អត់ ។ ញត្តិបានផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាធម្មតាចូលរួមជាទម្រង់ «គណៈកម្មការស្វែងរកការពិត»នៅឆ្នាំ១៩៨២-១៩៨៣ ផ្ងាស់ប្តូរហត្ថលេខាដើមនិងប្រាប់ជនរងគ្រោះថាការផ្តល់ជាកសិណសាក្សីឥឡូវនេះធ្វើឲ្យគាត់មានឱកាសចូលរួមសកម្មភាពម្តងទៀតដូចជាគណៈកម្មការនេះព្រមទាំងដឹងថាការផ្តល់កសិណសាក្សីពីមុនរបស់ខ្លួនមិនមែនគ្មានប្រយោជន៍នោះទេ ។ **វីល្យៀម ឌេ ស្កលថ៍**

# ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ៈ
# កំណែទម្រង់គតិយុត្តិ ផ្នែកព្រហ្មទណ្ឌជាតិនិងការផ្តល់អំណាចក្នុងតំបន់

***(តពីលេខមុន)***

***១) គុណវិបត្តិរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី***

*អ្នកអត្ថាធិប្បាយជាច្រើនយល់ស្របថា សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីជួបនូវវិបត្តិតិចតួចជាងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃប្រទេសរ៉្វាន់ដា ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងអំពើពុករលួយនិងកំហុសផ្នែកគ្រប់គ្រង បើទោះជាមានការបង្ហាញខ្លះៗពីភាពយឺតយ៉ាវនិងអសមត្ថភាពរបស់សាលាក្តីនេះក៏ដោយ ។ យ៉ាងណាមិញសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី ជួបប្រទះនូវបញ្ហាលំបាកយ៉ាងច្រើនដូចគ្នាទៅនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសរ៉្វាន់ដាដែរដែលកើតចេញមកពីភាពស្ថិតនៅដាច់ឆ្ងាយរបស់ខ្លួនខាងផ្នែកវប្បធម៌ខាងភាសានិងកត្តារូបសាស្ត្រៈ*

*អ្នកសង្កេតការណ៍មួយចំនួនជឿជាក់ថា សកម្មភាពរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីពិតជាបានបន្កនូវភាពរាំងស្ទះព្រោះថា ការចោទប្រកាន់របស់តុលាការបានធ្វើឲ្យការប្រឆាំងរបស់ពួកស៊ែបទៅនឹងអនុសញ្ញាសន្តិភាពកាន់តែខ្លាំងក្លាឡើង ។ ប្រជាពលរដ្ឋប៊ូស្នៀរ ស៊ែប ភាគច្រើនធ្វើការតវ៉ាថាសាលាក្តីនេះមានភាពលម្អៀង ពីព្រោះតែបានធ្វើការកាត់ទោសតែទៅលើពួកស៊ែបច្រើនជាងពួកក្រូអាត ឬអ្នកកាន់សាសនាមូស្លីមបើទោះជាអ្នកទាំងអស់នោះ សុទ្ធតែបានប្រព្រឹត្តនូវអំពើឃោរឃៅដូចគ្នាយ៉ាងណាក៏ដោយ ។ ខណៈពេលនោះដែរអ្នកកាន់សាសនាមូស្លីមជាច្រើនបានអះអាងថា ការកាត់ទោសទៅលើជនមូស្លីមគឺធ្វើឡើងដើម្បីជំទាស់ទៅនឹងការចោទប្រកាន់ពីភាពលម្អៀងរបស់ពួកស៊ែប ។ មិនថាមានហេតុផលណាទេទាំងពួកស៊ែបនិងមូស្លីមមានការរួញរាក្នុងការបញ្ជូនជនសង្ស័យដែលជាប់ចោទ ។*

*ក្រុមជាតិសាសន៍នានាជាញឹកញាប់មានការយល់ខុសចំពោះការងាររបស់តុលាការ ។ ការណ៍ដែលសាលាក្តីព្រហ្មទណ្ឌ*



*ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួបសាច់ញាតិរបស់ម្ចាស់ប្រវត្តិរូប*

អន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីមិនបានផ្សព្វផ្សាយនូវការងាររបស់ខ្លួននៅក្នុងប្រទេសប៊ូស្នៀ ពិសេសនៅក្នុងសហគមន៍ច្បាប់ ព្រមទាំងអវត្តមាននៃក្រុមអ្នកចូលរួមក្នុងប្រទេស ដូចជាក្រុមអ្នកសង្កេតការណ៍ជាដើម ។ ទាំងនេះធ្វើឲ្យច្បាប់ខមិនឡរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីដែលពុំមាននរណាស្គាល់ដែលប្រើសម្រាប់ដំណើរការយុត្តិធម៌ផ្នែកព្រហ្មទណ្ឌរឹតតែមានលក្ខណៈខុសប្លែកពីវិជ្ជាជីវៈច្បាប់នៅក្នុងប្រទេសថែមទៀត ។ ផ្អែកតាមការសិក្សាជាក់ស្តែងមួយដែលធ្វើឡើងក្នុងឆ្នាំ១៩៩៩ ដោយសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សប៊ឺកលី ទៅលើក្រុមតំណាងគំរូមួយនៃចៅក្រមនិងរដ្ឋអាជ្ញាប៊ូស្នៀដែលមានសមត្ថកិច្ចដំបូងប្ដឹងឧទ្ធរណ៍លើការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមក្នុងប្រទេសបញ្ជាក់យ៉ាងច្បាស់អំពីការយល់ឃើញខ្លះៗរបស់មេធាវីនិងចៅក្រមដែលមកពីក្រុមជាតិសាសន៍ទាំងឡាយនៅក្នុងប្រទេសបូស្នៀនិងហឺហ្សេហ្គោវីណា ។ ការសិក្សានោះបង្ហាញថាអ្នកផ្តល់បទសម្ភាសន៍ភាគច្រើនពុំបានទទួលព័ត៌មានគ្រប់គ្រាន់អំពីសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីទេ ហើយជានិច្ចកាលអ្នកទាំងនោះមានមន្ទិលសង្ស័យទៅលើសកម្មភាពនិងលទ្ធផលរបស់សាលាក្តីនេះ ។

ប្រជាជនស៊ែបនៅទូទាំងអតីតប្រទេសយូហ្គោស្លាវីពុំបានផ្តល់នូវការគាំទ្រជាពិសេសចំពោះសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីទេ ដោយបានចាត់ទុកថាតុលាការនេះជាការចាត់តាំងឡើងដោយលោកខាងលិច និងជិតដាមទៅដោយរបបគ្រប់គ្រងចក្រពត្តិនិយម ។ យោងទៅតាម Bogdan Ivanisevic នៃអង្គការឃ្លាំមើលសិទ្ធិមនុស្សបានឲ្យដឹងថា «ការរាយការណ៍មិនពិតនិងមិនត្រឹមត្រូវអំពីការងាររបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី គឺភាគច្រើន[ស្ថិតនៅពីក្រោយ]ឥរិយាបថជាអវិជ្ជមានដ៏ច្រើនលើសលប់របស់ប្រជាពលរដ្ឋស៊ែបទូទៅចំពោះសាលាក្តីក្រុងឡាអេ» ។ «ក្រុមអ្នករាយការណ៍ និងអ្នកវិភាគដ៏មានឥទ្ធិពលនៅក្នុងប្រទេសស៊ែប ដែលមិនពេញចិត្តទាល់តែសោះចំពោះសាលាក្តីដែលលាតត្រដាងនូវរឿងមិនពិតជាច្រើនអំពីការពិតនិងដែលពាក់ព័ន្ធទៅនឹងទិដ្ឋភាពការងារផ្នែកច្បាប់ពិតប្រាកដរបស់សាលាក្តីនោះ...ដែលផ្សព្វផ្សាយតាមរយៈប្រព័ន្ធសារព័ត៌មានដ៏លេចធ្លោបំផុតនៅក្នុងប្រទេសស៊ែប» ជាមួយការមិនទុកចិត្តមួយនិង «ដែលមានឥទ្ធិពលខ្លាំងប្រកបដោយហាយនភាពមកលើមតិសាធារណៈ» ។ ដូច្នេះ ប្រព័ន្ធសារព័ត៌មាននេះ «រឹតតែដុតកម្តៅកាន់តែខ្លាំងឡើងដែលជំរុញឲ្យមានការប្រមូលផ្តុំរួមគ្នាដ៏ធំមួយប្រឆាំងនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីនៅក្នុងសង្គមជាតិនៃប្រទេសស៊ែប» ។ ជាអកុសល របាយការណ៍លម្អៀងដែលបង្កើននូវការមិនជឿទុកចិត្តនៅក្នុងប្រទេសនិងបន្ថែមការអាក់អន់ចិត្តកាន់តែខ្លាំងឡើង គឺរឹតតែបង្កភាពធ្ងន់ធ្ងរមួយកម្រិតទៀតមកលើការពិតដែលថាសាលាក្តីនេះដែលពុំបានធ្វើការផ្សព្វផ្សាយនៅតាមមូលដ្ឋានប្រកបដោយជោគជ័យ ។ មិនមែនមានតែប្រជាជនស៊ែបម្នាក់ឯងដែលធ្វើការប្រឆាំងទៅនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតយូហ្គោស្លាវីទេ សូម្បីតែសារព័ត៌មាននិងព្រឹត្តិបត្រគោលនយោបាយនៅក្នុងប្រទេសក្រូអាតដែលក្នុងនោះពោរពេញទៅដោយពាក្យជេរប្រមាថក៏បានសម្តែងនូវការប្រឆាំងកាន់តែខ្លាំងឡើងៗចំពោះសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតយូហ្គោស្លាវីតាមរយៈការបញ្ចេញមតិសាធារណជនទូទៅរបស់ប្រទេសក្រូអាត ។ ក្រៅពីទិន្នន័យតាមរយៈការសម្តែងនូវអារម្មណ៍ទាំងនេះ ការស្ទង់មតិមួយត្រូវបានរៀបចំធ្វើឡើងកាលពីខែសីហា ឆ្នាំ២០០០ នៅក្នុងប្រទេសក្រូអាតបានបង្ហាញឲ្យដឹងថាៈ អត្រាភាគរយខ្ពស់របស់ប្រជាពលរដ្ឋជឿជាក់ថា តុលាការក្រុងឡាអេមានភាពលម្អៀងខណៈពេលដែលប្រជាពលរដ្ឋ៥២ភាគរយជឿជាក់ថា «តុលាការក្រុងឡាអេ មានបំណងដាក់ឲ្យក្លាយជាទោសឧក្រិដ្ឋចំពោះសង្គ្រាមក្នុងប្រទេស» ។ នេះមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេដែលថាមនុស្ស៧៨ភាគរយយល់ថា ប្រទេសក្រូអាតមិនគួរបញ្ជូនប្រជាពលរដ្ឋរបស់ខ្លួនទេ ប្រសិនបើតុលាការក្រុងឡាអេស្នើសុំ» ។ អ៊ីវ៉ាណា នីហ្សិច ដែលបម្រើការឲ្យអង្គការឃ្លាំមើលសិទ្ធិមនុស្សបានកត់សម្គាល់ថា«មានមនុស្សតិចតួចណាស់នៅក្នុងអតីតប្រទេសយូហ្គោស្លាវីដែលជឿថា សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីនឹងធ្វើការកាត់ទោសអ្នកទាំងឡាយដែលស័ក្តិសមនឹងទទួលទោសនេះ ហើយវានឹងបង្កើតនូវការពិតមួយអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យសង្គ្រាមឬបានជឿជាក់ថា វានឹងក្លាយជាយានមួយឬជាកម្លាំងចលករមួយដែល

នាំទៅរកការផ្សះផ្សាគ្នាឡើងវិញរវាងប្រជាជនក្នុងអតីតនៃប្រទេសយូហ្គោស្លាវី» ។ នីហ្សិច បន្ថែមថា «សូម្បីតែក្រុមប្រឆាំងនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី ក៏សម្តែងនូវការស្រងាកចិត្តចំពោះសកម្មភាពរបស់សាលាក្តីនេះដែរ» ហើយការព្រួយបារម្ភបន្ថែមទៀតនោះគឺថា ប្រជាជននៃអតីតប្រទេសយូហ្គោស្លាវី បានចាត់ទុកសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីជាស្ថាប័នមួយក្នុងក្រុងឡាអេដែលមានរចនាសម្ព័ន្ធមិនច្បាស់លាស់ ដែលត្រូវបានបង្កើតឡើងដោយសហគមន៍អន្តរជាតិដើម្បីកែកុននូវកំហុសរបស់ខ្លួន...វាជាសាលាក្តីរបស់(អ្នកផ្សេងទៀត) ...ជាអសមត្ថភាពរបស់សាលាក្តីនេះក្នុងការបំពេញតួនាទីជាយានមួយសម្រាប់ធ្វើការផ្សះផ្សា ឬជាអសមត្ថភាពដោយមិនទទួលបាននូវការគោរពពីក្រុមបាល់កង់មួយភាគធំដោយសារតែខ្លួនមិនបានចុះទំនាក់ទំនងឲ្យបានទូលំទូលាយជាមួយប្រជាជននៅតាមតំបន់នានា ។

កម្មវិធីចុះផ្សព្វផ្សាយ នៅតាមមូលដ្ឋានរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ តែប៉ុណ្ណោះគឺក្រោយពេលបង្កើតសាលាក្តីនេះបានរយៈពេល៥ឆ្នាំក្រោយពីសាលាក្តីនេះចេញដីកាចោទប្រកាន់របស់ខ្លួនជាលើកដំបូង ។ បុគ្គលិកការិយាល័យអគ្រានុកូលដ្ឋានជាអ្នកចុះទំនាក់ទំនងនៅក្នុងតំបន់មួយឬពីរនៅក្នុងប្រទេសបាល់កង់(ក្នុងក្រុងហ្សាក្រេប ឬតំបន់មួយចំនួននៅក្នុងប្រទេសប៊ូស្នៀ) ក៏ប៉ុន្តែជាទូទៅបុគ្គលិកទាំងនេះធ្វើការផ្សព្វផ្សាយតិចតួចបំផុតនូវព័ត៌មានទូទៅស្តីអំពីសាលាក្តីនេះ ។ វិធាននៃកម្មវិធីទំនាក់ទំនងនេះគឺគ្រាន់តែជាកិច្ចប្រឹងប្រែងដើម្បីផ្លាស់ប្តូរជំនាញរបស់សាលាក្តីនេះជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងអតីតប្រទេសយូហ្គោស្លាវីប៉ុណ្ណោះ ហើយវានៅតែជាការរួមចំណែកដែលមិនមានលក្ខណៈជាប្រព័ន្ធដដែល ។

មិនត្រឹមតែប៉ុណ្ណោះ«ការិយាល័យរដ្ឋអាជ្ញាបានប្រឹងប្រែងតិចតួចបំផុតក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងសាធារណជនទូទៅនៃប្រទេសយូហ្គោស្លាវី បើទោះជាការិយាល័យនេះមានគោលដៅចម្បងមួយដើម្បីផ្តល់នូវយុត្តិធម៌ជូនជនរងគ្រោះនៅក្នុងតំបន់នោះក៏ដោយ» ។ ដាក់ស្តែងផ្អែកតាមការស្ទង់មតិមួយដែលធ្វើឡើងជាមួយនឹងក្រុមតំណាងគំរូមួយនៃចៅក្រមនិងរដ្ឋអាជ្ញាប៊ូស្នៀដែលមានសមត្ថកិច្ចដំបូងឬខាងឧទ្ធរណ៍លើការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមក្នុងប្រទេសបានបង្ហាញឲ្យដឹងថា សូម្បីតែអ្នកទាំងនេះជាតួអង្គដ៏សំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសក៏ដោយ ក៏អ្នកទាំងនេះអាចមានសិទ្ធិតិចតួច ឬគ្មានសិទ្ធិចូលពិនិត្យមើលឯកសារបោះពុម្ពផ្នែកច្បាប់របស់សាលាក្តីនេះ ឬដែលទាក់ទងនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីនេះទេ ។ ការព្រងើយកន្តើយ ឬមិនយកចិត្តទុកដាក់របស់អ្នកខាងក្រៅដែលពុំមានភាពជិតស្និទ្ធបានធ្វើឲ្យក្រុមអ្នកច្បាប់ក្នុងប្រទេសមានទស្សនៈជាអវិជ្ជមានចំពោះតុលាការនេះ ។ ការរិះគន់ជាទូទៅរបស់ក្រុមអ្នកច្បាប់ប៊ូស្នៀចំពោះសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី គឺដោយសារអ្នកទាំងនោះយល់ថាទំនាក់ទំនងយូរម្តងៗជាមួយសាលាក្តីនេះគឺគ្រាន់តែជានិមិត្តរូបនៃការមិនគោរពចំពោះសាលាក្តីនេះប៉ុណ្ណោះ ។ ក្រុមអ្នកចូលរួមភាគច្រើននៅក្នុងការស្ទង់មតិនេះជឿជាក់ថា ជាក់ស្តែងណាស់ថាសាលាក្តីនេះមានចរិតជាសាលាក្តីអន្តរជាតិដែលនាំមកនូវបញ្ហាមួយចំនួនព្រមទាំងបានលើកឡើងថា «ក្រុមអ្នកតំណាងអន្តរជាតិជានិច្ចកាលមិនបានដឹងអំពីប្រព័ន្ធច្បាប់របស់ប្រទេសប៊ូស្នៀទេ ហើយពួកគេបំពេញតួនាទីដោយឯករាជ្យរបស់ខ្លួនក្នុងការដាក់បញ្ញត្តិខាងក្រៅមកលើប្រទេសនេះនិងស្ថាប័ននីតិកម្មរបស់ប្រទេសនេះ» ។

ប្រជាពលរដ្ឋជាមធ្យមដែលមានចំណេះតិចតួចខាងផ្នែកច្បាប់ និងធនធានដ៏ស្តួចស្តើងសម្រាប់បំពេញនូវតម្រូវការរបស់ខ្លួនទំនងដូចជាមិនបានទទួលព័ត៌មានពេញលេញអំពីសាលាក្តីនេះ និងសកម្មភាពនានារបស់សាលាក្តីនេះទេ ឬក៏មានអារម្មណ៍ថា ខ្លួនជាចំណែកមួយនៅក្នុងដំណើរផ្តល់ប្រឹក្សានិងប្រកបដោយការគោរព(ថ្វីបើនេះវាអាចជាចំណែកមួយក្នុងការបរិយាយទៅលើការជំនុំជម្រះខាងផ្លូវច្បាប់ ដែលមានចរិតលក្ខណៈផ្តោតទៅលើក្រុមឧក្រិដ្ឋជននៅក្នុងប្រទេសក៏ដោយ) ដែលផ្ទុយនឹងដំណើរការផ្តោតលើជនរងគ្រោះ ដូចជាគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សា) ។ ការដែលមិនមានឥទ្ធិពលទៅលើប្រជាជនសំខាន់ៗដែលរស់នៅក្នុងអតីតប្រទេសយូហ្គោស្លាវីក្នុងរបបក្រោយសម័យសង្គ្រាមគឺជាបញ្ហាមួយធ្ងន់ធ្ងរជាងការមានអំណាចដោយការបង្គាប់បញ្ជាក្នុងការអនុវត្តរបស់សាលាក្តី ឬភាពយឺតយ៉ាវនៃដំណើរការជំនុំជំរះក្តីរបស់

ខ្លួន ។ ការអសមត្ថភាពរបស់សាលាក្តីដើម្បីជំរុញឲ្យមានវប្បធម៌នៃការទទួលខុសត្រូវនិងការផ្តល់យុត្តិធម៌គឺភាគច្រើនអាចបណ្តាលមកពីឥទ្ធិពលដ៏តិចតួចរបស់ខ្លួនមកលើប្រជាជនក្នុងស្រុក ។

នៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីធ្វើការ«វាយតម្លៃទៅលើមរតកច្បាប់របស់សាលាក្តីនេះ»លោក ដេវីត ថលប៊ឺត ដែលបច្ចុប្បន្នមានមុខងារជានាយកប្រតិបត្តិនៃ *ABA-CEELI* និងជាអតីតនាយខុទ្ទកាល័យរបស់ប្រធានសាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់អតីតយូហ្គោស្លាវី ព្រមទាំងជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់មួយរូបរបស់មន្ត្រីកាន់បញ្ជីនៃសាលាក្តីនេះបានធ្វើការអះអាងថា តុលាការនេះមិនបាន «ដើរតួនាទីជាមធ្យោបាយដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យច្បាប់ (នៅក្នុងប្រទេស) ហើយវាក៏មិនបានផ្តល់ជាកម្លាំងចលករមួយដែលជំរុញទៅដល់ដំណើរការកាត់ទោសលើឧក្រិដ្ឋកមសង្គ្រាមក្នុងប្រទេសដែរ» ។ គាត់គូសបញ្ជាក់ឲ្យដឹងទៀតថា «សាលាក្តីនេះទំនងជាក្តោបទុកនូវដំណើរការរបស់ខ្លួន ដោយពុំបានចូលរួមចំណែកឲ្យបានច្រើនដល់ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសនិងកាត់ទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាម បើទោះជាយ៉ាងណា «អ្នកទាំងឡាយដែលបានបង្កើតលក្ខន្តិកៈរបស់សាលាក្តីនេះគួរតែដឹងជាមុនថាដំណើរការកាត់ទោសលើឧក្រិដ្ឋកម្មសង្គ្រាមនេះធ្វើឡើងនៅតុលាការជាបន្តបន្ទាប់នៅក្នុងប្រទេសក៏ដោយ» ។ ការសង្កេតតាមដានទាំងនេះគឺមានសារសំខាន់ខ្លាំងណាស់ ព្រោះថាវាបានឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងការទទួលខុសត្រូវចំពោះឧក្រិដ្ឋជនបទល្មើសកាលពីអតីតកាលនិងការបង្កើតឡើងនូវវប្បធម៌នៃការផ្តល់យុត្តិធម៌ៈ ថ្វីបើសាលាក្តីនេះបានធ្វើការផ្តន្ទាទោសចំពោះក្រុមឧក្រិដ្ឋជនសង្គ្រាមទាំងនោះក៏ដោយ សាលាក្តីនេះមិនទាន់បានជំរុញខ្លាំងក្លាគួរឲ្យកត់សម្គាល់ទៅដល់ការបង្កើតនីតិរដ្ឋ ឬសេចក្តីគោរពចំពោះច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្សនៅក្នុងអតីតប្រទេសយូហ្គោស្លាវីដែរ ។ សាលាក្តីនេះពុំមានសិទ្ធិអំណាច ហើយក៏ពុំមានធនធានគ្រប់គ្រាន់ដើម្បីចូលរួមយ៉ាងសកម្មក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ក្នុងប្រទេស ឬក៏ជួយដល់ដំណើរការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមដ៏មានរយៈពេលយូរអង្វែងដែរ ។ ការបរាជ័យក្នុងការរៀបចំទាំងនេះបញ្ជាក់ថា សាលាក្តីមានឥទ្ធិពលយ៉ាងតិចតួចក្នុងរយៈពេលវែងទៅលើប្រព័ន្ធយុត្តិធម៌នៅក្នុងអតីតប្រទេសយូហ្គោស្លាវី សូម្បីតែនៅក្នុងករណីដែលពាក់ព័ន្ធជាមួយនឹងដំណើរការកាត់ទោសលើឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលទាំងនេះជាកម្មវត្ថុមូលដ្ឋានគ្រឹះនៃសមត្ថកិច្ចរបស់សាលាក្តីនេះ ។ អ្វីដែលគួរឲ្យសោកសៅនោះគឺថា បើទោះជាទឹកប្រាក់រាប់លានដុល្លារត្រូវបានចំណាយទៅលើការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធតុលាការនៅក្នុងក្រុងឡាអេក៏ដោយ គេឃើញមានប្រសិទ្ធភាពដ៏តិចតួចនៅក្នុងការអនុវត្តច្បាប់សំខាន់ៗទាំងនេះនៅក្នុងតុលាការក្នុងស្រុកនៃប្រទេសនេះ ដែលនៅតែមិនមានលក្ខណៈគ្រប់គ្រាន់នៅឡើយក្នុងការផ្តល់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌និងអព្យាក្រឹតទៅដល់ក្រុមជាតិសាសន៍ទាំងអស់ ជាពិសេសនៅក្នុងបរិបទឧក្រិដ្ឋកម្មសង្គ្រាមដ៏ហិង្សានេះ ។

កង្វះភាពទទួលខុសត្រូវគឺអាចត្រឹមតែបំផ្លាញដល់កិច្ចប្រឹងប្រែង ក្នុងការកសាងជាថ្មីនូវសន្តិភាព សន្តិសុខ និងនីតិរដ្ឋនៅក្នុងប្រទេសតែប៉ុណ្ណោះ ។ ការមិនបានផ្តល់ការគាំទ្រចំពោះតុលាការក្នុងប្រទេសដែលធ្វើការកាត់ទោសលើឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់នេះ បង្កើតជាបញ្ហាកាន់តែច្រើនថែមទៀត បើពិនិត្យទៅលើទឹកប្រាក់រាប់លានដែលបានចំណាយលើសាលាក្តីនេះ និងការចំណាយស្រដៀងគ្នាដ៏ទាបទៅលើការបំពាក់បំប៉នព្រះរាជអាជ្ញាក្នុងស្រុកចៅក្រមក្នុងប្រទេស ក៏ដូចជាការពិនិត្យតាមដានចំណាត់ការ-របស់តុលាការដែលពាក់ព័ន្ធនឹងរឿង ឧក្រិដ្ឋកម្មសង្គ្រាមនិងការផ្តល់ជំនាញបច្ចេកទេស ។

និយាយរួម កង្វះសមត្ថភាពរបស់សាលាក្តីព្រហ្មទណ្ឌអន្តរ-ជាតិនៃអតីតប្រទេសយូហ្គោស្លាវីនិងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិប្រទេសរ៉្វាន់ដា នៅក្នុងការកែលម្អប្រព័ន្ធច្បាប់ក្នុងប្រទេសឲ្យមានភាពប្រសើរឡើង និងអប្រជាប្រិយភាពរបស់សាលាក្តីទាំងពីរនេះនៅក្នុងប្រទេសរ៉្វាន់ដានិងអតីតប្រទេសយូហ្គោស្លាវីបានចោទជាសំណួរមួយគឺថា តើតាមពិតគោលបំណងចម្បងរបស់សាលាក្តីទាំងនេះ គឺដើម្បីជំរុញទៅដល់ការបង្កើតនីតិរដ្ឋសម្រាប់ប្រទេសនីមួយៗ និងជំរុញឲ្យមានការផ្តល់នូវភាពយុត្តិធម៌ ឬក៏បង្កើតឲ្យមាននីតិវិធីច្បាប់អន្តរជាតិ ដែលអាចឲ្យសហគមន៍អន្តរជាតិលុបលាងនូវកំហុសរបស់ខ្លួន? **(នៅមានត)**

***រេអែល ហ៊ីហ្វូនេត***

# ការធន្ទឹងរង់ចាំរបស់គ្រួសារខ្ញុំ



ភូមិដក់ពរ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ជាទីកន្លែងកំណើតរបស់ខ្ញុំ ។ ក្រុមគ្រួសាររបស់ខ្ញុំមានសមាជិកប្រាំពីរនាក់ គឺជីដូនជីតា (ខាងម្ដាយ) មីង បងជីដូនមួយ ឪពុកម្ដាយខ្ញុំ ប្អូនប្រុស និងខ្ញុំ ។ នៅក្នុងគ្រួសារមានតែរូបខ្ញុំ និងប្អូនប្រុសប៉ុណ្ណោះដែលកើតមិនទាន់របបខ្មែរក្រហម ។ រាល់ពេលបាយល្ងាចឬបន្ទាប់ពីពេលបាយរួចឬក្នុងឱកាសមានពិធីបុណ្យផ្សេងៗ ក្រុមគ្រួសារខ្ញុំតែងតែអង្គុយជុំគ្នាជជែកគ្នាលេងពីនេះពីនោះ ។ ជីដូនរបស់ខ្ញុំនិយាយជារឿយៗអំពីរបបនេះថា «គាត់និងក្រុមគ្រួសារព្រមទាំងម្ដាយខ្ញុំជួបលំបាកយ៉ាងខ្លាំង ប៉ុន្តែខ្ញុំហាក់ដូចមិនសូវជឿ ។ ពេលខ្លះគាត់ស្ដីបន្ទោសខ្ញុំថា «អីចឹងហើយ! ក្មេងកើតមិនទាន់គ្រាប់ផ្លោង» ។ ពេលខ្លះយាយបានលើករឿងកូនប្រុសគាត់មកនិយាយ ហើយប្រៀបធៀបខ្ញុំនិងប្អូនប្រុសទៅនឹងកូនប្រុសរបស់គាត់ថា ខ្ញុំទាំងពីរមិនបានមួយចំណិតកូនប្រុសគាត់ទេ ។ ខ្ញុំសួរគាត់វិញថាឯណាទៅកូនប្រុសរបស់យាយ? តើគាត់នៅទីណាបានជាមិនដែលឃើញមកផ្ទះ? ពេលខ្លះខ្ញុំឃើញគាត់ស្រក់ទឹកភ្នែកទៀតផង ។

## ជីដូនជីតាខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ជីដូនរបស់ខ្ញុំឈ្មោះ អេន ចាន់ ជីតាខ្ញុំឈ្មោះ អ៊ុន យៀង ។ អ្នកទាំងពីររៀបការក្នុងអំឡុងឆ្នាំ១៩៣៥ ហើយបានមករស់នៅក្នុងភូមិដកពរ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ។ មុនរបបខ្មែរក្រហមអ្នកទាំងពីរមានជីវភាពរស់នៅសមរម្យជាប្រជាពលរដ្ឋសាមញ្ញ ។ យាយមានកូនស្រី៤នាក់ និងកូនប្រុសម្នាក់ឈ្មោះ អ៊ុន ឈុន ។

មកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលកងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនពីទីក្រុងឲ្យទៅកាន់ជនបទក្នុងគោលបំណងដើម្បីឲ្យមានសមភាពនៅក្នុងសង្គម គ្មានអ្នកក្រុង អ្នកស្រែ អ្នកក្រ ឬអ្នកមាន ។ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមរបបថ្មីមួយត្រូវបានបង្កើតឡើងដែលមាន ឈ្មោះថា«កម្ពុជាប្រជាធិបតេយ្យ» ។ ប្រជាជនកម្ពុជា ព្រមទាំងគ្រួសាររបស់យាយត្រូវបានបំបែកចេញពីគ្រួសារ មានតែម្ដាយនិងមីងរបស់ខ្ញុំទេដែលនៅក្មេងជាងគេ ហើយអាចមានឱកាសបានរស់នៅបានយូរជាមួយគ្រួសារ ។ ប៉ុន្តែក្រោយមកគាត់ក៏ត្រូវបានបញ្ជូនទៅតាមកងកុមារ ។

យាយបានប្រាប់ថា បន្ទាប់ពីជម្លៀសបានប្រហែលជិតកន្លះឆ្នាំ គាត់បានជួបអ្នកមកពីភ្នំពេញមួយគ្រួសារដែលមានស្ថានលំបាកក្នុងការរស់នៅតំបន់ស្រុកស្រែប្រហែលជាក្រុមគ្រួសារនេះពុំធ្លាប់ជួបការលំបាកបែបនេះទេពីមុនមក ។ សន្និដ្ឋានបែបនេះ ព្រោះយាយឃើញគ្រួសារនេះមានសម្ភារប្រើប្រាស់មានតម្លៃច្រើន ។ យាយបានជួយឲ្យគ្រួសារនោះស្នាក់នៅជាមួយបានមួយរយៈពេលដែរ ។មិនបានប៉ុន្មានផងត្រូវកងឈ្លបមកហៅទៅរស់នៅកន្លែងផ្សេងបាត់ទៅ ។

យាយមិនត្រូវបានជម្លៀសទៅស្រុកណាទេគឺគ្រាន់តែឲ្យទៅធ្វើការងារឆ្ងាយៗពីផ្ទះប៉ុណ្ណោះ ។ យាយបន្ថែមទៀតថា ធ្វើការងារច្រើនណាស់តែអាហារមិនបានហូបគ្រប់គ្រាន់ទេ ហើយបើយើងមិនធ្វើឈ្លបនឹងយកទៅកសាងរៀនសូត្រ ឬដាក់ទណ្ឌកម្មឲ្យរែកដីដកស្ទោនិងរែកដីពេលថ្ងៃត្រង់ដោយមិនឲ្យអាហារហូប ។ ពេលខ្លះយាយបានឃើញកងឈ្លបខ្មែរក្រហមបណ្ដើរប្រជាជនជាច្រើននាក់ដើរជាជួរហើយប្រាប់ថាយកទៅរៀនសូត្រ ។ ឈ្លបខ្មែរក្រហមខ្លះប្រាប់ថា «ប្រសិនបើអ្នកទាំងអស់គ្នាមិនប្រឹងប្រែងធ្វើការ ឬធ្វើការឲ្យមិនអស់ពីដៃពីជើង ឬរអ៊ូរទាំពេលកំពុងធ្វើការអង្គការនឹងនាំយកទៅរៀនសូត្រដូចគ្នា» ។ ថ្ងៃមួយយាយត្រូវអង្គការឲ្យទៅស្ទូងស្រូវនៅខាងកើតភ្នំជីសូរ ប្រហែលជា៦ទៅ៧គីឡូម៉ែត្រពីផ្ទះ ។ ពេលត្រឡប់មកវិញពេលល្ងាច យាយបានធ្វើដំណើរឆ្លង

កាត់ជើងភ្នំជីសូរ ប៉ែកខាងជើង ស្រាប់តែបានព្រួសម្រែកមនុស្ស ស្រែកហាក់បីដូចជាត្រូវនរណាម្នាក់វាយធ្វើបាប ។ ពេលនោះ យាយបានលបមើលហើយបានឃើញឈ្លបកំពុងធ្វើទារុណកម្ម ប្រជាជនប្រមាណជា៥ ទៅ៦នាក់និងមានមនុស្សមួយចំនួនទៀត ដែលជាប់ចំណង ។ យាយតក់ស្លុតយ៉ាងខ្លាំងចំពោះហេតុការណ៍ នេះ រួចក៏ប្រញាប់ប្រញាល់វិលត្រឡប់មកភូមិវិញ ។ ប៉ុន្តែយាយ មិនបានប្រាប់រឿងនេះឲ្យនរណាដឹងទេ ព្រោះ «អង្គការធ្លាប់បង្រៀន ប្រជាជនថាបើ ចង់រស់បានយូរត្រូវរៀនដាំដើមគ...» ។ ក្រោយ មកទើបយាយបានដឹងច្បាស់ថាកន្លែងនោះ ជាកន្លែងធ្វើទារុណកម្ម និងជាកន្លែងឃុំឃាំងអ្នកទោសដែលអ្នកស្រុកស្គាល់ឈ្មោះថា «អន្ទង់ស» ស្ថិតនៅខាងកើតភ្នំក្នុងភូមិត្រពាំងស្គុក ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ ។

## អំពីម្តាយខ្ញុំ

ម្តាយខ្ញុំសព្វថ្ងៃមានអាយុ៨៩ឆ្នាំ ។ កាលណោះ ម្តាយខ្ញុំស្ថិត ក្នុងកងកុមារបានមួយរយៈក៏ត្រូវបញ្ជូនទៅកាន់កងចល័តវិញ ។ ការងារដែលគាត់ធ្វើរាល់ថ្ងៃជាមួយប្រជាជនក្នុងភូមិគឺធ្វើការតាម ការកំណត់របស់អង្គការនិងតាមរដូវកាល ឧទាហរណ៍ពេលរដូវ វស្សាត្រូវទៅបោចស្មៅដកសំណាបនិងស្ទូងស្រូវជាដើម ហើយ នៅរដូវប្រាំង ទៅច្រូតស្រូវនិងប្រមូលកណ្តាប់ ។ ក្រៅពីនេះអង្គការ ឲ្យទៅជីកប្រឡាយ ប្រមូលជី និងរែកដីថែមទៀត ។ ម្តាយខ្ញុំត្រូវ ធ្វើការនេះដដែលៗ ចំណែកឯការហូបចុកមិនបានគ្រប់គ្រាន់ទេ គឺម្នាក់ៗទទួលបានបបររាវមួយចាន ។ ថ្ងៃមួយម្តាយខ្ញុំអស់កម្លាំង ពេក គាត់បានទៅលួចដកដំឡូងហូបពេលនោះគាត់ស្ទើរតែបាត់ បង់ជីវិតដោយសារតែពេលកំពុងដកដំឡូងស្រាប់តែមានកងឈ្លប ម្នាក់ឈ្មោះ សឹម ដែលត្រូវជាបងជីដូនមួយរបស់គាត់មកទាន់ ហើយបានទាញយកដំឡូងដែលគាត់កំពុងហូបពីដៃ ។ បន្ទាប់មក សឹម បានបណ្តើរគាត់ទៅក្នុងភូមិដើម្បីយកទៅកសាង ប៉ុន្តែគាត់ ត្រូវបានដោះលែងនៅតាមផ្លូវ បន្ទាប់ពីម្តាយខ្ញុំអង្វរគាត់យ៉ាង យូរ ។ សឹម ព្រមានថា «ប្រសិនបើហ៊ានលួចម្តងទៀតនឹងត្រូវបាត់ ខ្លួនហើយ» ។ បន្ទាប់មកម្តាយខ្ញុំត្រូវបានជម្លៀសឲ្យទៅធ្វើស្រែនៅ ក្បែរភ្នំដំរីរមៀលបានមួយរយៈគាត់ក៏លួចរត់មកវិញ ។ ពេល មកដល់ផ្ទះបានមួយយប់ ស្រាប់តែឈ្លបមកយកម្តាយខ្ញុំត្រឡប់ ទៅវិញ ។ មិនបានប៉ុន្មានថ្ងៃផងម្តាយខ្ញុំបានលួចរត់មកផ្ទះម្តងទៀត ។ គ្រាន់តែមកដល់យប់នោះ សឹម បានតាមគាត់ដល់ផ្ទះ ហើយឲ្យ គាត់ត្រឡប់ទៅវិញ ។ ម្តាយខ្ញុំប្រាប់ថាគាត់ឈឺ ។ ប៉ុន្តែ សឹម ចោទ ថា «មិត្តឯងកើតជំងឺខ្ជិលមានចេតនាចង់ក្បត់អង្គការ ។ ប្រសិនបើ មិនត្រឡប់ទៅវិញទេនឹងនាំយកគាត់ទៅកសាងនិងរៀនសូត្រ...» ។ បន្ទាប់មកម្តាយខ្ញុំរត់ទៅស្នាក់នៅជាមួយបងស្រីនៅឯឃុំអង្គប្រិយ៍ ។

តាមការរៀបរាប់របស់ជីដូននិងម្តាយខ្ញុំ ធ្វើឲ្យខ្ញុំបានដឹង កាន់តែច្បាស់អំពីរបបនេះ ជាពិសេស បន្ទាប់ពីខ្ញុំបានរៀនចប់ ថ្នាក់មធ្យមសិក្សានិងបន្តដល់ថ្នាក់ឧត្តមសិក្សានិងរួមផ្សំជាមួយការ ចែករំលែកនូវបទពិសោធន៍របស់មនុស្សចាស់ៗដែលបានឆ្លងកាត់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបន្ទាប់ពីខ្ញុំបានមកធ្វើការជាអ្នក ស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំកាន់តែយល់ច្បាស់និង ស៊ីជម្រៅអំពីទង្វើរបស់ខ្មែរក្រហមដែលពីមុនខ្ញុំគិតថាគ្រាន់តែជា រឿងដែលចាស់ៗនិទានដើម្បីបន្លាចក្មេងៗប៉ុណ្ណោះ ។ ផ្ទុយទៅវិញ របបខ្មែរក្រហមពិតជាបានផ្តល់នូវការឈឺចាប់ច្រើនអនេកចំពោះ ប្រជាជនខ្មែរ ហើយសកម្មភាពនេះជាអំពើអមនុស្សធម៌សម្រាប់ ប្រជាជនខ្មែរគ្រប់រូបនិងជាអំពើរបៀបសត្វធាតុខ្វះការពិចារណា ។

## គ្រួសារខ្ញុំក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់ ម្តាយខ្ញុំបានបាត់បង់សមាជិកម្នាក់គឺបងប្រុសរបស់គាត់ឈ្មោះ អ៊ិន ឈុន ។ រាល់ពេលដែលក្រុមគ្រួសារខ្ញុំជួបជុំគ្នា យើងតែងតែ ចាប់ផ្តើមលើកយករឿងរបស់អ៊ំប្រុសមកនិយាយមុនគេ ។ កាលពីជីដូនជីតាខ្ញុំនៅរស់អ្នកទាំងពីរតែងសរសើរថា «ជាកូនប្រុស ដែលមានរូបរាងស្រស់សង្ហានិងជាមនុស្សឆ្លាតវាងវៃដែលគាត់ មានរំពឹងតែមួយគត់នៅក្នុងជីវិត» ។

តាំងពីរបបប៉ុលពតបានរលត់ទៅគ្រួសាររបស់ខ្ញុំ ជីដូនជីតា មាអ៊ឹ ពូមីង និងឪពុកម្តាយខ្ញុំ តែងទន្ទឹងរង់ចាំផ្លូវដោយសង្ឃឹមថា អ៊ិន ឈុន នឹងវិលត្រឡប់មកវិញនៅថ្ងៃណាមួយមិនខាន ក៏ប៉ុន្តែ រហូតមកដល់ពេលនេះ ក្រុមគ្រួសាររបស់ខ្ញុំពុំទាន់ទទួលតម្រុយ ណាមួយអំពីគាត់នៅឡើយ ។

កាលខ្ញុំនៅសិក្សាថ្នាក់បឋម ។ ថ្ងៃទី២០ ខែឧសភា រៀងរាល់ ឆ្នាំគឺជាទិវាចងកំហឹងនឹងបនប្រល័យពូជសាសន៍ខ្មែរក្រហមនៅ

សាលារៀនលោកគ្រូអ្នកគ្រូតែងនាំសិស្សានុសិស្សឲ្យចូលរួមពិធីចងកំហឹងចំពោះបនប្រល័យពូជសាសន៍ប៉ុលពតនៅក្បែរជើងភ្នំជីសូរដោយមានការអញ្ជើញចូលរួមពីសំណាក់ប្រជាជន ព្រះសង្ឃ កម្មាភិបាលគ្រប់ជាន់ថ្នាក់នៅក្នុងតំបន់ដើម្បីប្រារព្ធពិធីចងកំហឹងការឈឺចាប់ដែលប្រជាជនកម្ពុជាឆ្លងកាត់ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ ពេលនោះទើបខ្ញុំបានដឹងច្បាស់ថា ទីនោះជាកន្លែងដែលជីដូនខ្ញុំប្រាប់ថា គាត់បានឃើញឈ្លបខ្មែរក្រហមធ្វើទារុណកម្មមកលើប្រជាជនស្លូតត្រង់ ។

ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅ៣០ឆ្នាំហើយក៏ដោយ ប៉ុន្តែការឈឺចាប់នៅតែដក់ជាប់ជានិច្ចក្នុងចិត្តប្រជាជនខ្មែរគ្រប់រូប ។ ចំណែកក្មេងដូចជារូបខ្ញុំនិងប្រជាជនខ្មែរជំនាន់ក្រោយគ្រាន់តែបានដឹងតាមរយៈការសិក្សារៀនសូត្រនិងការនិយាយប្រាប់ពីឪពុកម្តាយឬចាស់ៗប៉ុណ្ណោះ ។ ខ្ញុំមានការឈឺចាប់ជំនួសអ្នកដែលស្លាប់បាត់បង់ជីវិតទៅនិងកោតសរសើរអ្នកដែលបានរួចរស់ជីវិតទាំងត្រដាបត្រដួសមកដល់សព្វថ្ងៃនេះគឺពិតជាអស្ចារ្យខ្លាំងណាស់ ។

ការទន្ទឹងរង់ចាំរបស់គ្រួសារខ្ញុំចំពោះបងប្រុស អ៊ីប្រុស គឺជាការលំបាក ព្រោះមិនដឹងថានឹងត្រូវធ្វើយ៉ាងណា ឬត្រូវពឹងពាក់អ្នកណាឲ្យជួយនោះទេ ។ ខ្ញុំគិតថា មិនមែនមានតែគ្រួសាររបស់ម្តាយខ្ញុំប៉ុណ្ណោះទេដែលបានជួបប្រទះរឿងនេះ ។ ប្រាកដណាស់របបនេះបង្កឲ្យគ្រួសារប្រជាជនកម្ពុជាជាច្រើនជួបប្រទះការនិរាសព្រាត់ប្រាសគ្រួសារ បងប្អូន កូនចៅ និងបន្សល់ទុកនូវអសន្តិសុខ អំពើហិង្សា ភាពល្ងង់ខ្លៅ បាត់បង់ធនធានមនុស្សនិងធម្មជាតិដែលជាហេតុធ្វើឲ្យកម្ពុជាមិនអាចអភិវឌ្ឍជឿនលឿនទៅមុខបានដូចប្រទេសជិតខាង ។

បន្ទាប់ពីទទួលដំណឹងថានឹងមានការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីរៀបចំកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមតាមរយៈការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ទាំងគ្រួសារខ្ញុំក៏ដូចជាប្រជាជនខ្មែរគ្រប់រូបមានសេចក្តីរំភើបដោយសាររឿងរ៉ាវដ៏អាក្រក់ដែលបានកើតឡើងចំពោះជនរងគ្រោះត្រូវបានសើរើឡើងវិញដើម្បីនាំយកស្ថាបនិកនៃរបបនេះមកកាត់ទោសតាមផ្លូវច្បាប់ ។ រហូតមកដល់ពេលនេះប្រជាជនខ្មែរកំពុងតែរង់ចាំមើលការកាត់ទោសដែលនឹងអាចពាំនាំនូវយុត្តិធម៌ពិតប្រាកដមួយជូនជនរងគ្រោះ ។

គ្រួសារខ្ញុំក៏មានចិត្តរីករាយខ្លាំងដែរពេលដែលបានទទួលដំណឹងថាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌មកឲ្យប្រជាជនដែលបានស្លាប់បាត់បង់ជីវិត១,៧លាននាក់ និងអ្នកដែលរួចរស់ជីវិតមកដល់សព្វថ្ងៃ។ ប្រសិនបើតុលាការអាចនាំមកនូវយុត្តិធម៌ពិតប្រាកដជូនប្រជាជនកម្ពុជាបានមែននោះការទន្ទឹងរង់ចាំរបស់ក្រុមគ្រួសារខ្ញុំចំពោះកូនប្រុស ប្អូនប្រុស បងប្រុស អ៊ីប្រុស ពិតជាមិនខាតបង់ទាំងពេលវេលា និងកម្លាំងកាយកម្លាំងចិត្តនោះទេ ។ ខ្ញុំគិតថាប្រជាជនគ្រប់រូបក៏មានគំនិតដូចគ្រួសារខ្ញុំដែរ ។ ប្រទេសកម្ពុជានឹងរីកចម្រើនកាន់តែខ្លាំង ក្រោយពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រកបដោយយុត្តិធម៌ពិតប្រាកដនិងតាមផ្លូវច្បាប់រួចរាល់ ។ **ប្រាក់ កែវតារា**

# ដំណឹងស្វែងរកបងប្រុស

នាងខ្ញុំឈ្មោះ ប៊ុន ឡាម៉ៃ សព្វថ្ងៃរស់នៅទីក្រុងហុងកុង សូមស្វែងរកបងប្រុសឈ្មោះ ប៊ុន ឡាទោត ដែលបានបែកគ្នានៅចុងឆ្នាំ១៩៧៥ កាលពីអាយុ១៦ឆ្នាំ ក្នុងភូមិជងអៀន ស្រុកអរញ្ញប្រាថេត ខេត្តសាកែវ ប្រទេសថៃ ក្បែរព្រំប្រទល់ប្រទេសខ្មែរនៃខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ប៊ុនឡា ប៊ុតស៊ី (នៅរស់) និងម្តាយឈ្មោះ ប៊ុន ឡាគៀ (នៅរស់) ។ ខ្ញុំបាទមានបងប្អូនបួននាក់ បងទី១) ប៊ុន ឡាទោត (បាត់ខ្លួន), បងទី២) ប៊ុន ឡាអាត (នៅរស់), បងទី៣) ប៊ុន ឡាលេត (នៅរស់) និងបងទី៤) ប៊ុន ឡាឡៃ (នៅរស់) ។


ប៊ុន ឡាទោត

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ប៊ុន ឡាទោត នេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១២ ១៨៣៧ ៣៥៨ ដែលមានអសយដ្ឋានផ្ទះលេខ៣៩AEo ផ្លូវលេខ២៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ យើងខ្ញុំនឹងមានជូនជាសគុណ ។

# ខ្ញុំរង់ចាំមើលលទ្ធផលនៃការកាត់ទោសមេខ្មែរក្រហម



ខ្ញុំគឺជាក្មេងជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហម ហើយធំធាត់ឡើងដោយពុំបានទទួលការលំបាកអ្វីទាំងអស់ ។ កាលពីខ្ញុំអាយុខ្ទង់៩-១០ឆ្នាំ ខ្ញុំតែងតែឆ្ងល់អំពីពាក្យ«ខ្មែរក្រហម» អ្វីទៅជាខ្មែរក្រហម? បើមានខ្មែរក្រហម តើមានខ្មែរខៀវឬទេ តើមានខ្មែរប៉ុន្មានពណ៌? ខ្ញុំបានអានសៀវភៅមួយដែលបោះពុម្ពនៅរវាងឆ្នាំ១៩៨០ ដែលមានឃ្លាមួយសរសេរថា «ពួកបនខក្រិដ្ឋប្រល័យពូជសាសន៍ ប៉ុល ពត, អៀង សារី, ខៀវ សំផន» ។ ក្រោយពីបានអានអត្ថបទនេះ ខ្ញុំឆ្ងល់ថាតើមានអ្វីខ្លះកើតឡើងនៅសម័យកាលនោះ?

ក្នុងចំណោមបងប្អូន៧នាក់ ខ្ញុំនិងប្អូនប្រុសកើតនៅទីក្រុងភ្នំពេញ ។ ឪពុកម្តាយខ្ញុំជាម្ចាស់ហាងផលិតកម្មស្ករគ្រាប់និងនំចិននៅសង្កាត់បឹងកេងកងទី១ ។ ដោយសារការងារនេះមមាញឹកស្ទើរតែគ្មានពេលសម្រាក ហេតុនេះទើបឪពុកម្តាយខ្ញុំមានពេលវេលាតិចតួចណាស់ទៅលេងស្រុកកំណើត ។ ប៉ុន្តែទោះជាយ៉ាងណាក៏ឪពុកខ្ញុំឆ្លៀតចំណាយពេលនិយាយអំពីរឿងរ៉ាវលំបាករបស់គាត់ក្នុងសម័យខ្មែរក្រហមប្រាប់កូនៗដែរ ។

ឪពុកខ្ញុំមានឈ្មោះ ឈាវ អ៊ា អាយុ៦៣ឆ្នាំ និងម្តាយឈ្មោះ



ឈាវ ម៉េង អាយុ ៦២ឆ្នាំ ។ អ្នកទាំងពីរមានស្រុកកំណើតនៅជាមួយគ្នានៅភូមិឫស្សីស្រុក ឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ កាលពីជំនាន់សម្តេចតា (សីហនុ) ឪពុកខ្ញុំរស់នៅជាមួយគ្រួសារចិនធ្វើស្ករគ្រាប់និងនំចិននៅស្រុកកំពង់ត្របែក ខេត្តព្រៃវែងរយៈពេល ២-៣ឆ្នាំ ។

ឆ្នាំ១៩៧០ រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ឪពុកខ្ញុំក៏សម្រេចចិត្តវិលត្រឡប់មកស្រុកវិញប្រកបមុខរបរធ្វើចម្ការ ។ នៅក្នុងឆ្នាំនោះ កងទ័ពខ្មែរក្រហមបានពង្រាយទ័ពតាមបណ្តាស្រុកភូមិ ។ រយៈមួយឆ្នាំក្រោយមក ឪពុកខ្ញុំបានរៀបការជាមួយម្តាយខ្ញុំស្របពេលដែលប្រទេសជាតិកំពុងកើតចលាចល មានទាហានអាមេរិកកាំងទម្លាក់គ្រាប់បែកពាសពេញស្រុក ។ គោ ក្របី ស្រែចម្ការត្រូវ បំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែក ។ មុនដំបូងទាហានខ្មែរក្រហមបានមកសុំស្នាក់នៅជាមួយអ្នកភូមិដើម្បីបង្ហាញពីភាពស្មោះស្ម័គ្ររបស់ខ្លួន ។ ជាបន្តបន្ទាប់ទាហានខ្មែរក្រហមតែងតែកោះហៅប្រជាជនដែលមានការខ្វះខាតក្នុងជីវភាពមកប្រជុំដើម្បីបំពាក់បំប៉នគោលជំហរ ។ យូរៗម្តងឪពុកខ្ញុំក៏ត្រូវបានកោះហៅមករួមប្រជុំដែរ ។ ពួកខ្មែរក្រហមឃោសនាមិនឲ្យជឿលើព្រះពុទ្ធសាសនាទេ ព្រោះព្រះពុទ្ធរូបនិងព្រះវិហារសាងសង់ឡើងពីស៊ីម៉ងត៍ប៉ុណ្ណោះ ។ រយៈពេល២-៣ឆ្នាំ ការគ្រប់គ្រងរបស់ក្រុមនេះមានសភាពកាន់តែតឹងតែងឡើង ។ ខ្មែរក្រហមបានសុំកម្លាំងប្រជាជនទៅជួយសង់ស្ពាន ជុសជុលស្ពានណាដែលបាក់បែក និងជួសជុលអគារដើម្បីស្តុកសម្ភារៈផ្សេងៗ ។ មិនយូរប៉ុន្មាន សម្ភារៈប្រើប្រាស់និងរបស់របរផ្ទាល់ខ្លួន ដូចជា គោ ក្របី នង្គ័ល ស្រូវ កង់ វិទ្យុ ។ល។ ត្រូវដាក់ជារបស់សមូហភាព ។ ពីដំបូងប្រជាជនអាចហូបបាយនៅតាមផ្ទះរបស់ខ្លួន ។ ក្រោយៗមក ប្រជាជនទាំងអស់ត្រូវបានចាត់តាំងឲ្យមកហូបនៅរោងបាយរួម «រោងបាយសហករណ៍» ដែលមានមនុស្សចំនួនពី២០០ទៅ៣០០នាក់ ។ ខ្មែរក្រហមបានបែងចែកប្រជាជននៅក្នុងភូមិឃុំទៅតាមសហករណ៍នីមួយៗ ។ ឪពុកខ្ញុំនៅរោងបាយទី១៣ ដែលមាន ម៉េន ជាប្រធានរោងបាយ ។ នៅក្នុងសហករណ៍របស់ឪពុកខ្ញុំមានប្រជាជននៅ២ភូមិ គឺភូមិឫស្សីស្រុកក្នុងនិងឫស្សីស្រុកក្រៅ ។ ឪពុកខ្ញុំស្នាក់នៅភូមិឫស្សីស្រុកក្នុង ។ ដោយសារឪពុកខ្ញុំមានគោ១នឹមមានកម្លាំងខ្លាំង ហេតុដូចនេះទើប ម៉េន តែងតែចាត់

តាំងគាត់ឲ្យទៅធ្វើការនៅព្រៃឆ្ងាយៗ ហើយការងារទាំងនោះសុទ្ធសឹងជាការងារធ្ងន់ៗ ។

នៅឆ្នាំ១៩៧៧ មានពេលមួយនោះ ពេលដែលឪពុកខ្ញុំមកពីដឹកកណ្តាប់ស្រូវវិញ គាត់រាកមួលយ៉ាងខ្លាំង ហើយបានចូលមន្ទីរពេទ្យតែគ្មានពេទ្យណាយកចិត្តទុកដាក់ថែទាំគាត់ឡើយ ។ ពុំទាន់ធូរស្រាលផង ម៉េន ក៏បានចាត់តាំងឲ្យគាត់ទៅលើកប្រព័ន្ធប្រឡាយទឹកនៅភូមិគោកមនរយៈពេល៨ខែទៀត ។ ការងារមួយពុំទាន់ធ្វើចប់សព្វគ្រប់ផង ម៉េន ចាត់តាំងឲ្យគាត់ភ្ជួរស្រែនៅឯភូមិស្បាទៅដឹកអំបិលនៅភូមិព្រែកពោធិទៀត ។ ផន់ ជាយុវកកដែលធ្វើការនៅក្នុងអគ្គភាពបានបន្ទោសគាត់ថា «ឯងប្រយ័ត្នងាប់រាកខ្លាំងផងហើយទៅឆ្ងាយទៀត» ហើយគាត់ក៏បានប្រាប់ឲ្យទៅកាប់ដើមថ្នាំមួយចំនួនយកទៅដាំទឹកដឹក ។

នៅឆ្នាំ១៩៧៨ ឪពុកខ្ញុំបានសុំមេគោចាស់មួយក្បាលពីប្រធានក្រុមរោងបាយឈ្មោះ ឃួន ដើម្បីយកមកចិញ្ចឹម ។ មួយឆ្នាំក្រោយមកគោនោះកើតបានកូនមួយ ។ ម៉េន ឃើញដូចនេះក៏មកសុំកូនគោពីគាត់ ។ ឪពុកខ្ញុំបដិសេធ ព្រោះទម្រាំតែចិញ្ចឹមបានធំល្អមិនមែនជាការងាយស្រួលទេ ។ ម៉េន និង សែម ដែលជាអ្នកពូកែអែបអបបានទិតៀនគាត់ពេលប្រជុំថាគាត់នៅមាន «កម្មសិទ្ធិក្រាស់» ។ ប្រធានភូមិបានព្រមានគាត់ថា «ប្រយ័ត្នបាត់ខ្លួនកុំស្រលាញ់ពេក» ។ ប៉ុន្តែប្រជាជននៅក្នុងក្រុមទាំងអស់បានជួយនិយាយសម្រួលជាមួយអ្នកទាំងពីរដើម្បីកុំឲ្យមានរឿងរ៉ាវវែងឆ្ងាយដល់គាត់ ។ ចំណែកគណៈប្រធានរោងបាយបានពិចារណាពីហេតុផលរបស់ឪពុកខ្ញុំ ហើយយល់ស្របថាការបដិសេធរបស់ឪពុកខ្ញុំ ត្រឹមត្រូវទើបរឿងរ៉ាវនោះស្ងប់ទៅវិញ ។ ឪពុកខ្ញុំនិងមិត្តគាត់ម្នាក់ឈ្មោះឡៃគីម មិនដែលបានហូបគ្រប់គ្រាន់ទេ បណ្តាលឲ្យគាត់កើតជំងឺហើមដៃហើមជើង ។ នៅឆ្នាំដដែល ពេលដែលគាត់កំពុងបរទេះគោទៅភូមិស្បា ប្រធានចុងភៅពីរនាក់បានសុំគាត់ទៅជាមួយ ។ គាត់ទទួលអ្នកទាំងពីរដោយរីករាយព្រមទាំងមានគំនិតសុំអាហារហូបខ្លះផង ។ ចុងភៅទាំងពីរប្រាប់គាត់ថា បើមិត្តហូបមិនគ្រប់មកហូបនៅភូមិរបស់គាត់ទៅព្រោះ នៅភូមិរបស់គាត់សម្បូរហូប ។ នៅពេលល្ងាចឪពុកខ្ញុំ និង ឡៃគីម បានបបួលគ្នាទៅភូមិស្បា ។ ចុងភៅទាំងពីរបានរៀបចំបបរនិងសម្លស្ងោរត្រឡាច សាច់ជ្រូកទុកឲ្យជាស្រេច ។ ដោយសារឃ្លានខ្លាំងពេកឪពុកខ្ញុំហូបពុំបានគិតអ្វីទាំងអស់ ចំណែក ឡៃគីម មិនហ៊ានហូបទេព្រោះខ្លាច ម៉េន យកទៅរៀនសូត្រ ។ នៅសហករណ៍ឯណោះវិញដោយបាត់គាត់ទាំងពីរមិនបានមកប្រជុំ ម៉េន ក៏ទិតៀននៅពេលប្រជុំទៀត ។ អ្នកជិតខាងបានលួចប្រាប់ពីដំណឹងនេះដល់ឪពុកខ្ញុំដើម្បីឲ្យគាត់ប្រយ័ត្នប្រយែងខ្លួន ។

ការរស់នៅរបស់ម្តាយខ្ញុំគឺខុសពីឪពុកខ្ញុំ ។ ម្តាយខ្ញុំបានទទួលការយោគយល់ច្រើនពីប្រធានសហករណ៍និងប្រធានក្រុមពីព្រោះគាត់កូនខ្ចីកំណើតបងស្រីទី៣ ។ ម្យ៉ាងទៀត ម្តាយខ្ញុំមានជំងឺប្រចាំកាយមិនអាចធ្វើការធ្ងន់បានទេ ។ ប្រធានក្រុមអនុញ្ញាតឲ្យគាត់សម្រាកនៅផ្ទះ ។ ស្ទើរតែពេញរបបខ្មែរក្រហមម្តាយខ្ញុំដើរទៅចម្ការក្បែរផ្ទះបានតែ៦-៧ដងប៉ុណ្ណោះ ។ នេះជាសំណាងមួយដែលនៅក្នុងសហករណ៍ពុំសូវមានការតឹងតែងដូចនៅភូមិដទៃទៀត ។ ប៉ុន្តែមានលំបាកច្រើននៅពេលពួកនិរតីបានចូលមកកាន់កាប់ភូមិនៅឆ្នាំ១៩៧៨ ។ ពួកនេះសម្លាប់មនុស្សគ្មានការយោគយល់អ្វីទាំងអស់ ។ ឪពុកម្តាយខ្ញុំរស់នៅក្នុងជីវភាពនេះរហូតដល់វៀតណាមមករំដោះនៅថ្ងៃ៧មករា ឆ្នាំ១៩៧៩ ។

បទពិសោធន៍របស់ឪពុកម្តាយខ្ញុំ គឺជាផ្នែកមួយដែលផ្តល់ឲ្យខ្ញុំដឹងពីហេតុការណ៍ និងស្ថានភាពរស់នៅយ៉ាងលំបាករបស់ប្រជាជនខ្មែរក្នុងរបបខ្មែរក្រហម ។ មិនមែនមានតែឪពុកខ្ញុំទេដែលទទួលរងលំបាកគឺមានប្រជាជនរាប់ពាន់ម៉ឺនសែននាក់ទៀតក៏រស់នៅទាំងលំបាក ឈឺចាប់ផ្លូវកាយនិងចិត្ត ការនិរាសព្រាត់ប្រាសស្លាប់បងប្អូន និងសាច់ញាតិដែរ ។ បច្ចុប្បន្ន ខ្ញុំកាន់តែយល់ដឹងថែមទៀត តាមរយៈការអានសៀវភៅនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបណ្ណាល័យមួយចំនួន និងតាមរយៈការសាកសួរមនុស្សចាស់ៗអំពីប្រវត្តិក្នុងសម័យខ្មែរក្រហមនៅតាមបណ្តាខេត្តមួយចំនួន ។

ទោះបីជារយៈពេលបីទសវត្សរ៍ជារយៈពេលរង់ចាំយូរក្នុងការរង់ចាំយុត្តិធម៌និងស្វែងរកការពិតមួយរបស់ប្រជាជនខ្មែរ ប៉ុន្តែគាត់នៅតែអាចរង់ចាំបានក្នុងការបង្កើតតុលាការមួយដែលមានឈ្មោះថា «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ដើម្បីកាត់ទោសមេដឹកនាំកំពូលទាំង៥រូប ដែលសព្វថ្ងៃកំពុងត្រូវបាន

ឃុំខ្លួននៅក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញ ។ តុលាការនេះបានធ្វើឲ្យមានភាពស្មើគ្នាចំពោះមុខច្បាប់រវាងប្រជាជនជាជនរងគ្រោះនិងមេដឹកនាំកំពូលនៃរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការបំពេញបណ្ដឹងរបស់ជនរងគ្រោះ ។ នេះជាកិច្ចការដ៏មានសារសំខាន់សម្រាប់ឲ្យខ្ញុំមានឱកាសបានចូលរួមចំណែកជួយប្រជាជនក្នុងការបំពេញពាក្យបណ្ដឹងដើម្បីបញ្ជូនទៅសាលាក្ដីខ្មែរក្រហមតាមរយៈ «គម្រោងនៃការចូលរួមរបស់ជនគ្រោះ»របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលអាចជួយប្រជាជនកម្ពុជាដែលធ្លាប់បានដាក់ពាក្យប្ដឹងតាមរយៈញត្តិដែលបានធ្វើឡើងនៅទសវត្សរ៍ឆ្នាំ១៩៨០ ។ ដំណើរការកាត់ក្ដីនេះនឹងផ្ដល់ឲ្យជនរងគ្រោះអាចបញ្ចេញសំឡេងរបស់ខ្លួនអំពីរឿងរ៉ាវពិតក្នុងរបបដ៏សែនជូរចត់ហើយនឹងអាចធ្វើឲ្យគាត់បានទទួលនូវការផ្សះផ្សា ។ ស្របនឹងពេលនេះដែរ ពុំមែនចំពោះតែប្រជាជនដែលជាជនរងគ្រោះក្នុងសម័យខ្មែរក្រហមទេដែលកំពុងចង់ដឹងរកការពិតនិងយុត្តិធម៌ សូម្បីតែខ្ញុំជាក្មេងជំនាន់ក្រោយក៏មានក្ដីសង្ឃឹមថាតុលាការនឹងសម្រេចការងារនិងលទ្ធផលដែលអាចទទួលយកបាន ។ ព្រឹត្តិ-ការណ៍នេះនឹងក្លាយជាប្រវត្តិសាស្ត្រសម្រាប់ក្មេងជំនាន់ក្រោយបានយល់ពីរបបខ្មែរក្រហម ជាការព្រមានដល់មេដឹកនាំជំនាន់ក្រោយកុំឲ្យយកគំរូនេះមកអនុវត្តទៀតនិងផ្ដល់ឲ្យមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបានថ្លឹងថ្លែងពីដើមហេតុដែលនាំឲ្យប្រទេសធ្លាក់ដល់ចំណុចសូន្យ ពិសេសលទ្ធផលសម្រាប់ពេលបច្ចុប្បន្នដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូបបានទទួលនូវសន្តិភាពនិងការផ្សះផ្សាជាតិ ។

**សេង គន្ធី**

*លិខិតពីមិត្តអ្នកអានៈ*

# សេចក្ដីអំពាវនាវពីជនរងគ្រោះក្នុងរបបខ្មែរក្រហម

ក្នុងនាមខ្ញុំបាទជាជនរងគ្រោះម្នាក់ដែរ ក្នុងចំណោមជនរងគ្រោះជាច្រើនទៀត ខ្ញុំសូមស្វាគមន៍យ៉ាងពេញទំហឹងចំពោះបច្ចុប្បន្នភាពនៃដំណើរការសាលាក្ដីខ្មែរក្រហមដែលកំពុងវិវត្តន៍ជាប់ជាប្រចាំតាមនីតិវិធីច្បាប់ស្របតាមស្ដង់ដារអន្តរជាតិ បើទោះបីជាកំពុងមានបញ្ហាខ្លះៗចំពោះមុខនៅខាងមុខនេះក្ដីដូចជាកង្វះខាតថវិកាបម្រុងសម្រាប់ដំណើរការសាលាក្ដីនេះឲ្យបានចប់ជាស្ថាពរនិងបញ្ហាផ្សេងៗ(បណ្ដឹងរដ្ឋប្បវេណី) ទៀត ទាក់ទងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទចំនួន២នាក់ (នួន ជា និង ខៀវ សំផន) ដែលកំពុងតែដំណើរការកាត់ក្ដី ។

ពិតមែនហើយ សាលាក្ដីខ្មែរក្រហមបានអនុវត្តនូវនីតិវិធីច្បាប់ស្របតាមស្ដង់ដារអន្តរជាតិ ដោយផ្ដល់ឱកាសឲ្យកូនក្ដីតាមរយៈមេធាវីបានទទួលសិទ្ធិធ្វើការតវ៉ាឬប្រឆាំងនានាដែលគេគិតថានៅមិនទាន់គ្រប់លក្ខណៈច្បាប់ដែលត្រូវបានផ្ដល់ឲ្យក្នុងអំឡុងពេលធ្វើសវនាការ ឬទាក់ទងនឹងស្ថានភាពនៃការឃុំខ្លួនបណ្ដោះអាសន្នរបស់ខ្លួន(ស្ថានភាពនៃមន្ទីរឃុំឃាំង) តាមការអះអាងរបស់ជនត្រូវចោទ ។ តាមរូបភាពនេះ ខ្ញុំសូមគាំទ្រនិងអះអាងថា យ៉ាងណាក៏ដោយ ជនត្រូវចោទកំពុងត្រូវបានផ្ដល់ ឬខ្លួនគាត់បានទទួលនូវយុត្តិធម៌មួយយ៉ាងសមរម្យរួចទៅហើយនិងស្របទៅតាមនីតិច្បាប់រួចដែរ (អាចធ្វើការតវ៉ាបានចំពោះអ្វីដែលខ្លួនយល់ថាមិនមានយុត្តិធម៌ដល់ខ្លួន រស់ក្នុងបន្ទប់ឃុំឃាំងមានលក្ខណៈទំនើបតាមស្ដង់ដារអន្តរជាតិ ទទួលបាននូវការថែរក្សានិងការព្យាបាលសុខភាព) ក្នុងនាមគាត់ជាប្រជាពលរដ្ឋម្នាក់ដែលកំពុងរស់នៅក្នុង



សង្គមបច្ចុប្បន្ន ហើយមានសិទ្ធិស្មើគ្នាដូចពលរដ្ឋដទៃទៀតដែរ នេះប្រសិនបើប្រៀបធៀបទៅនឹងអ្វីដែលប្រជាពលរដ្ឋខ្មែរទាំងអស់បានទទួលពីរបបខ្មែរក្រហមក្នុងអំឡុងពេលដែលខ្មែរក្រហមកំពុងកាន់កាប់អំណាចនៅចន្លោះថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៧មករា ឆ្នាំ១៩៧៩គឺមិនដូចគ្នាទាល់តែសោះ ឬអាចនិយាយបានថា ជាមហាអយុត្តិធម៌សម្រាប់ពលរដ្ឋខ្មែរដែលជាជនរងគ្រោះរស់នៅក្រោមរបបកាន់កាប់របស់ខ្មែរក្រហម ។

ភាពអយុត្តិធម៌នេះបានកំពុងធ្វើឲ្យអារម្មណ៍ជនរងគ្រោះដែលស្ងប់ស្ងាត់យូរមកហើយតាមរយៈស្ថានភាពឬវិធីសាស្ត្រផ្សេងៗ (យកព្រះធម៌រំងាប់ការសងសឹក យកនយោបាយផ្សះផ្សាជាតិរំងាប់ការសងសឹក ។ល ។) បានផុតបញ្ចោះឲ្យពុះកញ្ជ្រោលឡើងវិញដើម្បីទាមទារយុត្តិធម៌តាមរយៈការគាំទ្រយ៉ាងពេញទំហឹងចំពោះដំណើរការសាលាក្តីខ្មែរក្រហម ។ តើអ្វីទៅជាយុត្តិធម៌ដែលជនរងគ្រោះទាំងអស់កំពុងទាមទារ? ចម្លើយគឺពិតជាមិនខុសទេដែលថា ជនរងគ្រោះទាំងអស់គ្រាន់តែចង់ឃើញនូវលទ្ធផលនៃការកាត់ទោសជនត្រូវចោទទាំង៥នាក់ ដោយតុលាការនៃសាលាក្តីខ្មែរក្រហម ទោះបីជាជនទាំង៥នាក់នោះត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារក្នុងម្នាក់ៗរយៈពេលប៉ុន្មានឆ្នាំក្តី(ច្បាប់ប្រទេសកម្ពុជាបច្ចុប្បន្នមិនមានទោសប្រហារជីវិតទេ) ឬមួយក៏កាត់ក្តីឲ្យរួចទោសនោះគឺ ជាយុត្តិធម៌ដែលជនរងគ្រោះដង្ហោយចង់បាននោះដើម្បីឲ្យជនរងគ្រោះទាំងនោះទទួលបាននូវការផ្សះផ្សាផ្លូវចិត្តដែលធ្លាប់រងរបួស ។

ប៉ុន្តែតើអ្វីទៅដែលជាលទ្ធផល ជាគុណភាពរបស់សាលាក្តីខ្មែរក្រហមចង់ផលិតក៏ដូចជា សាធារណជន រួមទាំងជនរងគ្រោះចង់ឃើញនោះ? អ្វីទៅដែលជាបំណងប្រាថ្នារបស់ជនត្រូវចោទទាំង៥នាក់ដែលអ្នកខ្លះ ឬទាំងអស់គ្នាមានសុឆន្ទៈចង់បង្ហាញដល់ជនរួមជាតិនិងពិភពលោកតាមរយៈសាលាក្តីនេះឲ្យបានដឹងនូវបុព្វហេតុពិតនៃការឈានមកដល់នៃរបបរបស់ខ្លួន ហើយដែលត្រូវបានលាយឡំទៅវិញគួរឲ្យសោកស្តាយ?

ដូចនេះ ខ្ញុំសូមអំពាវនាវដល់លោកដែលជាជនត្រូវចោទទាំង៥នាក់ (អតីតសមមិត្ត-សមមិត្តនារី មានៈ នួន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, កាំង ហ្គេកអ៊ាវ (ហៅ ឌុច) សូមមេត្តាពិចារណាឡើងវិញនូវប្រតិកម្មរបស់ខ្លួនក្នុងអំឡុងពេលសាលាក្តីកំពុងដំណើរការ (ការចោទប្រកាន់ទោសដោយសហចៅក្រមស៊ើបអង្កេត) ថាតើគួរធ្វើយ៉ាងណាដើម្បីជួយពន្លឿនសវនាការកាត់ទោសនេះឲ្យបានឆាប់ចប់ ដើម្បីឲ្យជនរួមជាតិក៏ដូចជាពិភពលោកដែលកំពុងតែទន្ទឹងរង់ចាំបានដឹងនូវបុព្វហេតុពិតនៃការឈានមកដល់ការកាន់កាប់អំណាចរបស់ខ្មែរក្រហម ព្រោះថាសាក្សីនៅរស់នៃរបបនោះ មានតែអស់លោកទេដែលអាចបំភ្លឺការពិតបាន ។ បើទោះបីជាមានអ្នកប្រាជ្ញប្រវត្តវិទូ និងអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រជាច្រើនបានសរសេរជាសៀវភៅរួចមកហើយ ដោយផ្អែកតាមឯកសារនានាបានធ្វើការសន្និដ្ឋានជាលក្ខណៈវិទ្យាសាស្ត្រក៏ដោយ ដោយលើកជាមូលហេតុយ៉ាងនេះ ឬជាមូលហេតុយ៉ាងនោះក្តី តែនេះក៏គ្រាន់ជាការសន្និដ្ឋានដែលមិនទាន់មានការអះអាងបំភ្លឺពីសាមីពាក់ព័ន្ធដើម្បីគាំទ្រចំពោះការសន្និដ្ឋាននោះនៅឡើយទេ ។

ចំពោះលទ្ធផលនៃសវនាការកាត់ក្តីរបស់តុលាការបានចេញយ៉ាងណាក៏ដោយ ហើយត្រូវបានជនរងគ្រោះទទួលស្វាគមន៍ឬប្រតិកម្មក្នុងកម្រិតណានោះ សម្រាប់មតិខ្ញុំ ខ្ញុំក៏នឹងមិនមានប្រតិកម្មឬជំទាស់អ្វីដែរ ដោយហេតុថានេះជាសាលាក្តីដែលមានលក្ខណៈស្តង់ដារអន្តរជាតិ (ព្រោះប្រទេសផ្តល់ជំនួយបានផ្តល់ថវិកាសម្រាប់ដំណើរការសាលាក្តី) ។ ប៉ុន្តែអ្វីដែលជាសារសំខាន់ សម្រាប់ខ្ញុំនោះគឺ គុណតម្លៃនៃការដែលបង្ហាញការពិតរបស់ប្រវត្តិសាស្ត្រពីអ្នកណាម្នាក់នៃរឿងរ៉ាវអ្វីមួយដែលកំពុងឋិតនៅក្នុងការមន្ទិលទាំងនោះឯងដែលខ្ញុំចាត់ទុកថាជាវីរបុរសប្រវត្តិសាស្ត្រនៅក្នុងកាលប្រវត្តិឯកជនរបស់ខ្ញុំ បើទោះបីជាអ្នកដទៃមិនយល់ដូចខ្ញុំក៏ដោយ (ប្រវត្តិសាស្ត្រពិតមានតម្លៃ ថ្លៃជាងមាសប្រាក់ដែលមនុស្សឲ្យតម្លៃ) ។ (សូមកុំឲ្យការពិតដ៏មានតម្លៃថ្លៃឥតគណនាកប់បាត់ទៅតាមការវិវត្តនៃវ័យរបស់អស់លោកឲ្យសោះ ។

ជាបញ្ចប់ ខ្ញុំអំពាវនាវជាថ្មីម្តងទៀតចំពោះលោកជាជនត្រូវចោទទាំងអស់ថា សូមលោកមេត្តាក្លាហានឡើងដើម្បីធ្វើការស្រាយបំភ្លឺឲ្យពិភពលោកនិងជនរួមជាតិយើងបានដឹងនូវអ្វីដែលកំពុងតែមន្ទិលចំពោះបុព្វហេតុដ៏មានតម្លៃរបស់ខ្មែរក្រហមដែលមានអស់លោកជាអ្នកចូលរួមចំណែកកសាងឡើង ។

**ភី ម៉ាន់ដែន**

# ដំណឹងស្វែងរកឪពុកឈ្មោះ ជី ចំរើន

ខ្ញុំបាទឈ្មោះ វឌ្ឍនា ជី សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក សូមសួររកឪពុកឈ្មោះ ជី ចំរើន ដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមប្រហែលជាក្នុងខែមេសា ឆ្នាំ១៩៧៥ ។ មុនឆ្នាំ១៩៧៥ ឪពុកខ្ញុំអ្នកវាយសីនិងជាប៉ូលីស ។

ប្រសិនបើបងប្អូនណាបានស្គាល់សូមទំនាក់ទំនងមកខ្ញុំបាទតាមអ៊ីម៉ែល vathana_chy@dot.ca.gov ឬតាមអាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ ខ្ញុំបាទនឹងមានជូនជាសគុណ ។








ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 100, April 2008 ◆ Funded by Denmark, Norway, Sweden, and USA.

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.